NOW AT PHILADELPHIA
Youth Voice Project
Broadcasting on
Channal 1540 AM Radio
Every Saturday 3 PM


The Voice of Khmer American Radio

# ខ្មែរប៉ុស្តិ៍ thekhmer Post

ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍
ហ្វីឡាដែលហ្វីយ៉ា
❖សុបិន : (២៦៧) ២៥៣-៣៩៤៧
❖ទូរស័ព្ទ នៅរ៉ូដអាយឡិន
❖សេរី : (៤០១) ៩១៩-៩៩៥៤
ទូរស័ព្ទវិទ្យុសម្លេងខ្មែរអាមេរិកាំង
❖ស៊ីជន : (២១៥) ២៨៤-១៣៤៣
Email : thekhmerpostEC@gmail.com

KHMER BILINGUAL BIWEEKLY NEWSPAPER
VOLUME 02 ISSUE 14 May 22th-07th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM

# បោះឆ្នោតនៅសហរដ្ឋអាមេរិក:
## ដាក់ខ្សែក្រវ៉ាត់ផ្លូវរលាក់ហើយ




សូមអាននៅទំព័រទី០៤

## The 2nd Annual Asian Pacific American Heritage Month

•••ទិវាវប្បធម៌អាស៊ីប៉ាស៊ីហ្វិកអាមេរិកាំង ឆ្នាំទី២ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៧ នៅសួនឧទ្យាន "ហ្វ្រង់ក្លីនស្ក្វែ" នៃទីក្រុងហ្វីឡាដែលហ្វីយ៉ា ចូលរួមដោយអភិបាលរដ្ឋផែនស៊ីវេនិញ សិល្បៈអាស៊ីប៉ាស៊ីហ្វិក បានត្រូវយកមកចូលរួមសំដែងចែកជូនសាធារណជនកំសាន្ត ។





សមាគមខ្មែរ បាននាំរបាំបីឈុតមក ចូលរួម និងរបាំសិល្បៈជនជាតិដទៃទៀត មាន ចិន, យួន, ហ្វីលីពីន, ឥណ្ឌូនេស៊ី, ជប៉ុន, កូរ៉េ, ថៃ និងឥណ្ឌា ៕

# កញ្ចក់ឆ្លុះខ្មែរអាមេរិកាំង

**ដោយ : ពិន សំខុន**

"ខ្មែរប៉ុស្តិ៍" តែងតែរំលឹកនូវស្ថានភាពខ្មែរ- អាមេរិកាំងនៃទីក្រុងៗ ៣ ដែលសំបូរខ្មែរ រស់នៅជាងគេថា"ជាអម្បូរខ្មែរអង្គរយើងជាកូនចៅពំទាន់មានអ្វី សម្រាប់អួតអាងបាននៅឡើយទេ ដោយហេតុថា សមាគមន៍ខ្មែរទាំងបី មាន ហ្វីឡាដែលហ្វីយ៉ា, ឡូវែល និងឡុងប៊ិច កំពុងប្រទះនឹង ការលំបាកខាងផ្នែកសេដ្ឋកិច្ច, ខាងសង្គម , ខាងវប្បធម៌យ៉ាងជ្រាលជ្រៅ" ។ មកទល់នឹងថ្ងៃនេះ គ្មានសញ្ញាណាមួយ ចង្អុលថា ស្ថានភាពលំបាកនេះ នឹងអាចកែប្រែឱ្យបានប្រសើរឡើងនៅពេលណាមួយខាងមុខនៅឡើយទេ ។

បើតាមក្រសែភ្នែកអ្នកស្រុកខ្មែរ ឬក៏បញ្ញាវន្តធូរធារមួយចំនួនតិចតួចនោះ សមាគមន៍ ខ្មែរយើងហាក់ដូចជា នៅមានរស្មីភ្លឺថ្លានៅឡើយ ក៏ប៉ុន្តែបើតាមស្ថិតិរបស់អង្គការជាតិបានបង្ហាញជោគជ័យនៃការសិក្សារបស់កូនខ្មែរ ពុំលើសពួកមង, ពួកលាវ ដែលជាសមាគមន៍ទន់ទាបពីក្រោយពួក យួន ពួកចិន កូរ៉េ ហ្វីលីពីន ។ល។ ជាទូទៅលើស៥០%កុនខ្មែររៀនបានក៏វិតទាបជាវិទ្យាល័យ ហើយអ្នកមានប្រកបការងារទៀតទាត់មិនបាន៤០%ទេ បើរបរពាណិជ្ជកម្មខ្នាតតូចតិចតួច ហើយមិនរកស៊ីចូលហ៊ុនគ្នាទេ ។ តួលេខនេះ តម្រូវឱ្យបញ្ញាវន្តខ្មែរ ដែលបានទទួលការបណ្តុះបណ្តាលសមរម្យរួចហើយនោះ ងាកមករកវិធីជួយសមាគមន៍ទន់ខ្សោយ ឱ្យបានងើបលើងរួច ឱ្យបានទាន់ពេល ។ (តទៅទំព័រទី២២)

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង
AM 1540 ផ្សាយចេញពីស្ថានីយ៍ New world Radio



វិទ្យុសម្លេងខ្មែរអាមេរិកាំង
Youth Voice Project
Phone : Glenn Wrighten
267-918-6284
Every Saturday 3-4 PM
Voice of Khmer
Phone :
(215) 722-2226

# សំពាធនយោបាយញាំញី រណឬទ្ធិ, សមរង្ស៊ី តាមប្រព័ន្ធតុលាការ

*ហុងកុង : មាជ សុវណ្ណារ៉ា*

●●●ទាំងអ្នកវិភាគនយោបាយអ្នកច្បាប់ និងអ្នកការទូតបានអះអាងថា រាល់ករណីប្តឹងប្តល់ទៅលើសម្តេចក្រុមព្រះនរោត្តម រណឬទ្ធិ និង សម រង្ស៊ី ក្តី គឺជានិន្នាការនយោបាយមិនឯករាជ្យក្នុងប្រព័ន្ធតុលាការខ្មែរ បច្ចុប្បន្ន ដែលស្ថិតក្នុងសំពាធឥទ្ធិពលអ្នកមានអំណាច ដែលអាចធ្វើឱ្យប៉ះពាល់ការបោះឆ្នោតនាពេលខាងមុខ ។


បណ្ឌិត ឡៅ ម៉ុងហៃ (រូបថតខ្មែរប៉ុស្តិ៍)

អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គការសិទ្ធិមនុស្សអាស៊ីមានមូលដ្ឋាន នៅក្រុងហុងកុង បណ្ឌិត ឡៅ ម៉ុងហៃ បានផ្តល់បទសំភាសន៍ដល់កាសែតខ្មែរប៉ុស្តិ៍ឱ្យដឹងថា តាមរបាយការណ៍ផ្សេងៗ ឬការអង្កេតរបស់លោកបានឃើញថា តុលាការមិនទាន់មានឯករាជ្យនៅឡើយទេ ព្រោះនៅក្រោមសំពាធនយោបាយ ហើយអ្នកនយោបាយមានពាក់ព័ន្ធក្នុងរឿងក្តីក្តាំគ្នា គឺជាការចៀសវាងមិនរួចពីនិន្នាការដូចជាករណីលោកឧបនាយករដ្ឋមន្ត្រីខ្មែរ ហោ ណាំហុង ជាមេដឹកនាំគណបក្សប្រជាជនកម្ពុជា និង សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំង ហើយចៅក្រមនិងព្រះរាជអាជ្ញាមួយចំនួនធំជាសមាជិកគណបក្សកាន់អំណាច ម្ល៉ោះហើយចង់ ឬមិនចង់គេឃើញនិងយល់ថា តុលាការវាលំអៀងទៅហើយ ដែលការកាត់ក្តីវាអត់បានត្រឹមត្រូវ ។

លោក ឡៅ ម៉ុងហៃ បានបន្តថា បញ្ហាមូលដ្ឋានដែលយើងមើលមិនឃើញ មិនមែនរឿងត្រង់ប្តឹងប្តល់គ្នានោះទេ ។ គឺត្រង់រឿងតុលាការឯករាជ្យមានអនាគតិឥតលំអៀង ឬអត់ វាជាការគ្រប់គ្រាន់ទៅហើយ ដោយតុលាការឯករាជ្យ

( តទៅទំព័រទី០៧ )

# សម រង្ស៊ី ស្រមៃ ចន ម៉ាកខេន ប្តូររបប ហ៊ុន សែន

## ចន ម៉ាកខេន បេក្ខជនប្រធានាធិបតីអាមេរិក ចេញពីអ្នកទោសឈ្លើយសឹកសង្គ្រាមនៅយួន




*ឡុងប៊ិច : មាជ សុវណ្ណារ៉ា*

●●●មេដឹកនាំគណបក្ស ប្រឆាំង សម រង្ស៊ី កំពុងស្រមៃបេក្ខជនប្រធានាធិបតីសហរដ្ឋ អាមេរិក ចន ម៉ាកខេន ដោយអះអាងថា បើសិនលោក ចន ម៉ាកខេន បានជាប់ឆ្នោតជាប្រធានាធិបតី រូបគាត់ច្បាស់ជាជួយប្រទេសកម្ពុជាពេញទំហឹង ដោយការជំរុញនោះ គឺគ្រាន់តែបញ្ចេញនូវរបាយការណ៍របស់ខ្លួនពីរឿងរ៉ាវឧក្រិដ្ឋកម្មនានា នៅកម្ពុជា ដែលកំពុងស្ថិតនៅក្នុងដៃ FBI គឺជាការបញ្ចប់អនាគតជីវិតនយោបាយរបស់ ហ៊ុន សែន និងការប្តូររបបហ៊ុន សែន លោក សម រង្ស៊ី បានថ្លែងបែបនេះ នៅក្នុងពិធីជួបបងប្អូនខ្មែរនៅសហគមន៍ខ្មែរក្រុងឡុងប៊ិច ដែលមានមនុស្សចូលរួមស្តាប់លោកប្រមាណជិត២០០នាក់ កាលពីចុងខែមេសាកន្លងទៅនេះ ។

ចន ម៉ាកខេន ជាជនខ្លាំងម្នាក់នៅក្នុងតំណែងលោកជាសមាជិកព្រឹទ្ធសភាអាមេរិកពីដើម រហូតមកតែងតែប្រឆាំងរាល់ទង្វើដឹកនាំរបស់លោក ហ៊ុន សែន ដែលបានធ្វើការរំលោភបំពានផ្នែកសិទ្ធិមនុស្សការកាប់

( តទៅទំព័រទី១៤ )

AUTOGRAPH
Audio Visual Vehicle Design Specialist
Wimean Hing
Cell: (215) 892-4122

ហាងកូនខ្មែរសំរាប់ដាក់ "អូឌីយ៉ូ " ដាក់ " ការពារកុំឱ្យចោរលួចដាក់ម៉ាស៊ីនសំរាប់ជួយរកផ្លូវ នឹងគ្រឿងអេឡិចត្រូនិចច្រើនទៀត"



-Audio
-Video and Navigation Systems
-Wheels and Tires
-Satellite Radio
-GPS Tracking
-Alarm and Remote Start
-Custom Fiberglass Enclosures and Accessories

"អូតូក្រាហ្វ" ជាហាងរបស់កូនខ្មែរ ដែលមានបទពិសោធន៍ខ្ពស់ ក្នុងការដាក់សម្ភារៈបន្ថែម ឬ អេឡិចត្រូនិចបំរើលោក-អ្នកមិនឱ្យខុសចិត្តឡើយ ។
បើចង់បានព័ត៌មានបន្ថែម សូមរកវិមាន ហ៊ីង

7114 State Road
Philadelphia, Pa 19135
Phone : (215) 333-3723
Fax : (215) 333-3715
vimeanhing@autogrpahcar.com, www.autographcar.com

LOGAN OLNEY
EPIC STAKEHOLDERS
COMMUNITY HEALTH FAIR

"LIVING GREAT IN 08"
Co-Sponsor by: Logan Olney Jr. Stakeholders

ទិវា "រួមរស់ដោយសុខភាពល្អ ក្នុងឆ្នាំ ២០០៨ "
- មានឆ្នោតវត្ថុ
- មានឱ្យរបស់របរច្រើនមុខ
- មានទទួលភេសជ្ជៈ

Date: SATURDAY MAY 31st, 2008
Time: 10 A.M. – 3 P.M.




GROVER WASHINGTON
MIDDLE SCHOOL
201 EAST OLNEY AVENUE
(B & OLNEY AVENUE)

RAFFLES!
GIVEAWAYS!
REFRESHMENTS!

FOR MORE INFORMATION CONTACT:
CHARLENE SAMUELS (215)-456-5561
VALARIE KEYES (267) 257-2851
CHARLOTTE SHAW (267) 456-5561

ALL ARE WELCOME

# Complex Nutrition.Made Simple

លោកមានសុខភាពរាល់ថ្ងៃ មិនប្រក្រតី អស់កម្លាំង ផ្កាសាយ លើសឈាម ឈឺឆ្អឹងឆ្អែង ខលខ

## RELIV សុខភាព

ផលិតផលសុខភាពធ្វើពីធម្មជាតិសុទ្ធសាធនៅសហរដ្ឋអាមេរិកឈ្មោះ RELIV នេះ អាចជួយដល់សុខភាពជរាទ្រុឌទ្រោមរបស់មនុស្សចាស់យើងបាន ជាពិសេសជួយដល់មនុស្សធ្វើការច្រើន នាំឱ្យចាស់មុនអាយុ ជួយបន្ថយការឈឺចុកចាប់នៅសន្លាក់ដៃជើង ឬរោគស្ត្រីនិងបុរសមួយចំនួន គេហៅ RELIV នេះថាជា "អាហារសុខភាពល្អ" ស្រួលពិសារ ដែលលោកអ្នកគួរប្រើដូចគ្នានឹងពិសារទឹកក្រូច រាល់ព្រឹកមុននឹងចេញធ្វើការម្តងៗ ដើម្បីលើកកម្លាំងបំពេញការងារដោយងាយស្រួលប្រើប្រាស់ RELIV នៅជុំវិញ សហរដ្ឋអាមេរិកនេះ គ្រប់សាសន៍សព្វាតិបានថ្លែងអំណរគុណដល់ RELIV អាហារ VITAMIN ដែលបានជួយបន្ថយការប្រើថ្នាំនានាច្រើនមុខ ដោយសារតែការផ្សំផលិតផលនេះ ដើម្បីទៅបំពេញដល់ការខ្វះខាតជីវជាតិក្នុងចំណីអាហារ ដែលលោកអ្នកពិសាររាល់ថ្ងៃ ។ មានជីវជាតិចិញ្ចឹមសរីរាង្គ សរីរាង្គយើងក៏ដើរពេញកម្លាំងវិញ ។

ការឈឺថ្កាត់ក៏ថយទៅបាត់ស្មារតីនឹងកម្លាំងអន់ថយក៏កើតឡើងយ៉ាងឆាប់រហ័ស ។ RELIV ជាផលិតផលរបស់របស់អាមេរិក តម្លៃថោកមានប្រសិទ្ធិភាពដែលលោកអ្នករកជាវបានតាមទូរស័ព្ទលេខ.... ហើយប្រាប់លេខ Spsnsor ។

ហើយបើលោកអ្នកចង់ជាវ RELIV
សូមទំនាក់ទំនង តាមលេខទូរស័ព្ទ
**(267)253-3947**



reliv

The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

**របៀបប្រើ :** រៀងរាល់ព្រឹក ដួស RELIV មួយស្លាបព្រាវង្វាល់ពីកំប៉ុង A មួយស្លាបព្រាវង្វាល់មួយទៀត ពីកំប៉ុង B ដាក់ទៅក្នុងកែវមានទឹកធម្មតា ឬទឹកផ្លែឈើ
កូរលាយគ្នា រួចពិសារព្រឹកម្តង ល្ងាចម្តង-
ទទួលលទ្ធផលទាន់ចិត្ត RELIV
CLASSIC : A
RELIV INNERGIZE : B

RELiV 20th anniversary

**Relv,Inc**
P.O.Box JO5
Chesterfield,MO
63006-0405
636-537-9715
Reliv Distributor

**ទូរស័ព្ទសំរាប់ ជាវ (636) 537-9715**
កុំភ្លេចឱ្យលេខ Relive Distributor : RNC.# 7070 438001

**ទូរស័ព្ទ : (267) 253-3947 សំរាប់ហៅ**
**បើលោក-អ្នកបានទទួលលទ្ធផលល្អប្រសើរ ហើយចង់ចែកចាយជូនមិត្តភក្តិបងប្អូនបន្តទៅទៀត លោកអ្នកអាចជាវ Relive Distributor**

**RCN# 7070438001 WWW.reliv.Com**

**Please Call : (267) 253-3947**

# តើនៅលើផ្ទៃមុខលោកអ្នក មានជាំ ឬមុន ឬទេ?




ផលិតផល WHITIMO-WHITESHOT និង WHINKLE SHOT អាចជួយលោកអ្នកបានដ៏មានប្រសិទ្ធិភាព ។
មនុស្សគ្រប់រូបសុទ្ធតែសង្ឃឹមថា នៅលើផ្ទៃមុខរបស់ពួកគេ គឺ "គ្មានជាំ គ្មានមុន" ហើយសង្ឃឹមថា និងអាចរកបាននូវផលិតផលដែលអាចកំចាត់ជាំ និងមុន ព្រមទាំងជួយថែរក្សាស្បែកមុខឱ្យមានភាពស្រស់ស្អាត គ្មានជ្រីវជ្រួញ ។
-**ផលិតផល :** ហ្វៃទីស៊ីម៉ូ ហ្វៃត៍សុត និង ហ្វ្រូ ឃល សុត នឹងជួយដោះស្រាយលោកអ្នកបានយ៉ាងពេញចិត្តដ៏មានប្រសិទ្ធិភាព ។
-ផលិតផលនេះអាចជួយបំបាត់ មុន ជាំ និងស្នាមមុខ និងជួយថែរក្សាស្បែកមុខលោកអ្នក ធ្វើឱ្យស្បែក ស ភ្លឺលោងស្អាត ។
-ផលិផលនេះ អាចប្រើបានជាប្រចាំធ្វើឱ្យស្បែកស្អាតរលោង ២៤ ម៉ោង ក្នុងពេលធ្វើការថ្ងៃ ឬយប់ ។




## ហាងថែរក្សាស្បែក លីន

បានបង្ហាញឱ្យប្រើ "ស្បតអីរេសឺ "ធ្វើឱ្យសាច់ស្បែកលោកអ្នកផ្លាស់ប្តូរយ៉ាងសក្តិសិទ្ធភ្លាមៗ ពីជាំកើតមុន ទៅជាស្បែកភ្លឺថ្លារលោង ហើយឃើញសាច់លោកអ្នកល្អស្អាតឥតខ្ចោះ ។
-សូមសួររកគ្រឿងព្យាបាលថែរក្សាស្បែករបស់លោកអ្នកផ្សេងៗទៀត សំរាប់ព្យាបាលមុខជាំ កើតមុន និងស្បែកជ្រីវជ្រួញ ។
-ផលិតផលនេះ នឹងជួយធ្វើឱ្យស្បែករបស់លោកអ្នកបានស្អាត ល្អភ្លឺរលោង គ្មានជ្រីវជ្រួញជាទីពេញចិត្តលោកអ្នកមិនខុសបំណងឡើយ

# ទស្សនៈ សម្ដេចនរោត្ដម សីហនុ រិះគន់អ្នកគាំទ្រ លន់នល់

**ដោយ : លោក ម៉ម ឃិន**

អតីតព្រះមហាក្សត្រ សម្ដេចនរោត្ដម សីហនុ ដែលខណៈនេះទ្រង់ប្រថាប់នៅ ខេត្តសៀមរាប បានចារក្នុងទំព័រវិប សែថរបស់ព្រះអង្គ Norodom Sihanouk. INFO. ថាពួកលន់ន ល់និយមទាំងប្រុសទាំងស្រី ដែលត្រូវបរាជ័យ ដូចជាចៅហ្វាយអាមេរិករបស់ខ្លួន៥ឆ្នាំ ក្រោយពីរដ្ឋប្រហារថ្ងៃទី ១៨ មុនឆ្នាំ១៩៧០ ហើយ ដែលខណៈនេះ រស់នៅជាជនភៀសខ្លួន ចោលស្រុកចោលទេសទៅនៅសហរដ្ឋអាមេរិក នៅប្រទេសបារាំង និងប្រទេសដទៃទៀត ព្រមទាំងកូនចៅរបស់ពួកគេបានប្រកាសឱ្យដឹងថា នឹងតាមរំខានធ្វើយ៉ាងណាមិនឱ្យសីហនុអាចរស់នៅបានយ៉ាងសុខសាន្តឡើយ បើព្រះអង្គយាងទៅ អាមេរិក បារាំង បែលហ្ស៊ិក អាល្លឺម៉ង់ ។ គឺថា បើហ៊ានតែយាងទៅប្រទេសទាំងនោះ គឺច្បាស់ជានឹងមានធ្វើបាតុកម្មតវ៉ាប្រឆាំ និងជេរប្រទេចផ្ដាសាព្រះអង្គជាមិនខាន ។



សម្ដេចនរោត្ដម សីហនុ ទ្រង់បញ្ជាក់ថា ព្រះអង្គគ្មានបំណងចង់យាងទៅប្រទេស ដែលអស់លោក-អ្នកនាងកញ្ញា ដែលស្អប់ សីហនុ រស់នៅនោះឡើយ ។

ព្រះអង្គក៏បានបញ្ជាក់ផងដែរថា ពួក លន់នល់និយមទាំងប្រុសទាំងស្រីនេះ គប្បីយល់ព្រមទទួលខុសត្រូវចំពោះផលវិបាកនៃបរាជ័យដ៏អាមាស់របស់ពួកខ្លួន កាលពីថ្ងៃទី១៧ មេសា ១៩៧៥ បន្ទាប់ពីបានរស់នៅ៥ឆ្នាំ យ៉ាងគ្មានកិត្តិគុណនាទីក្រុងភ្នំពេញនោះមក ។

( តទៅទំព័រទី០៦ )

**LOGAN OLNEY**
**EPIC STAKEHOLDERS**
**COMMUNITY HEALTH FAIR**
**" LIVING GREAT IN 08 "**

Nazareth Hospital

H.E.A.R.T
HELPING EVERYONE ADDRESS RISKS TODAY

Health Fair at Grover Washington High School
Saturday, May 31st, 2008
10:00 a.m. – 1:00 p.m.

**ដឹងទេថា បេះដូងលោកអ្នក អាចមានបញ្ហា?**

បើចង់ដឹងចូរទៅឆ្លុះមើល ដោយឥតយកថ្លៃ នៅពេទ្យ "ណាស៊ារ៉េត" រៀនពីវិធីបន្ថយគ្រោះថ្នាក់ គាំងបេះដូង ឬ លើសឈាម ឆ្លុះមើលដំណើរបេះដូង គឺរាប់បញ្ចូល :

- **ប្រាប់ពីគ្រោះថ្នាក់ របៀបរស់នៅ**
- **គុណភាពនៃសុខភាព រូបរាងកាយ**
- **កូលេស្តេរ៉ុល និងជាតិស្ករក្នុងឈាម**
- **សំពាធឈាម និងការវាស់កម្លាំងឈាមរត់នៅក្នុងជើង**

**ដើម្បីអោយគេឆ្លុះដំណើរឈាមរត់របស់បេះដូង សូមទូរស័ព្ទ ដើម្បីកំណត់ថ្ងៃទៅជួបពិនិត្យបេះដូង**

**For more information contact: Charlene Samuels**
**(215)-456-5561**

# បង្សុកូល បញ្ជូនមគ្គផលឱ្យ ព្រំ ច័ន្ទម្លិកា

**❖ សាធារណៈជននៅតែចង់ដឹង ម្លិកា ស្លាប់ដោយសារអ្វី ?**

**( អាកា សូមឯងទៅកាន់សុគតិភពចុះ ថ្ងៃនេះក្រុមអ្នកសិល្បករយើងជាអ្នកចម្រៀងអាជីពដូចគ្នាបានធ្វើបុណ្យឧទ្ទិសកុសលបញ្ជូនមគ្គផលជូនប្អូនហើយ ...សូមឱ្យវិញ្ញាណក្ខន្ធឈប់វិលវល់ទៅ សូមឱ្យប្អូនកើតទៅជាមនុស្សជាតិឱ្យបានឆាប់ណា ) ។ នេះជាសំដីបួងសួងរបស់អ្នកស្រី ប្លុង ឫទ្ធី ដែលសកម្មភាពដៃកាន់ធូបប្រណមបុណ្យស្រន់ចំពោះមុខរូបថត ព្រំ ច័ន្ទម្លិកា ។**



អ្នកនាង ព្រំ ច័ន្ទម្លិកា (កាលនៅរស់)

●●●ផ្សែងធូបបានហុយឡើងជាមួយភ្លើងដុតលុយក្លែងក្លាយក្រោមស្នូរសម្លេងព្រះធម៌ ដែលសូត្រដោយព្រះសង្ឃក្នុងការបង្សុកូលបញ្ជូនមគ្គផលទទួលទាន ចង្ហាន់ ទានបច្ច័យ ដើម្បីឧទ្ទិសរំលឹកដល់វិញ្ញាណក្ខន្ធអ្នកចម្រៀង ព្រំ ច័ន្ទម្លិកា ដែលបានចែកឋានទៅកាន់បរលោក សូមឱ្យកើតជាមនុស្ស ឬទេវតាចៀសចាកផុតទៅកើតជានរកប្រេត ។

ក្រុមអ្នកសិល្បៈខ្មែរនៅ Long Beach ចំរុះដោយអ្នកចម្រៀងអ្នកភ្លេងតារាភាពយន្ត ឬខារ៉ាអូខេជាច្រើននាក់ បាននាំគ្នាយកចង្ហាន់ និងទានបច្ច័យទៅកាន់វត្តអារាម ដើម្បីធ្វើបុណ្យឧទ្ទិសកុសលដល់នាង ព្រំ ច័ន្ទម្លិកា កាលពីថ្ងៃទី៣០ខែមេសា កន្លងទៅនេះ ។

ព្រំ ច័ន្ទម្លិកា អាយុ២៩ឆ្នាំ បានទទួលមរណភាពកាលពីថ្ងៃទី០៦ ខែមេសា ដោយមិនដឹងពីមូលហេតុនៃការស្លាប់ច្បាស់លាស់ បណ្ដាលមកពីប្រការណានោះ គឺស្របនឹងថ្ងៃដែលអ្នកក្បួនវប្បធម៌ចូលឆ្នាំខ្មែរនៅក្រុង Long Beach



ការបញ្ជូនមគ្គផលជូនដល់វិញ្ញាណក្ខន្ធ ព្រំ ច័ន្ទម្លិកា



ក្រុមអ្នកចម្រៀងប្រគេនចង្ហាន់ដល់ព្រះសង្ឃបង្សុកូល ឧទ្ទិសកុសលជូន ព្រំ ច័ន្ទម្លិកា



អ្នកស្រី ប្លុង ឫទ្ធី (រូបកណ្ដាល) អ្នកផ្ដួចផ្ដើមធ្វើបុណ្យបង្សុកូលជូន ព្រំ ច័ន្ទម្លិកា

តាមផ្លូវ Anaheim ទីប្រជុំជននៃឈ្មួញខ្មែរចំរុះមុខរបររកស៊ី ។

អ្នកស្រី ប្លុង ឫទ្ធី អ្នកចម្រៀងប្រចាំភោជនីយដ្ឋានឋានសួគ៌ថ្មី ដែលជាអ្នកផ្ដួចផ្ដើមគំនិតធ្វើបុណ្យឧទ្ទិសវិញ្ញាណក្ខន្ធបញ្ជូនមគ្គផលនេះឡើងចំពោះខ្មោច ព្រំ ច័ន្ទម្លិកា ក៏ព្រោះយើងរាល់គ្នាជាអ្នកសិល្បៈរួមអាជីពដូចគ្នាក្នុងនាមមិត្តភ័ក្តិជាមួយការដែលអ្នកចម្រៀងជាច្រើនរូបបានយល់សប្ដិឃើញនាងមកប្រាប់ឱ្យដឹងថា "ការស្លាប់ទៅជាខ្មោចរបស់នាងមិនមានការហូបចុកស្លៀកពាក់គ្រប់គ្រាន់ទេ សូមអ្នករាល់គ្នាជួយផ្ដល់ឱ្យនាងហូបចុក និងមានសំលៀកបំពាក់ស្លៀកផង" ។

អ្នកស្រី ប្លុង ឫទ្ធី បន្តថា ការយល់សប្ដិឃើញនូវភាពសោកសៅបែបនេះ បានជំរុញទឹកចិត្តនៃក្រុមអ្នកសិល្បករយើងទាំងអស់គ្នាឱ្យមូលមតិរៃអង្គាសលុយកាក់ធ្វើបុណ្យបញ្ជូនមគ្គផលចំពោះនាង ។ ហើយនេះមិនជាការជ្រៀតជ្រែកចំពោះគ្រួសាររបស់នាងទេ គឺយើងធ្វើបុណ្យនេះសូមកុំឱ្យមានពាក្យយ៉ាងដូច្នេះ ។

នៅក្នុងពិធីនោះ គេពុំឃើញមានវត្តមានប្ដីរបស់នាងឡើយ ក្រៅតែពីអ្នកចម្រៀងដូចជា មាស សុម៉ាលី, ដារ៉ានី, ដារីយ៉ា, ឡុង ស៊ីដា, អ៊ិន សូលីដា និងតារាដទៃទៀត សុទ្ធតែបានបញ្ចេញមតិដោយដាក់ចម្ងល់ថា ជាការមិនអស់ចិត្តនឹងការស្លាប់របស់ ព្រំ ច័ន្ទម្លិកា ទាំងវ័យក្មេងខ្ចីល្អក់សម្រស់ស្អាតយ៉ាងនេះទេ ។ ពួកគេនិយាយថា ការស្លាប់របស់នាងពុំត្រូវបានឱ្យគេដឹងមកពីមូលហេតុអ្វីទេ ? ។

( តទៅទំព័រទី០៧ )

# ធនាគារខ្មែរ : មួយឆ្នាំកន្លង ផុតទៅ មានអ្វីប្លែក !

***ឡុងប៊ិច : វ៉ានាថ***

•••ក្រោយពីបាយមិត្តភាពក្នុងថ្ងៃគំរប់ខួប មួយឆ្នាំនៃធនាគារខ្មែរមួយឈ្មោះ Goden



ពិធីសម្ពោធធនាគារខ្មែរកាលពីឆ្នាំ២០០៧



នាយកធនាគារ William

Coast Bank កាលពីថ្ងៃទី០៧ ខែឧសភាកន្លងទៅនេះ នាយកធនាគារលោក William T.C.LU បានអះអាងប្រាប់ខ្មែរប៉ុស្ដិ៍ឱ្យដឹងថា អ្វីដែលប្លែកក្រោយពីមួយឆ្នាំដែលធនាគារមួយនេះបានបើកសេវាកម្ម ដើម្បីរកស៊ីជាមួយអតិថិជន ពិសេសបងប្អូនខ្មែរក្នុងសហគមន៍ឡុងប៊ិច មានសន្ទុះគួរឱ្យកត់សំគាល់ ដែលចាប់យកធនាគារនេះធ្វើជាដៃគូ ។

ធនាគារ Goden Coast Bank បានសម្ពោធទីតាំងរបស់ខ្លួនបើករកស៊ីក្នុងតំបន់ខ្មែររស់នៅច្រើនជាងគេបំផុតក្នុងសហរដ្ឋអាមេរិក គឺក្រុងខ្មែរឡុងប៊ិច កាលពីខែឧសភា ឆ្នាំ២០០៧ ។

អ្នកគ្រប់គ្រងទីផ្សាររបស់ធនាគារនេះ លោក អ៊ុង ការី បង្ហាញថា Goden Coast Bank បានវាយលុកទីផ្សារខ្មែរ និងបរទេស ទទួលបាននូវការទុកចិត្ត និងការរកស៊ីជាមួយអតិថិជនគួរឱ្យកត់សំគាល់ ។ ពិសេសបងប្អូនខ្មែរឃើញថាមានអត្រាកើនរហូតដល់ជាង៦០%ជាដៃគូ ។

អ៊ុង ការី បន្តថា ដោយសារតែមានអតិថិជនជាខ្មែរនោះហើយ បានធ្វើឱ្យធនាគារមួយនេះកំពុងឆ្ពោះទៅមុខដោយរលូនក្នុងការខ្ចីប្រាក់ ការប្រាក់តាមប្រព័ន្ធ CD សន្សំ និងការផ្ញើប្រាក់យ៉ាងឆាប់រហ័សទៅកាន់ប្រទេសកម្ពុជា ដែលមានធនាគារ ACLEDA ជាដៃគូកំពុងរកស៊ីជាមួយគ្នា ។

នាយកធនាគារ William អះអាងថា ខ្មែរជួយខ្មែរ ចម្រើនសហគមន៍យើងទាំងអស់គ្នាសូមបងប្អូនទុកចិត្តចុះ ធនាគារយើងមានក្រុមហ៊ុនធានារ៉ាប់រងចំពោះប្រាក់របស់លោក-អ្នកដែលមានកុង Account ក្នុងធនាគាររបស់យើងដែលចេញដោយសហព័ន្ធ FDIC ដោយគ្មានការភ័យព្រួយ លួចបន្លំ ឬបោកប្រាស់នៃការបាត់បង់របស់លោក-អ្នកឡើយ ។ ហើយជូនការប្រាក់ខ្ពស់ជាងបណ្ដាធនាគារផ្សេងៗ នូវ Capital ២៦% ខុសពីធនាគារគេត្រឹមតែ Capital ៨% នោះ ។ ក្រុមអ្នកជំនាញខ្មែរតាមការសំភាសន៍របស់ខ្មែរប៉ុស្ដិ៍ កាលពីឆ្នាំមុនបានស្ទាក់ស្ទើរចិត្តក្នុងការរកស៊ីដាក់ប្រាក់ ឬខ្ចីប្រាក់ជាមួយធនាគារខ្មែរមួយនេះ ព្រោះតែការខ្លាចក្រែងមានការបោកប្រាស់ ។ ប៉ុន្តែឆ្នាំនេះ អ្នករកស៊ីជំនួញជាច្រើន បានចាប់ដៃគូយកធនាគារមួយនេះរកស៊ីជាមួយគ្នាក្នុងការបង្វិលប្រាក់ខ្ចីប្រាក់ បើកកុង Account ដាក់លុយចរាចរ ឬសន្សំប្រាក់ជាដើម ។ ដោយក្រុមអ្នកជំនួញខ្លះនិយាយថា ការរកស៊ីជាមួយខ្មែរដូចគ្នា វាប្រសើរជាងជាតិសាសន៍គេ ទាំងទំនាក់ទំនងវាងាយស្រួល ដែលពួកគេគិតថា ជាការចម្រើនឱ្យខ្មែរទៅវិញទៅមកក្នុងកម្លាំងសាមគ្គីពង្រឹងកិច្ចអភិវឌ្ឍន៍មូលដ្ឋានសេដ្ឋកិច្ចក្នុងសហគមន៍ខ្មែររស់នៅឱ្យមានភាពជឿនលឿនកែប្រែមុខមាត់ និងជីវភាពបងប្អូនខ្មែរឡុងប៊ិច ៕

## សម្តេចន រោត្តម សីហនុ....

អតីតព្រះមហាក្សត្រទ្រង់ចារទៀតថា បើគ្មានគំនិតធ្វើរដ្ឋប្រហារ ១៨ មិនា ១៩៧០ ទេ នោះពួកនេះច្បាស់ជានឹងនៅរស់យ៉ាងសុខសាន្តប្រកបដោយកិត្តិយស និងទ្រព្យសម្បត្តិស្តុកស្តម្ភ ដូចជាពួក ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន និងអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាដ៏មហាប្រសើរ និងជាទីគោរពរាប់អានដទៃទៀត មិនមែនទៅរស់ចោលស្រុកនៅបរទេសដូចសព្វថ្ងៃនេះឡើយ (sic) ។

**<u>មតិអ្នកអាន</u>** : ក្នុងសារលិខិតរបស់អតីតមហាក្សត្រនរោត្តម សីហនុនេះ បានធ្វើឱ្យជនជាតិខ្មែរទាំងអស់ ដែលធ្លាប់បានរស់នៅប្រទេសខ្មែរ កាលពីសម័យចលនាសង្គមរាស្ត្រនិយម ឬរាស្ត្រយំ មានសេចក្តីចុកចាប់យ៉ាងខ្លាំងម្តងទៀត ដោយសារតែចំណារលិខិតនេះ ។

យើងទាំងអស់គ្នាជាជនជាតិខ្មែរ ដែលបានភៀសខ្លួនចាកចេញពីមាតុភូមិជាទីស្រលាញ់លើសជីវិតនេះ មិនមែនពីព្រោះតែប្រព្រឹត្តអំពើក្បត់ជាតិ ដោយទៅចូលដៃជាមួយលោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទំលាក់ប្រមុខរដ្ឋសីហនុនេះទេ ។

យើងភៀសខ្លួនដោយសារតែយើងស្អប់ខ្ពើមពីកាន់អំណាចផ្តាច់ការព្រៃផ្សៃ ដែលប្រើនយោបាយ ដើរខុសពីសន្ធិសញ្ញានៃសន្និសិទអន្តរជាតិ នាក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ស្តីអំពីអព្យាក្រិតឥតលំអៀងរបសប្រទេសកម្ពុជា ដើម្បីថែរក្សាការពារ សន្តិភាព ឯករាជ្យភាព បូរណ និងអធិបតេយ្យភាពទឹកដីឱ្យបានស្ថិតស្ថេរគង់វង្សជារៀងរហូត ។

តើលោក លន់ នល់ បានបាញ់ប្រហារកាប់សំលាប់ប្រជាពលរដ្ឋ និងបំផ្លេចបំផ្លាញ ហេដ្ឋារចនាសម្ព័ន្ធខ្មែរគ្របវិស័យរបស់ខ្មែរ ឬមួយកងទ័ពព្រៃជនជាតិប្រទេសណា ដែលបានលើកទ័ពរាប់ម៉ឺននាក់ វាយចូលលុកលុយសម្លាប់ជនជាតិខ្មែរ និងបំផ្លេចបំផ្លាញខ្ទេចខ្ទីស្ទើរអស់រលីង នាអំឡុងពីឆ្នាំ ១៩៧០នោះ ?

បន្ទាប់មកអតីតប្រមុខរដ្ឋនៃចលនាសង្គមរាស្ត្រនិយមបានឡើងធ្វើជាប្រធានាធិបតីលើ

( **តទៅទំព័រទី២០** )

# លះបង់ជីវិត ដើម្បីភាសាខ្មែរ រស់ឡើងវិញ នៅខេត្តសុរិន្ទ

***ខេត្តសុរិន្ទ, ប្រទេសសៀម : មាជ សុវណ្ណារ៉ា***

•••ថ្ងៃមួយពេលបុរសម្នាក់អាយុជាង៤០ឆ្នាំ ទុកពុកមាត់វែងជុំវិញរង្វង់ក្រអូមមាត់ ដែលចេះភាសាខ្មែរច្បាស់ កំពុងតែបង្រៀនសិស្សក្មេងៗជាង១០០នាក់ ជាកូនពួកខ្មែរសុរិន្ទសញ្ជាតិថៃនោះ ស្រាប់តែមានក្រុមកងទ័ពសៀមបានចូលទៅសួរ និងគំរាមកំហែងក្នុងបំណងមិនចង់ឱ្យរូបគាត់បង្រៀនភាសាខ្មែរ ខណៈដែលខ្មែរយើងទាំងអស់គ្មានមានការអាម៉ាស់ ព្រោះថានៅខេត្តសុរិន្ទត្រូវបានហាមមិនឱ្យរៀនភាសាខ្មែរអស់រយៈពេល៥០ឆ្នាំកន្លងមកហើយ ។

កំពុងតែបង្រៀនសិស្សនៅក្នុងបរិវេណប្រាសាទភូមិពោន មិនឆ្ងាយពីជំរុំភ្នំដងរែក ដែលថាតំបន់អតីតកាលមួយនៃជនភៀសខ្លួនខ្មែរ ត្រូវសៀមដឹកឡានយកទៅចាក់ចោលរាប់ពាន់គ្រួសារ ស្លាប់ដោយវេទនា ព្រោះតែជាន់មីន និងដាច់បាយក្រហាយទឹក ក្នុងអំឡុងឆ្នាំ១៩៧៩ ជ័យមង្គល បានឆ្លើយតបទៅក្រុមកងទ័ពថៃវិញថា នេះជាសិទ្ធិសេរីភាពដែលប្រទេសរបស់អ្នក (ប្រទេសថៃ) បានចុះសន្ធិសញ្ញាជាមួយអង្គការសហប្រជាជាតិ (UN) ដើម្បីរក្សានូវវប្បធម៌អក្សរសាស្ត្ររបស់ជនជាតិភាគតិច ។ ដូច្នេះអ្នកគ្មានសិទ្ធិឃាត់ឃាំងចំពោះពួកយើងឡើយ ។

ក្នុងទិដ្ឋភាពដែលយើងបានឃើញ ជ័យ មង្គល មានសញ្ជាតិជាថៃ តែរូបលោកមិនភ្លេចនិយាយភាសាខ្មែរម្តងណានោះទេ លោកថា បេះដូងរបស់លោកគឺជាខ្មែរ រហូតដល់ទីអវសាន្តនៃជីវិត ដោយលោកនិយាយទៅកាន់កូនសិស្សជាខ្មែរ ទៅកាន់អ្នកលក់ដូរ ឬសរសេរឃីហោ និងទៅកាន់អ្នកដទៃទៀតជាភាសាខ្មែរ នៃកំណើតជាអំបូរខ្មែរ



លោក ជ័យ មង្គល



លោក ឈុម ចំនួតារា ស្ថាបនិកម្នាក់



លោក ជ័យ មង្គល កំពុងបង្រៀនសិស្ស

សុរិន្ទ ។ រហូតដល់ថ្ងៃមួយលោកបានធ្វើដំណើរទៅកាន់ខេត្តស៊ីសាកេត ជាប់ព្រំប្រទល់ខេត្តសុរិន្ទ ដែលមានខ្មែររស់នៅដែរនោះ ជ័យ មង្គល បានសាកសួរទៅកាន់លោកគ្រូ-អ្នកគ្រូនៅខេត្តមួយនេះ អំពីការសិក្សាភាសាខ្មែរ ត្រូវពួកគេសើចចំអកឱ្យ ព្រោះពួកគេយល់ថា ឪពុកម្តាយបានសាបព្រោះភាសាថៃនៅតាមផ្ទះ ដែលគេយល់ថា ការនិយាយភាសាខ្មែរមានតម្លៃតិចតួចណាស់សំរាប់អនាគតពួកគេ ។

លោកគ្រូ ជ័យ មង្គល និយាយយ៉ាងអស់សង្ឃឹមបន្តថា បច្ចុប្បន្ននៅក្នុងផ្នែកអប់រំ និងការសិក្សាភាសាខ្មែរក្នុងខេត្តសុរិន្ទនោះ យើងប្រឈមមុខសំរាប់ជីវិតរស់នៅឱ្យបានប្រសើរ គេត្រូវតែបំភ្លេចដើមកំណើតរបស់គេបន្តិចម្តងៗ ដើម្បីស្វែងរកការងារចិញ្ចឹមជីវិត ។

លោក មង្គល បន្តថា រឿងមួយទៀត ពួកយុវជន-យុវនារីខ្មែរសុរិន្ទបានបោះបង់ភាសាកំណើតរបស់ខ្លួនជាអំបូរភាសាខ្មែរសុរិន្ទ គឺដោយសារគេមើលឃើញប្រទេសថៃមានសេដ្ឋកិច្ច និងនយោបាយខ្លាំងជាងប្រទេសកម្ពុជា, ហើយអ្នកខ្លះទៀតបានយល់ថា ខ្មែរយើងជាមនុស្សកាចសាហាវជាងជនជាតិថៃទៅទៀត ដែលធ្វើឱ្យគេមិនចង់តាំងខ្លួនជាខ្មែរសុរិន្ទនោះ ។ ខណៈដែលឪពុកម្តាយរបស់គេពុំទាន់យកពេលពន្យល់ ឬបង្ហាញនូវប្រវត្តិសាស្ត្រខ្មែរ-សៀម ដើម្បីឱ្យគេយល់ច្បាស់នោះថា ទឹកដីដែលជាកំណើតរបស់គេកើតជាលើទឹកដីសៀម ឬរបស់ខ្មែរ ? ដែលនេះជាកត្តាចាំបាច់ត្រូវឪពុកម្តាយបង្ហាញឱ្យច្បាស់ ដើម្បីផ្ចិតមនោសញ្ចេតនា និងការស្រឡាញ់របស់ពួកគេ ចំពោះឈាមជ័រជាខ្មែរ ។

•យើងអាចមើលឃើញថា នៅទីនោះ (ទឹកដីសុរិន្ទ) ការខ្វះខាតសំភារៈរបស់ខ្មែរ ដូចជាផ្នែកទំនើបនិយមជាភាសាខ្មែរ មានចំរៀង, ភាពយន្តក៏អាចបណ្តាលឱ្យយុវជន-យុវនារីយើងងាយស្រួលនឹងភ្លេចភាសាដើមកំណើតរបស់ខ្លួនផងដែរ ។

លោក ជ័យ មង្គល បានប្រាប់ទៅដល់រាជរដ្ឋាភិបាលកម្ពុជាអំពីការបាត់បង់ភាសាខ្មែរនៅខេត្តសុរិន្ទ ពិសេសពួកក្មេងៗជំនាន់ក្រោយកំពុងតែមានដំណើរធ្លាក់ចុះជាលំដាប់ក្នុងការយល់ដឹងអំពីវប្បធម៌ខ្មែរ និងភាសាអក្សរសាស្ត្រខ្មែរនោះ ។ ប៉ុន្តែគេមិនទាន់ឃើញមានប្រតិកម្មណាឆ្លើយតបវិញ ពីរដ្ឋាភិបាលលោក ហ៊ុន សែន នៅឡើយទេដែរ ។

ជាដើមកំណើតជាខ្មែររស់នៅតាមព្រំដែនសីមានៃប្រទេសថៃ ដែលធ្លាប់ជាអាណាចក្រនៃចក្រភពអង្គរបុរី ប្រទេសខ្មែរ ជ័យ មង្គល បានបង្កើតសាលារៀនភាសាខ្មែរចំនួន៤ ក្នុងរយៈពេល២ឆ្នាំមកនេះ គឺក្នុងន័យដើម្បីខិតខំរក្សា និងលើកស្ទួយវប្បធម៌, អក្សរសាស្ត្រ-ភាសាខ្មែរយើងដែលមាននៅទីនោះ មិនចង់ឱ្យបាត់បង់

( **តទៅទំព័រទី១៦** )

# ៣៣ឆ្នាំការវិលត្រឡប់ របបសាធារណៈរដ្ឋខ្មែរ អាចកើតមានឬ ?

***ភ្នំពេញ : គីម សារឿន, មាជ សុវណ្ណារ៉ា***

ចាប់តាំងពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ របបសាធារណៈរដ្ឋខ្មែរ ដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ បានដួលរលំទាំងស្រុង ហើយលោកក៏បាននាំក្រុមគ្រួសាររត់ភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិក ។ ប៉ុន្តែរយៈពេល៣៣ឆ្នាំក្រោយមក កូនប្រុសរបស់លោកសេនាប្រមុខ លន់ នល់ ក៏បានប្រកាសបើកគណបក្សនយោបាយឈ្មោះ "គណបក្សខ្មែរសាធារណៈរដ្ឋ" ដើម្បីប្រកួតប្រជែងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នៅថ្ងៃទី២៧ កក្កដា ឆ្នាំ២០០៨ ក្នុងប្រទេសកម្ពុជា ។


លន់ ឫទ្ធិ


សម្តេច សីហនុ

នៅពេលមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាលើកដំបូងលើទឹកដីកំណើតនោះ លោក លន់ ឫទ្ធិ ដែលជាកូនប្រុសលោក លន់ នល់ បានធ្វើសន្និសីទក្នុងបន្ទប់វីអាភីថា លោកអន្ទះអន្ទែងចង់មកលេងស្រុកកំណើត និងចង់ជួបជុំបងប្អូនទាំងអស់គ្នា ។

លោក លន់ ឫទ្ធិ បានឱ្យដឹងថា ចាប់តាំងពីឆ្នាំ១៩៧៥មក ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងរបបកុម្មុយនិស្តគួរឱ្យភ័យខ្លាចខ្លាំងណាស់ ។ កាលខ្ញុំទើបតែមានអាយុ១១ឆ្នាំ បានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិកជាមួយក្រុមគ្រួសារ ជានិច្ចកាលខ្ញុំមានអារម្មណ៍នឹកស្រុកកំណើត និងសាច់ញាតិខ្លាំងណាស់ ។ ម្យ៉ាងទៀតមុនពេលឪពុកខ្ញុំស្លាប់ទៅបានផ្តែផ្តាំឱ្យចេះស្រឡាញ់ជាតិមាតុភូមិ ទោះបីរស់នៅទីណាក៏ដោយ ។

លោកបានឱ្យដឹងថា ខ្ញុំចង់មកប្រទេសកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ ចង់ផ្តល់នូវចំណេះដឹងនានាដែលលោកទទួលបានពីសហរដ្ឋអាមេរិក ។ ដូច្នេះហើយទើបរូបលោកផ្តួចផ្តើមបង្កើតគណបក្សឡើង ដោយដាក់ឈ្មោះដូចសម័យកាលឪពុកលោកដឹកនាំតែម្តង ។

ជាមួយគ្នានោះដែរ លោក លន់ ឫទ្ធិ ក៏បានរំលឹកពីអតីតកាលរបស់ឪពុកលោក និងក្រុមគ្រួសារមុនពេលចាកចេញទៅរស់នៅសហរដ្ឋអាមេរិកទាំងបង្ខំចិត្តនៅឆ្នាំ១៩៧៥ ។

បន្ទាប់ពីដួលរលំនៃរបបសាធារណៈរដ្ឋខ្មែររួចមក ប្រទេសជាតិធ្លាក់ក្នុងរបបកុម្មុយនិស្ត ហើយអំពើឃោរឃៅកាប់សំលាប់មកលើប្រជាជនគ្មានញញើតដៃពីសំណាក់ជនផ្តាច់ការទាំងនោះ ។ កាលណោះឪពុកលោកបានប្រឹងប្រែងតស៊ូសង្គ្រោះប្រទេសជាតិឱ្យរួចផុតពីការយាយី ប៉ុន្តែក្រោយមកត្រូវបរាជ័យ ។

លោក លន់ ឫទ្ធិ បានបញ្ជាក់ថា អ្វីដែលឪពុកលោកបានធ្វើវាមិនទាន់ចប់នោះទេ ហើយលោកត្រូវតែបន្តវេណដឹកនាំប្រជាជន ដើម្បីសិទ្ធិសេរីភាព ការគោរពច្បាប់កសាងប្រទេសជាតិឡើងវិញ ជួយជំរុញសេដ្ឋកិច្ចជាតិប្រជាជនឱ្យកាន់តែប្រសើរដូចអារ្យប្រទេស ។

លោក លន់ ឫទ្ធិ បានអះអាងថា លោកនឹងដឹកនាំប្រទេសជាតិឱ្យមានការរីកចំរើន តាមលំអានឪពុកលោក ។ ប៉ុន្តែការអះអាងនេះ ត្រូវបានប្រវត្តិសាស្ត្រចារឹកថា លោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទំលាក់សម្តេចនរោត្តម ស៊ីហនុ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ខណៈពេលដែលព្រះអង្គយាងបំពេញព្រះរាជទស្សនកិច្ចជាផ្លូវការនៅសហភាពសូវៀត ។

ទង្វើរបស់លោក លន់ នល់ នេះ ត្រូវបានអ្នកនយោបាយ និងប្រជាពលរដ្ឋស្តីបន្ទោសថា ដឹកនាំប្រទេសជាតិធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិ ។ ជាពិសេសបានធ្វើឱ្យរបបខ្មែរក្រហមចូលកាន់កាប់អំណាចសំលាប់ប្រជាពលរដ្ឋរាប់លាននាក់ ( ឆ្នាំ១៩៧៥- ១៩៧៩) ។ អតីតរដ្ឋមន្ត្រីឃោសនាការក្នុងរបបសាធារណរដ្ឋខ្មែរ លោក ឆាំង សុង ដែលជាមនុស្សជំនិតបំផុតរបស់លោកប្រធានាធិបតី លន់ នល់ ផងនោះ បានអះអាងថា គេត្រូវចែកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរពីរឱ្យដាច់ចេញពីគ្នាយ៉ាងស្រឡះ ។ **ទី១.** គឺព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលគេតែងនាំគ្នាហៅជាញឹកញាប់ថា ជា "រដ្ឋប្រហារ" **ទី២.** គឺការប្រកាសសាធារណរដ្ឋខ្មែរ ដែលធ្វើឡើងនៅថ្ងៃទី០៩ តុលា ឆ្នាំ ១៩៧១ ។ ខ្ញុំនៅចាំបានថា : ការទាំងពីរនេះបានធ្វើឡើងនៅចំពោះមុខគ្រោះថ្នាក់ដ៏ធំក្រៃលែងនៃចម្បាំង ដោយគេបានផ្ទៀងផ្ទាត់នីតិវិធី (Legalité) និងពិនិត្យឆន្ទៈរបស់ពលរដ្ឋ (Légitimité) យ៉ាងល្អិតល្អន់ណាស់ មិនមែនជា "រដ្ឋប្រហារ" ធ្វើតាមអំពើចិត្តអ្នកកាន់អំណាចនោះទេ ។

ជាអ្នកនាំពាក្យក្នុងរដ្ឋាភិបាលសម័យនោះ លោក ឆាំង សុង និយាយបន្តថា ទូទៅគេតែងច្រឡំព្រឹត្តិការណ៍ ១៨ មីនា ដែលជាថ្ងៃសភាខ្មែរបោះឆ្នោតដកសម្តេច សីហនុ ចេញពីដំណែងរបស់ព្រះអង្គជាប្រមុខរដ្ឋ ជាមួយការប្រកាសសាធារណរដ្ឋខ្មែរ និងការបោះឆ្នោតដែលជ្រើសរើសឧត្តមសេនីយ៍ លន់ នល់ អតីតនាយករដ្ឋមន្ត្រីរបស់សម្តេច សីហនុ ឱ្យកាន់តំណែងជាប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ។ គួរបញ្ជាក់ខ្លះដែរថា តំណែងប្រមុខរដ្ឋ ដើមឡើយឥតមាននៅក្នុងរដ្ឋធម្មនុញ្ញខ្មែរសម័យនោះទេ ជាតំណែងថ្មីដែលសភាខ្មែរបានតុបតែងថ្វាយសម្តេច សីហនុ ដោយបន្ថែមមាត្រាថ្មីមួយទៀតនៅក្នុងរដ្ឋធម្មនុញ្ញ ក្រោយពេលព្រះវរបិតារបស់ព្រះអង្គ គឺសម្តេចនរោត្តមសុរាម្រិត

( តទៅទំព័រទី១៩ )

# ច្រានចោលសំដី សម រង្ស៊ី ចោទថា ចំណាប់ខ្មាំង ហ៊ុន សែន

***ឡុងប៊ិច : មាជ សុវណ្ណារ៉ា***

●●●អគ្គលេខាធិការគណបក្សសិទ្ធិមនុស្សលោក អ៊ូ ច័ន្ទរ័ត្ន បានច្រានចោលដោយប្រតិកម្មសំដី សម រង្ស៊ី ដែលបានចោទថា គណបក្សសិទ្ធិមនុស្សជាចំណាប់ខ្មាំង ហ៊ុន សែន ថា កំពុងបំភ្លើសមូលបង្កាច់ ដែលទទួលយកមិនបាន ។

លោក សម រង្ស៊ី បានថ្លែងយ៉ាងដូច្នេះ នៅក្នុងការជួបជាមួយអ្នកគាំទ្រគណបក្សរបស់លោកនៅទីក្រុងឡុងប៊ិច កាលពីចុងខែមេសាកន្លងទៅនេះថា គណបក្សសិទ្ធិមនុស្សដែលទើបបង្កើតថ្មីបានមិនដល់មួយឆ្នាំ គឺជាគណបក្សមានពាក់ព័ន្ធអំពើពុករលួយ ដែលថ្នាក់ដឹកនាំមានរឿងអាស្រូវកាលពីនៅគ្រប់គ្រងអង្គការមួយ ។ ដូច្នេះវាជាការងាយស្រួលឱ្យ ហ៊ុន សែន ចាប់កំហុសដោយប្រើ


ហ៊ុន សែន


សម រង្ស៊ី

ប្រព័ន្ធតុលាការក្នុងការចាត់វិធានការណ៍ ប្រសិនបើគណបក្សមួយនេះ ហ៊ានប្រឆាំង ហ៊ុន សែន ដែលបញ្ហានេះយើងឃើញថា គណបក្សសិទ្ធិមនុស្សជាចំណុចខ្សោយនៃចំណាប់ខ្មាំង ហ៊ុន សែន ។

លោក កឹម សុខា កាលពីនៅជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សត្រូវរងការចោទប្រកាន់ពីបុគ្គលិករបស់ខ្លួនចំនួន១៦នាក់ ពីការពាក់ព័ន្ធនឹងអំពើពុករលួយនៅក្នុងអង្គការមួយនេះ ដែលប្រើប្រាស់ថវិកាមិនប្រក្រតី ។ ប៉ុន្តែញ្ហានេះ ត្រូវបានលោក កឹម សុខា អះអាងថា បញ្ហាត្រូវបានបញ្ចប់ហើយ ព្រោះម្ចាស់ផ្តល់ជំនួយគេបានស៊ើបអង្កេតពីការចាយវាយពិតជាត្រឹមត្រូវតាមគោលការណ៍ដែលគ្មានទោសកំហុសអ្វីទេ ។

អគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស លោក អ៊ូ ច័ន្ទរ័ត្ន ថ្លែងថា យើងមិនខ្លាចប្រឆាំងតទល់ជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តាមគោលការណ៍លទ្ធិប្រជាធិបតេយ្យទេ ក្នុងការប្រកួតប្រជែងការបោះឆ្នោត ព្រោះគ្មានហេតុផល ឬចំណុចខ្សោយណាធ្វើជាចំណាប់ខ្មាំង ហ៊ុន សែន ដូចការអះអាងរបស់លោក សម រង្ស៊ី ចោទប្រកាន់នោះទេ ។ គណបក្សសិទ្ធិមនុស្សមានគោលការណ៍នយោបាយច្បាស់លាស់ជាមួយមនុស្សស្អាតស្អំមិនថា កឹម សុខា, ប៉ែន សុវណ្ណ, កែវ រ៉េមី និងលោក សឺន ស៊ូប៊ែរ៍ ដែលត្រូវធ្វើនយោបាយតទល់ជាមួយ ហ៊ុន សែន ។

ទាក់ទិនទៅនឹងការបង្រួបបង្រួមអ្នកលទ្ធិប្រជាធិបតេយ្យ លោក សម រង្ស៊ី បាននិយាយថា បើអ្នកប្រជាធិបតេយ្យមែនហើយចង់ឈ្នះ ហ៊ុន សែន គេត្រូវរួបរួមជាមួយគណបក្សណា ដែលខ្លាំងដូចគណបក្ស សម រង្ស៊ី មានមូលដ្ឋានគ្រឹះ១២ឆ្នាំទៅហើយ គួរតែគណបក្សតូចតាច ទើបបង្កើតថ្មីប្រហែលមួយឆ្នាំ មកចូលរួមមិនមែនឱ្យគណបក្ស សម រង្ស៊ី ទៅចូលរួមជាមួយខ្លួននោះទេ ដោយលោក សម រង្ស៊ី អះអាងថា វាមិនទំនងរុះរើផ្ទះថ្មរឹងមាំរួចមកហើយទៅចូលជាមួយខ្ទមទៅវិញ ។ លោក សម រង្ស៊ី ចំអកថា គណបក្សសិទ្ធិមនុស្សមិនអាចយកឈ្នះគណបក្សប្រជាជនកម្ពុជាបានទេ ព្រោះគណបក្សប្រជាជនកម្ពុជា គេមានកម្លាំងប្រដាប់អាវុធមានយួននៅពីក្រោយមានលុយ រីឯគណបក្សមួយនេះអត់លុយ អត់មានគ្រឹះនៅមូលដ្ឋាន តើមានសង្ឃឹមអ្វីនឹងឈ្នះ ។

លោក អ៊ូ ច័ន្ទរ័ត្ន បានប្រតិកម្មថា ឈ្នះឬចាញ់មិនប្រាកដថា មកពីគណបក្សថ្មី ឬចាស់នោះទេ គឺវាស្ថិតនៅលើគោលការណ៍នយោបាយគណបក្សច្បាស់លាស់ និងសមត្ថភាពអ្នកដឹកនាំជាមួយការបែងចែកអំណាច និងភារកិច្ចទទួលខុសត្រូវដោយអំណាចមិនត្រូវស្ថិតនៅលើមនុស្សម្នាក់នោះទេ ដោយប្រធានត្រូវមានអាណត្តិគណបក្សមិនត្រូវដាក់ឈ្មោះខ្លួនឯងធ្វើជាម្ចាស់កម្មសិទ្ធិនោះទេ ។

លោក អ៊ូ ច័ន្ទរ័ត្ន បន្តថា យើងចង់ណាស់បង្រួបបង្រួមអ្នកប្រជាធិបតេយ្យ ប៉ុន្តែគណបក្ស សម រង្ស៊ី គាត់ហាក់បង្ហាញមោទនភាពខ្លាំងពេក ដែលពិបាកចូលគ្នាបាន ព្រោះការដាក់លក្ខខណ្ឌធ្វើឱ្យយើងមិនត្រូវគ្នាចំពោះគោលការណ៍នយោបាយ ដែលត្រូវរៀបចំក្នុងការរួបរួមនោះ ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មកដល់ពេលនេះ អ្វីៗត្រូវហួសពេលទៅហើយ សំរាប់ក្រុមអ្នកប្រជាធិបតេយ្យចង់រកការរួបរួមគ្នានោះ ព្រោះបញ្ជីទទួលចុះឈ្មោះគណបក្សនយោបាយត្រូវបានបញ្ចប់ឈប់ទទួល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅហើយ កាលពីចុងខែមេសា កន្លងទៅនេះ ។

ប្រទេសកម្ពុជាឈានទៅរកការបោះឆ្នោត នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ដោយមាន គណបក្សនយោបាយជាង៥០ បានចូលរួមប្រកួតប្រជែងគ្នា ក្នុងការដណ្តើមអាសនៈសភាជាតិ និងនាយករដ្ឋមន្ត្រីអាណត្តិទី៤ ៕

# ប្រេងនិងឧស្ម័នក្នុងដែនសមុទ្រកម្ពុជា នឹងឱ្យផលនៅឆ្នាំ២០១១

***ភ្នំពេញ : គីម សារឿន***

ក្នុងដែនសមុទ្រកម្ពុជា មិនត្រឹមតែហុចផលផ្នែកត្រីសាច់ដ៏សំបូរបែបប៉ុណ្ណោះទេ តែត្រូវបានអ្នកសិក្សាស្រាវជ្រាវរកឃើញថា នៅបាតសមុទ្រ



សុខ អាន



លោក សុន ឆៃ

មានប្រេងប្រមាណ២កោដិធុង និងឧស្ម័នធម្មជាតិ១០.០០០កោដិហ្វីតគីប ។

កំណប់មហាសាលនេះនឹងហុចផលឱ្យប្រទេសកម្ពុជានៅឆ្នាំ២០១១ ដែលក្នុង១ឆ្នាំអាចទទួលបានប្រាក់ប្រមាណ១.៧០០លានដុល្លារ ធ្វើឱ្យប្រជាជនអាចចៀសផុតពីភាពទីទាល់ក្រក្តុង




ជីវភាពរស់នៅប្រចាំថ្ងៃបានដោយងាយស្រួល ។

ជាមួយគ្នានេះដែរ គណបក្សប្រឆាំង មន្ត្រីអង្គការសង្គមស៊ីវិលក៏បានសម្តែងនូវការព្រួយបារម្ភចំពោះអាជ្ញាធរ និងមន្ត្រីមានសមត្ថកិច្ចប្រព្រឹត្តិអំពើពុករលួយ បង្កឱ្យប្រទេសជាតិធ្លាក់ក្នុងគ្រោះមហន្តរាយដូចប្រទេសនីហ្សេរីយ៉ាទៀត ។

ចាប់តាំងពីក្រុមហ៊ុនឈីវរ៉ុនរបស់អាមេរិកប្រកាសថា ក្នុងដែនសមុទ្រកម្ពុជាមានធនធានធម្មជាតិប្រេង និងឧស្ម័នរួចមក រដ្ឋាភិបាលក៏បានផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនចំនួន១៣ មកពីប្រទេសចិន ជប៉ុន សិង្ហបុរី ស៊ុយអ៊ែត គុយវ៉ែតកូរ៉េខាងត្បូង និងប្រទេសមួយចំនួនទៀត ក្នុងពិភពលោកដែលចង់មករកស៊ីនៅកម្ពុជា ។

យោងតាមការសិក្សាស្រាវជ្រាវរបស់អង្គការយូអិនឌីភី ធនាគារពិភពលោក និងស្ថាប័នមួយចំនួនទៀត បានធ្វើការអះអាងប្រហាក់ប្រហែលគ្នាថា ក្នុងដែនសមុទ្រកម្ពុជាអាចមានប្រេង ២.០០០លានធុង និងឧស្ម័នធម្មជាតិ១០.០០០កោដិហ្វីតគីប ។ ចំពោះបញ្ហានេះខាងរដ្ឋាភិបាលមិនទាន់អះអាងឱ្យប្រាកដនោះទេ ប៉ុន្តែបញ្ជាក់ថា ប្រាកដជាមានប្រេង និងឧស្ម័នមែន

ក្នុងប្លុក A ចំងាយប្រមាណ២០០គីឡូម៉ែត្រ ពីក្រុងព្រះសីហនុ ក្បែរព្រំដែនសមុទ្រសៀម ។

លោក តែ ដួងតារា អគ្គនាយកនៃអាជ្ញាធរជាតិប្រេងកាតកម្ពុជាបានថ្លែងក្នុងសន្និសីទកាលពីខែមីនា កន្លងមកនេះថា ការធ្វើអាជីវកម្មប្រេង និងឧស្ម័នអាចជួយឱ្យប្រជាពលរដ្ឋខ្មែរចាកផុតពីភាពក្រីក្រ ។ ចំពោះបញ្ហាតំលៃមិនអាចជាតំលៃឯកោនោះទេ ។

លោក តែ ដួងតារា បន្តថា កម្ពុជាអាច នឹងចាប់ផ្តើមរុករកប្រេងនៅប្លុក A ក្នុងឆ្នាំ ២០១១ ហើយដៃគូក្នុងការស្វែងរកធនធានធម្មជាតិនេះគឺធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី ម្ចាស់ជំនួយអន្តរជាតិមួយចំនួនទៀត មកពីអាស៊ី និងអឺរ៉ុប ។

បន្ទាប់ពីទទួលព័ត៌មានថា ដែនសមុទ្រកម្ពុជាមានប្រេង និងឧស្ម័ននោះបណ្តាក្រុមហ៊ុនជាច្រើនក៏បានសំរុកមកប្រទេសកម្ពុជា ដែលគ្រោងនឹងធ្វើអាជីវកម្មនៅអំឡុងឆ្នាំ២០១១នេះដែរ ។ នៅប្លុក A ក្រុមហ៊ុន សិង្ហបុរី និង ម៉ាឡេស៊ី ។ ប្លុក B ហុងកុង និងម៉ាកាវ ។ ប្លុក C ក្រុមហ៊ុនចិន ។ ប្លុក D ក្រុមហ៊ុនឥណ្ឌូនេស៊ី និងប្លុក E ក្រុមហ៊ុនប្រទេសគុយវ៉ែត ។

លោក សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រេងប្រេងកាតកម្ពុជាបានថ្លែង ក្នុងសន្និសីទថា ការរុករកឃើញប្រេងកាត និងឧស្ម័នជាជំហានដ៏ធំមួយក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិកាត់បន្ថយភាពក្រីក្រ ។

លោក សុខ អាន បានបន្តថា ប្រាក់ចំណូលដែលបានមកពីប្រេង និងឧស្ម័ននេះ នឹងជួយឱ្យកម្ពុជាកាន់តែប្រសើរ ពីព្រោះសព្វថ្ងៃយើង

( តទៅទំព័រទី០៧ )

# អត្ថប្រយោជន៍នៃផ្លែម្ទេស







●●●ប្រភេទបន្លែផ្សំដែលបំភ្លេចមិនបានមិនឱ្យខ្វះបានម្ទេស មានរស់ជាតិហឹរ ធ្វើឱ្យអាហារឆ្ងាញ់បំបាត់ក្លិនឆ្អាប និងអាចការពារជំងឺមហារីកបាន ព្រោះវាមានបេតាការ៉ូទីន ។ ចំណែកឯកគ្រួយម្ទេសវិញ ប្រសិនបើយកមកប្រឡាក់ម្សៅ ហើយបំពងខ្លាញ់ ធ្វើជាអន្លក់ទឹកគ្រឿងវិញ កាន់តែប្រសើរ ។ ស្លឹកម្ទេសមានរស់ជាតិបេតាការ៉ូទីនខ្ពស់ និងនៅមានកាល់ស្យូមហ្វូសហ័រីសដែក និងវីតាមីនសេទៀតផង ។

ចំណុចអាក្រកក្នុងការទទួលទាន់ម្ទេសច្រើនពេក គឺប្រព័ន្ធរំលាយអាហារ និងការបឺតស្រូបយកសារធាតុអាហារក្នុងរាងាកាយលែងដំណើរការល្អ ។ តែប្រសិន បើយើងទទួលទានក្នុងកំរិតសមល្មមនឹងជួយធ្វើឱ្យឈាមមិនឆាប់កក់ជាដុំ ធ្វើឱ្យឈាមរត់បានល្អ ៕



Get Connect...Stay inform.

....Subscribe to the Khmer Post!

Please send me 1 year subscription of the Khmer Post newspaper 24 issues for $60.00

Name:________________

Address: ________________

Payment method:

Money order Check Bill me

Please send your payment to US-Asia Media Group.
5730 Rising Sun Ave. Philadelphia, Pa 19120

# បុណ្យវិសាខបូជារំលឹកដល់ថ្ងៃមង្គលទាំង៣របស់ព្រះសម្មាសម្ពុទ្ធ

***ភ្នំពេញ : ម៉ី សម្ផស្ស***

•••ពុទ្ធសាសនិកខ្មែរភាគច្រើនមានជំនឿចំពោះទស្សនៈកម្មផលធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់ ប្រៀបដូចស្រមោលអន្ទោលតាមប្រាណ ជឿថា មានឋានលើ ឋានកណ្តាល និងឋានក្រោម ហើយអ្នកដែលបានទៅកើតឋានណាមួយវា អាស្រ័យលើកុសលផលបុណ្យពីអតីតជាតិ ។



ពិធីបុណ្យវិសាខបូជា

ពុទ្ធបរិស័ទទាំងអស់សុទ្ធតែប្រាថ្នាឱ្យពេលបច្ចុប្បន្នជាតិ និងអនាគតជាតិបានរស់នៅសុខស្រួល មានយសស័ក្តិខ្ពង់ខ្ពស់ទ្រព្យសម្បត្តិស្តុកស្តម្ភ ដោយបានស្រុះស្រួលគ្នាធ្វើបុណ្យទាន ក្នុងនោះមានបុណ្យចូលឆ្នាំ បុណ្យភ្ជុំ វិសាខបូជា មាឃបូជា... ។

ចំណែកបុណ្យវិសាខបូជា ត្រូវបានគេប្រារព្ធធ្វើនៅថ្ងៃទី១៥កើត ខែពិសាខ ដើម្បីរំលឹកដល់ព្រះពុទ្ធបរមគ្រូនៃយើង គឺថ្ងៃខែដែលព្រះអង្គទ្រង់ប្រសូតត្រាស់ដឹង និងចូលព្រះនិព្វាន ។

បុណ្យវិសាខបូជា គឺជាថ្ងៃបុណ្យសាសនាដ៏ធំមួយក្នុងចំណោមបុណ្យនានា ដែលពុទ្ធសាសនិកអ្នកកាន់ព្រះពុទ្ធសាសនានៅលើពិភពលោកតែងតែប្រារព្ធធ្វើជារៀងរាល់ឆ្នាំតាំងពីយូរលង់ណាស់មក ហើយ ដោយបានជះឥទ្ធិពលរហូតមកដល់សព្វថ្ងៃ ដែលព្រះពុទ្ធទ្រង់ប្រសូតត្រាស់ដឹង និងចូលព្រះនិព្វាននៅថ្ងៃទី១៥កើត ខែពិសាខ ដោយខុសគ្នាតែឆ្នាំប៉ុណ្ណោះ ។

ទាក់ទិននឹងបញ្ហានេះ តាមអរិយធម៌របស់អ្នកស្រី ត្រឹង ងា បញ្ជាក់ថា ថ្ងៃមង្គលទាំង៣រួមមាន :

***១-ថ្ងៃកំណើត :*** ព្រះពុទ្ធទ្រង់ប្រសូតនៅថ្ងៃ សុក្រ ១៥កើត ខែពិសាខ ឆ្នាំច ក្រោមដើមសាលព្រឹក្សក្នុងព្រៃលុម្ពិនីព្រំប្រទល់នៃនគរកបិលពស្តុ និងទេវៈទហៈ ដែលនៅពេលនេះមានហេតុភេទអស្ចារ្យណាស់ ។ ក្រោយពីប្រសូតបាន៥ថ្ងៃ មានព្រាហ្មណ៍៨នាក់ថ្វាយព្រះនាមថា "សិទ្ធាថ" មានន័យថា "អ្នកសំរេចប្រយោជន៍គ្រប់បែបយ៉ាង" ។ ក្នុងខណៈនោះ ពួកព្រាហ្មណ៍៧នាក់ថ្វាយថា "បើព្រះរាជកុមារនៅជាក្សត្រនឹងបានក្លាយជាស្តេចចក្រពត្តិ បើចេញសាងផ្នួសនឹងបានត្រាស់ដឹងជាព្រះពុទ្ធ " ។ ប៉ុន្តែព្រាហ្មណ៍ម្នាក់បានលើកម្រាមដៃមួយ ហើយទាយថា "ព្រះរាជកុមារពិតជាបានត្រាស់ដឹងជាព្រះពុទ្ធមិនខាន" ។ បិតារបស់ព្រះអង្គព្រះនាម សុទ្ធោទន៍ ជាក្សត្រសោយរាជនៅនគរកបិលពស្តុ មាតាព្រះនាង សិរិមហា មាយា ហើយព្រះនាងបានសោយទីវង្គត បន្ទាប់ពីប្រសូតព្រះសិទ្ធាថបាន៧ថ្ងៃ ។



ព្រះសក្យមុន្នីចេតីនៅឧដុង្គ

***២-ការត្រាស់ដឹង :*** ព្រះសិទ្ធាថ ព្រះអង្គទ្រង់អភិសេកជាមួយព្រះនាង ពិម្ពាយសោធរា ក្នុងព្រះជន្ម១៦ព្រះវស្សា មានបុត្រមួយព្រះអង្គ រាកុលកុមារ បន្ទាប់ពីព្រះអង្គទតឃើញទេពនិមិត្ត៤យ៉ាង គឺ មនុស្សជរា មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួសរួចមក ធ្វើឱ្យព្រះអង្គមានការនឿយហត់ ចំពោះជីវិតយ៉ាងខ្លាំង ។

ក្នុងព្រះជន្ម២៩វស្សា ព្រះអង្គបានចេញទៅសាងផ្នួស ដើម្បីសំរេចនូវសម្មាសម្ពោធិញ្ញាណ ដោយធ្វើការលះបង់រាជវង្ស ប្រពន្ធកូន ទ្រព្យសម្បត្តិមិនស្តាយស្រណោះឡើយ ។ ព្រះអង្គទ្រង់តាំងសមាធិនៅក្រោមដើមពោធិព្រឹក្ស នៅក្បែរស្ទឹងនេរញ្ជរា ហើយបានផ្ចាញ់មារឈ្នះគ្រប់ពេល ដោយព្រះអង្គត្រាស់ដឹងជាព្រះពុទ្ធ នៅថ្ងៃទី១៥កើត ពេញបូរណ៍មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម៣៥វស្សា ។

***៣-ការចូលនិព្វាន :*** ក្រោយពីចេញវស្សាទី៤៥ នៅថ្ងៃ១៥កើត ពេញបូរណ៍មី ខែមាឃ ឆ្នាំ ម្សាញ់ ព្រះពុទ្ធបានដាក់អាយុសង្ខាររបស់ព្រះអង្គ ដោយប្រាប់មារថា ព្រះអង្គនឹងចូលនិព្វាន ក្នុងរយៈពេល៣ខែទៀត ។ ពេលព្រះអង្គយាងទៅដល់នគរកុសិនារា ព្រះអង្គបានយាងចូលសាលវន្ត ហើយត្រាស់ឱ្យអានន្ទរៀបចំគ្រែថ្វាយសំរាប់ផ្ទំ ហើយមច្ឆិមរាត្រីព្រះអង្គត្រាស់ដល់ ភិក្ខុទាំងឡាយ "ឥឡូវនេះតថាគត ហៅអ្នកទាំងឡាយមកប្រាប់ថា អ្វីដែលកើតឡើង ហើយដែលមានហើយផ្សំហើយ តែងមានធម៌ភាពនឹងរលត់ទៅវិញជាធម្មតា ចូរញុំាងប្រយោជន៍ឱ្យសំរេចដោយកិរិយាមិនប្រហែស" ។ ព្រះអង្គមានពុទ្ធដីកាតែប៉ុណ្ណោះ ក៏រលត់សង្ខារ ទៅ នៅថ្ងៃទី១៥កើតពេញបូរណ៍មី ខែពិសាខ ឆ្នាំម្សាញ់ ក្នុងព្រះជន្ម៨០វស្សា ។

យោងតាមឯកសារស្រាវជ្រាវបានបញ្ជាក់ថា បុណ្យវិសាខបូជាត្រូវបានប្រជាជនឥណ្ឌា និងស្រីលង្កាប្រារព្ធធ្វើតាំងពីយូរលង់ណាស់មកហើយប្រពៃណីនេះ បានជះឥទ្ធិពលដល់បណ្តាប្រទេស ដែលកាន់ព្រះពុទ្ធសាសនា ក្នុងនោះមាន ថៃ-កម្ពុជា ... ។

ចំណែកប្រទេសកម្ពុជាយើងចាប់ផ្តើមប្រារព្ធបុណ្យវិសាខបូជា ក្នុងអំឡុងឆ្នាំ ១៩៨៥ រជ្ជកាលព្រះបាទអង្គឌួង តាមរយៈនិកាយគណៈធម្មយុត្តិ លុះចំណេរកាលក្រោយមកគណៈមហានិកាយ ក៏ប្រារព្ធពិធីនេះដែរ រហូតដល់សព្វថ្ងៃ ។

លោកព្រឹទ្ធាចារ្យ មៀច ប៉ុណ្ណ ទីប្រឹក្សាក្រុមជំនុំទំនៀមទំលាប់ខ្មែរបានឱ្យដឹងថា នៅថ្ងៃប្រារព្ធពិធីនេះ តាមវត្តអារាមទូទាំងប្រទេសមានអុជគ្រឿងប្រទីបជ្វាលាបូជាភ្លឺព្រោងព្រាត ផ្កាភ្ញី និងមនុស្សក្មេងចាស់ ប្រុសស្រីនាំគ្នាទៅជួបជុំគ្នាធ្វើបុណ្យ ដើម្បីឧទ្ទិសកុសលចំពោះបុព្វការីជន និងរំលឹកដល់ពុទ្ធប្រវត្តិ ។ នៅតាមវត្តអារាមមួយចំនួនមានពុទ្ធបរិស័ទ មន្ត្រីរាជការ និងសែរាជវង្សានុវង្សនាំគ្នាយកម្ហូបអាហារទេយ្យទានផ្សេងៗទៅប្រគេនព្រះសង្ឃ និងខ្លះទៀតចែកទានដល់ជនក្រីក្រចាស់ជរា ។

ពេលយប់ព្រះសង្ឃបានសំដែងធម៌ទេសនាស្តីពីពុទ្ធប្រវត្តិ ។ "ការប្រសូតការត្រាស់ដឹង ការចូលនិពាន្ទ" ដើម្បីឱ្យពុទ្ធបរិស័ទស្តាប់កាន់តែមានសេចក្តីជ្រះថ្លា ក្នុងការធ្វើបុណ្យទាន ។

បុណ្យវិសាខបូជា ត្រូវបានគេរៀបចំធ្វើយ៉ាងអធិកអធមមានមនុស្សចូលរួមយ៉ាងច្រើនកុះករ សូម្បីតែមន្ត្រីរាជការ ក៏គេអនុញ្ញាតឱ្យឈប់សំរាក ដើម្បីទៅធ្វើបុណ្យនេះដែរ ។ ពិធីបុណ្យនេះក្លាយជាពិធីបុណ្យសាសនាដ៏ធំមួយរបស់ពុទ្ធសាសនិកខ្មែរគ្រប់រូបតែងតែចូលរួមប្រារព្ធ ធ្វើមិនដែលខានឡើយ ៕


ANGKOR AUTO SERVICE, INC.

ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street.
Philadelphia, Pa 19141

Tel : (215) 455-7810
Fax : (215) 455-7811

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត

និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

20 Years in Business
I-Care Certified

Free estimate
We can save your
insurance deductible






Complete Auto Services
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C




បើកពីម៉ោង ៩ ព្រឹក ដល់ម៉ោង៥ល្ងាច ពីថ្ងៃ ច័ន្ទ ដល់ ថ្ងៃ សៅរ៍

# ហ៊ុន សែន ឬ ញឹក ប៊ុនឆៃ ជាអ្នករារាំង ទ្រង់ រណឫទ្ធិ មិនឱ្យចូលបោះឆ្នោត ?

*ភ្នំពេញ : គីម សារឿន*

ទ្រង់ រណឫទ្ធិ ដែលជាព្រះរាជបុត្រាដ៏ឆ្នើមរបស់ព្រះសម្តេចនរោត្តម សីហនុ ហើយធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីទី១, ប្រធានរដ្ឋសភា និងប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានការចាប់អារម្មណ៍ពីមហាជន និងអ្នកនយោបាយជាតិ និងអន្តរជាតិមួយចំនួនធំ ។

នៅពេលដែលទ្រង់ រណឫទ្ធិ មានទំនាក់ទំនងស្នេហាស្ងាត់ៗ និងជាចំហជាមួយនឹងអ្នកស្រី អុក ផល្លា អតីតស្រីរបាំរូចមក គេសង្កេតឃើញទំនាស់ផ្ទៃក្នុងគ្រួសាររបស់ទ្រង់ ហាក់ដូចជាមានការប្រេះឆាកាន់តែធ្ងន់ធ្ងរ ហើយនៅទីបំផុតទ្រង់ក៏បានដាក់ពាក្យទៅតុលាការ ដើម្បីលែងលះជាមួយម្ចាស់ក្សត្រីនរោត្តម ម៉ារីរណឫទ្ធិ ។



ញឹក ប៊ុនឆៃ

ទង្វើរបស់ទ្រង់ រណឫទ្ធិ ក្នុងរឿងស្នេហានេះ វាមិនត្រឹមតែប៉ះពាល់ដល់បញ្ហាគ្រួសារនោះទេ ប៉ុន្តែវាបានជះឥទ្ធិពលដល់គណបក្ស និងមជ្ឈដ្ឋានខាងក្រៅទៀត ។ ខណៈនោះ ហ៊ុន សែន បាននិយាយបៀតបៀនចំពោះអ្នកម្នាង អុក ផល្លា ដោយប្រៀបប្រដូចទៅនឹងកញ្ច្រោងបិសាច ដែលចេះលូកលាន់កិច្ចការប្រទេសជាតិ ។

លើសពីនេះទៀត រដ្ឋសភាជាតិបានធ្វើសេចក្តីព្រៀងច្បាប់ "ឯកប្តីភាព" ប្តីមួយប្រពន្ធមួយ គឺប្រពន្ធមិនត្រូវលួចមានសហាយស្មន់ រីឯប្តីក៏មិនត្រូវលួចមានសហាយស្មន់ដែរ ។ បើមានបញ្ហានេះកើតឡើងប្តី ឬប្រពន្ធអាចមានសិទ្ធិប្តឹងទៅតុលាការទារជំងឺចិត្តពី១លានទៅ១០លានរៀល និងជាប់គុកពី១ឆ្នាំទៅ៥ឆ្នាំ ។

ច្បាប់ឯកប្តីភាពនេះ ទោះបីអនុម័តហើយក្តី ហាក់ដូចជាមិនសូវមានការគាំទ្រប៉ុន្មានទេ ចំណែកអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ក៏បានប្រឆាំងនឹងច្បាប់នេះថា វាមិនសូវមានប្រយោជន៍ ។ ទោះជាយ៉ាងណាច្បាប់ឯកប្តីភាពនេះត្រូវបានគេមើលឃើញថា អនុម័តឡើងដើម្បីបិទផ្លូវទ្រង់ រណឫទ្ធិ ក្នុងឆាកនយោបាយផងដែរ ។

នៅពេលដែលមានរឿងចំរូងចំរាស់ផ្ទៃក្នុងគ្រួសារ សមាជិកបក្សមិនសូវចុះសំរុងនឹងគ្នា ហើយមានសំដីផ្លែផ្កាពី ហ៊ុន សែន អតីតដៃគូសម្ព័ន្ធភាពក្នុងរដ្ឋាភិបាលផងនោះ ទ្រង់ រណឫទ្ធិ ទ្រង់ខ្វាល់យ៉ាងខ្លាំង ក៏សំរេចលាឈប់ពីប្រធានរដ្ឋសភាតែម្តង ។

ការលាឈប់ពីតំណែងរដ្ឋសភារបស់ទ្រង់ រណឫទ្ធិ នេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់មន្ត្រីដែលស្និទ្ធនឹងព្រះអង្គ គឺចាប់តាំងពីថ្នាក់ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, អភិបាល, អភិបាលរងខេត្ត-ក្រុង ត្រូវគេដកចេញពីតំណែងរដ្ឋាភិបាលជាបន្តបន្ទាប់ ធ្វើឱ្យផ្ទៃក្នុងគណបក្សហ៊្វុនស៊ិនប៉ិចមានការជ្រួលច្របល់កាន់តែខ្លាំង ។

ទ្រង់ រណឫទ្ធិ ពេលលាឈប់ពីប្រធានរដ្ឋសភា មិនសូវបាននៅបំរើគណបក្ស និងប្រជាពលរដ្ឋឱ្យមានភាពកក់ក្តៅនោះទេ គឺព្រះអង្គបាននិរទេសព្រះកាយទៅរស់នៅប្រទេសម៉ាឡេស៊ីជាមួយអ្នកម្នាងឥតខាន់ស្លា អ៊ុក ផល្លា ទៅវិញ ។ ទង្វើរបស់ទ្រង់ រណឫទ្ធិ ត្រូវបានអតីតព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ សរសេរតាមវេបសាយថា "ទ្រង់ រណឫទ្ធិ លះបង់តំណែងទៅបំរើរាស្ត្រដែរ ប៉ុន្តែតែបំរើអ្នកស្រី អ៊ុក ផល្លា ម្នាក់ប៉ុណ្ណោះ" ។

*** ហ៊ុន សែន អាចនៅពីក្រោយខ្នង ញឹក ប៊ុនឆៃ :**



ទ្រង់ រណឫទ្ធិ

នៅពេលដែលទ្រង់ រណឫទ្ធិ បានចាកចេញពីប្រទេសទាំងការមិនចុះសំរុងគ្នាជាមួយ ហ៊ុន សែន នោះ ជាឱកាសល្អនៅខេត្តកំពង់ឆ្នាំង ហ៊ុន-សែន បាននិយាយជាសាធារណៈទៅកាន់ប្រជាពលរដ្ឋ មន្ត្រីរាជការ ភ្ញៀវជាតិ-អន្តរជាតិ ឱ្យ ញឹក ប៊ុនឆៃ ដោះដូរមេបក្សរបស់ខ្លួនឱ្យបានឆាប់ ។

បន្ទាប់ពីមានសារនេះ ញឹក ប៊ុនឆៃ ដែលជាមន្ត្រីស្និទ្ធនឹងទ្រង់ រណឫទ្ធិ នោះ ក៏បានរៀបចំសមាជនៅថ្ងៃទី១៨ តុលា ២០០៨ ឯទីស្នាក់ការធំគណបក្សហ៊្វុនស៊ិនប៉ិច ទំលាក់ទ្រង់ រណឫទ្ធិ ពីប្រធានគណបក្ស ហើយតែងតាំងលោក កែវ ពុទ្ធរស្មី ជាប្រធាន ។ សមាជនេះ គណបក្សហ៊្វុនស៊ិនប៉ិច បានហៅថា "កំណែទំរង់ដ៏ស៊ីជំរៅ" អ្នកដែលមិនគាំទ្រសមាជ ត្រូវគេដកចេញពីតំណែងមានលោក យូ ហុកគ្រី អនុប្រធានទី១នៃរដ្ឋសភា ។

ព្រឹត្តការណ៍នេះ ទ្រង់ រណឫទ្ធិ ហៅថា "ជាបក្សប្រហារ" យ៉ាងអយុត្តិធម៌ ដែលបង្កឡើងដោយ កែវ ពុទ្ធរស្មី, ស៊ីសុវត្ថិ ស៊ីរីរតន៍, លី ឡាយស្រេង និង ញឹក ប៊ុនឆៃ ដែលភូតកុហក់រាស្ត្រ ហើយឆក់ប្លន់យកគណបក្សហ៊្វុនស៊ិនប៉ិច ដែលអតីតព្រះមហាក្សត្រនរោត្តម សីហនុ ប្រគល់ឱ្យទ្រង់ ដើម្បីដឹកនាំ ។

ក្នុងពេលជាមួយគ្នានោះដែរ ក្រុមស្និទ្ធនឹងទ្រង់ រណឫទ្ធិ ក៏បានចាកចេញ និងធ្វើការវាយប្រហារទៅលើ ញឹក ប៊ុនឆៃ យ៉ាងធ្ងន់ធ្ងរ ចោទថា ជាមនុស្សក្បត់ និងធ្វើតាមការបង្គាប់បញ្ជារបស់ ហ៊ុន សែន ។

*** ញឹក ប៊ុនឆៃ ចេញប្តឹងទ្រង់ រណឫទ្ធិ :**

ពេលទ្រង់ រណឫទ្ធិ រស់នៅប្រទេសម៉ាឡេស៊ីនោះ ដើម្បីជាការបំបាក់ និងរាំងស្ទះលែងឱ្យវិលត្រឡប់ចូលស្រុកបាន ញឹក ប៊ុនឆៃ ធ្វើពាក្យ

( តនៅទំព័រទី១៩ )

# ហ៊ុន សែន លុបភាសា ស្តេចចោល ដូច ប៉ុល ពត ?

*ឡុងប៊ិច : សុភាឫទ្ធិ*

អតីតប្រធានរដ្ឋសភាខ្មែរ និងជាអតីតប្រធានគណបក្សហ៊្វុនស៊ិនប៉ិច គឺព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បន្ទាប់ពីបានផ្តល់នូវបទសំភាសន៍តាមរយៈវិទ្យុអាស៊ីសេរី ស្តីពីដំណើររាំងស្ទះរបស់ព្រះអង្គមិនអាចវិលចូលមាតុប្រទេសដោយសារ ហ៊ុន សែន នោះ ។ បទសំភាសន៍របស់ទ្រង់ រណឫទ្ធិ នេះធ្វើឱ្យ ហ៊ុន សែន មានប្រតិកម្មទាំងគ្រេវគ្រោធជាសារណៈនៅខេត្តក្រចេះ កាលពីចុងខែមេសា ឆ្នាំ២០០៨ យ៉ាងខ្លាំង ។

ហ៊ុន សែន បានប្រើពាក្យឱ្យសម្តេចឪ និងព្រះមហាក្សត្រឱ្យប្រដៅទ្រង់ រណឫទ្ធិ កុំឱ្យរំខានដល់គាត់ទៀត ។ សំដីរបស់ ហ៊ុន សែន នេះវាជាការប្រមាថដល់អតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រធ្ងន់ណាស់ ពីព្រោះព្រះអង្គទាំងពីរមិនបានប្រឡូកក្នុងឆាកនយោបាយទេ ។



ហ៊ុន សែន

ហ៊ុន សែន ខឹងនឹងទ្រង់ រណឫទ្ធិ បែរជារាលដាលដល់រាជវង្ស ដែលពុំបានដឹងរឿងទាល់តែសោះ ។ ជាពិសេសនោះ ហ៊ុន សែន បានបញ្ជាក់ថា "ចង់តែលុបពាក្យព្រះអង្គម្ចាស់ និងទូលបង្គំនៅក្នុងរដ្ឋសភា ព្រឹទ្ធសភា និងរដ្ឋាភិបាលទៀតទើបយុត្តិធម៌" ។

ការលើកឡើងរបស់ ហ៊ុន សែន នេះមិនមែនប្រមាថត្រឹមតែទ្រង់ រណឫទ្ធិ អ្នកអង្គម្ចាស់សែរាជ្យវង្សប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាការជាន់ឈ្លីទឹកចិត្តរបស់ប្រជាពលរដ្ឋខ្មែរ រដ្ឋធម្មនុញ្ញដែលបានចែងថា ត្រូវតែមានញាតិវង្សធ្វើនយោបាយ ដើម្បីដឹកនាំប្រទេសជាតិ ក្នុងនាមជាប្រជាពលរដ្ឋ ។

យើងដឹងហើយថា តាំងពីអតីតកាលរហូតមកសែរាជ្យានុវង្ស ជាពិសេសព្រះមហាក្សត្រនៅតែមាននាទីក្នុងការដឹកនាំជាតិមាតុភូមិ ផ្តល់ភាពកក់ក្តៅដល់ប្រជារាស្ត្រ និងជានិមិត្តរូបនៃសុខសន្តិភាព សេរីភាព ឯករាជ្យ បូរណភាពទឹកដី ។ ព្រះមហាក្សត្រជំនាន់មុន បានបន្សល់ទុកនូវកេរដំណែលយ៉ាងច្រើនសំរាប់ប្រជារាស្ត្រខ្មែរ ដូចជា ប្រាង្គប្រាសាទថ្ម ទឹកដី ភាសា អក្សរ ទំនៀមទំលាប់ ប្រពៃណី និងក្បួនច្បាប់ផ្សេងៗ សំរាប់កូនខ្មែរជំនាន់ក្រោយ ។

មរតកទាំងនេះ នៅតែចាក់ឫសយ៉ាងជ្រៅក្នុងផ្នត់គំនិតកូនខ្មែរ គឺស្តេច សែរាជ្យវង្សនៅមានគុណធម៌ និងគុណបំណាច់មិនអាចបំភ្លេចបាន ហើយចាត់ទុកជាវណ្ណៈខ្ពង់ខ្ពស់ក្នុងសង្គមទៀតផង ។ អ្វីដែល ហ៊ុន សែន ចង់បំបាត់ភាសាស្តេច ឬរាជស័ព្ទចោលនោះ វាជារឿងមួយមិនពិបាកទទួលយកបាន ពីព្រោះទាំងព្រះមហាក្សត្រ និងរាជវង្សសុទ្ធតែធ្លាប់ប្រើប្រាស់ពាក្យពេចន៍នេះតំណរពីបុព្វបុរស ។ បើបំបាត់ពាក្យពេចន៍នេះមានន័យថា ជាការធ្វើអត្តឃាតរាជ្យវង្ស និងបុព្វបុរសរបស់ខ្លួន ។

គេនៅចាំបានថា ក្នុងរបប ប៉ុល ពត អំឡុងឆ្នាំ១៩៧៥-១៩៧៩ អង្គការចាត់តាំងខ្មែរក្រហមបានធ្វើការលុបបំបាត់មិនឱ្យមានវណ្ណៈខ្ពស់នោះទេ សូម្បីតែពាក្យ ឯកឧត្តម សម្តេច ស្មីក៏គ្មានដែរ ។ ពួកខ្មែរក្រហមបានធ្វើការកំទេចហេដ្ឋារចនាសម្ព័ន្ធខ្ទេចអស់ ហើយក្នុងការរស់នៅឱ្យប្រើតែពាក្យ "មិត្ត, សមមិត្ត" ប៉ុណ្ណោះ ។

ពាក្យពេចន៍នេះ យើងស្តាប់ទៅវ៉ាវល្ងូន និងស្មើភាពគ្នាណាស់ ប៉ុន្តែទីបំផុតពួកខ្មែរក្រហមល្អតែបបូរមាត់ខាងក្រៅទេ នៅពេលយប់ចាប់មនុស្សយកទៅសំលាប់ដូចសត្វធាតុ និងយកទៅដាក់គុក វាយដំ បង្អត់អាហារ ស្លាប់អស់ជិត២លាននាក់យ៉ាងអយុត្តិធម៌ ។

ពេលនោះ ហ៊ុន សែន តែងបានអួតអាងថាខ្លួនខ្លាំងគ្មាននរណាដូចខ្លួន ហើយទំនងចង់ដើរតាមគន្លងរបស់ ប៉ុល ពត ម្តងទៀតនោះ ក៏មនុស្សទូទាំងនគរពុំព្រមដែរ ពីព្រោះសែរាជ្យវង្សក៏ជាប្រជាពលរដ្ឋធ្លាប់បានបំរើជាតិមាតុភូមិរាប់ជំនាន់មកហើយដែរ ។

ការពិតទៅពាក្យ "ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម អ្នកឧកញ៉ា សម្តេច" វាគឺគោរមងារដែលបុគ្គលនោះត្រូវបានតាមរយៈរាជរដ្ឋាភិបាលស្នើទៅព្រះមហាក្សត្រ តែងតាំងឱ្យសក្តិសមនឹងការប្រឹងរបស់បុគ្គលនោះប៉ុណ្ណោះ ។

តាមវចនានុក្រមរបស់ស្តេចសង្ឃរាជ ជួន ណាត បានបញ្ជាក់ថា ពាក្យ "ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់" គឺជាឋានន្តរសក្តិរបស់សែរាជវង្សដែលព្រះមហាក្សត្របានតែងតាំងគោរមងារឱ្យ ដោយអ្នកខ្លះជា ម៉ឺន, នាម៉ឺន, ឃុន, ហ្លួង ក្រុមហ្លួង ក្រុមព្រះ ។ល។

ឯពាក្យ ឯកឧត្តម ឬ ឧកញ៉ា ជាពាក្យសំគាល់ឋានន្តរសក្តិមន្ត្រីជាន់ខ្ពស់ សំដៅចំពោះអ្នកត្រួតត្រាមុខការក្នុងក្រសួង ឬមុខងាររបស់ខ្លួន ។

(តនៅទំព័រទី១៦)

នាទី ប្រវត្តិសាស្ត្រ

## ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយៈ ពិនសំខុន** *តពីលេខមុន*

ថ្ងៃទី២៧ វិច្ឆិកា លោក សឺង ង៉ុកថាញ់ ដែលគាំទ្រសហរដ្ឋអាមេរិក និង សឺង ង៉ុកមិញគាំទ្រយួន បានជួបចរចាគ្នា ដើម្បីចង់បានតួនាទីជាចលនាដឹកមុខ តែមិនបានសម្រេច គេយល់ព្រមត្រឹមតែ "ធានាសន្តិភាពទៅវិញទៅមក" តែប៉ុណ្ណោះ ។

**ឆ្នាំ១៩៥៣**

១១ មករា សីហនុសុំអំណាចពិសេសពីសភាជាតិ ។

១៣ មករា ផ្តើមរដ្ឋប្រហាររបស់សម្តេច វគ្គទីពីរ ដោយសម្តេច សីហនុ រំលាយសភាជាតិ ប្រកាសច្បាប់ថ្មី "ប្រទេសស្ថិតក្នុងភាពអាសន្ន" ហើយឱ្យអំណាចទាំងអស់ទៅរដ្ឋាភិបាល ដែលសីហនុខ្លួនឯងជានាយករដ្ឋមន្ត្រីសមាជិកសភាគណបក្សប្រជាធិបតេយ្យ៩រូបត្រូវបានចាប់ខ្លួនពិបទឃុបឃិតាមរយៈ វៀតមិញ និងចលនាឥស្សរៈ ។

១៦. រដ្ឋាភិបាលនរោត្តមសីហនុ (២៩.៧.១៩៥៣- ២២.១១.១៩៥៣)

.នាយរដ្ឋមន្ត្រី : នរោត្តមសីហនុ

.រដ្ឋមន្ត្រីហិរញ្ញវត្ថុ-កីឡា-យុវជននិងអប់រំមូលដ្ឋាន : ប៉ែន នុត

.ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីធម្មការ-វិចិត្រសិល្បះ-សង្គមកិច្ចនិងការងារ : អូ ឈឺន

. រដ្ឋមន្ត្រីការបរទេសជាតិ : ស៊ុម វ៉ា

. រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ : ដាញ់ សួន

. រដ្ឋមន្ត្រីយុត្តិធម៌ : តុង អួនម៉ម

. រដ្ឋមន្ត្រីអប់រំជាតិនិងសន្តិសីទ : សម សារី

. រដ្ឋលេខាធិការថវិកាៈ ប្រាក់ ប្រញ្ញើង

. ទេសរដ្ឋមន្ត្រីទទួលបន្ទុកសាធារណសុខាភិបាល : ព្រះអង្គម្ចាស់ក្សត្រីនរោត្តមប៉េងបោះយុគន្ធរ

. រដ្ឋមន្ត្រីការបរទេស : ស៊ីសុវត្ថិស៊ីរីមតៈ

. រដ្ឋមន្ត្រីសាធារណការនិងទូរគមនាគមន៍ : ញ៉ឹក ជូឡុង

.រដ្ឋមន្ត្រីមហាផ្ទៃនិងស្វ័យការពារ : ប្រាក់ សារិន

.ប្រតិភូព័តិមាន : សាមសុង ហ្វៃណង់ដេស

.អនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកកីឡា-យុវជននិងអប់រំមូលដ្ឋាន អនុរដ្ឋលេខាធិការសង្គមកិច្ច និងកាងារ : ស៊ីសុវត្ថិឥស្សារ៉ូ

២៧ កមរា បង្កើតក្រុមប្រឹក្សាជាតិ សំរាប់ពិគ្រោះ ដោយមានអតីតសមាជិកសភាខ្លះ ដែលបានរំលាយទៅនោះចូលរួម ។

៩ កុម្ភៈ ចាប់ផ្តើមសលនា ដែលមានឈ្មោះថា "រាជបូជនីយកិច្ច ដើម្បីឯករាជ្យ" ។ សីហនុបានប្រគល់ឯករាជ្យបល្ល័ង្គឱ្យព្រះបីតា ហើយចេញដំណើរស្រុកបារាំង ។ នៅស្រុកបារាំងសីហនុ បានសុំឱ្យបារាំងលុបសហគមនិស្សិតខ្មែរ ដែលដឹកនាំដោយ ហ៊ូយន់ ពីឆ្នាំ១៩៥១ មកនោះ ចោលចេញ ២៥មិនា សីហនុ ជួបជាមួយប្រធានាធិបតីបារាំង លោក វ៉ាំង សង់ អូរីយ៉ូល តែពុំអាចធ្វើឱ្យបារាំងប្រគល់ឯករាជ្យមកកម្ពុជា ពេលនោះបានទេ ។

១៣មេសា សីហនុ ចេញដំណើរពីបារាំងទៅកាណាដា សហរដ្ឋអាមេរិក ជប៉ុន ដើម្បីខិតខំរកការគាំទ្រដល់"ព្រះរាជបូទីយកិច្ច"របស់ព្រះអង្គ ១៩មេសា សីហនុ បានធ្វើបទសម្ភាសន៍ឱ្យកាសែតញ៉ូវយ៉ក ថែមដែលធ្វើឱ្យបារាំងព្រួយបារម្ភ ចំពោះដែលបារាំងកំពុងរងការវាយក្របហារ ពីយួន នៅឥណ្ឌូចិន ។

ថ្ងៃទី២៧មេសា បារាំងបានរៀបចំប្តូររចនាសម្ព័ន្ធថ្មីដំណាងរបស់បារាំងក្នុងចំណោមប្រទេសសមាជិកឥណ្ឌូចិន ។

១៤សីហនុមកដល់កម្ពុជាវិញ ចំពេលព្រះរាជបុត្រ សីហមុនីប្រសូត

១២មិថុនា សីហនុប្រកាស និរទេសខ្លួនទៅសៀមរាប ហើយទាមទារឯករាជ្យពីបារាំងពីទីនោះ ។

១៤មិថុនា សីហនុ ទៅបាងកកប្រទេសសៀម តែពុំបានត្រូវសេនាប្រមុខ ភូមិបុល សង្គ្រាមទទួលឱ្យសមឋានៈព្រះអង្គនោះទេ

២៦មិថុនា សីហនុ មកដល់បាត់ដំបង ប្រកាសហៅរករាស្ត្រឱ្យចូលរួនចលនាឯករាជ្យ មនុស្ស២ម៉ឺននាក់ចូលរួម

**ឆ្នាំ១៩៥៣**

ថ្ងៃ៣កក្កដា ប្រទេសបារាំងបានថ្លែងការណ៍ថា "ត្រៀមខ្លួនសំរាប់ផ្តលឯករាជ្យ និងបូរាណភាពទឹកដីកម្ពុជាវិញ "

ថ្ងៃទី២៩កក្កដា សម្តេច សីហនុ ចាប់ផ្តើមប្តូររដ្ឋាភិបាលថ្មីមួយទៀត ដឹកនាំដោយខ្លួន ព្រះអង្គឯង

**១៦.** រដ្ឋាភិបាលនរោត្តមសីហនុ (២៩.៧.១៩៥៣- ២២.១១.១៩៥៣)

. នាយករដ្ឋមន្ត្រី : នរោត្តម សីហនុ

.រដ្ឋមន្ត្រីហិរញ្ញវត្ថុ កីឡា យុវជន និងកីឡាអប់រំមូលដ្ឋាន : ប៉ែន នុត

.ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីធម្មការ វិចិត្រសិល្បៈ-សង្គមកិច្ច និងការងារ : អូ ឈឺន

.ទេសរដ្ឋមន្ត្រីទទួលបន្ទុកសាធារណៈ សុខាភិបាល : ព្រះអង្គម្ចាស់ក្សត្រីនរោត្តមប៉េងបោះយុគន្ធរ

. រដ្ឋមន្ត្រីការបរទេសៈស៊ីសុវត្ថិស៊ីរីមតៈ

. រដ្ឋមន្ត្រីសាធារណៈការនឹងទូរគមនា គមន៍ : ញ៉ឹក ជូឡុង

. រដ្ឋមន្ត្រីមហាផ្ទៃ និងស្វ័យការពារ : ប្រាក់ សារិន

. រដ្ឋមន្ត្រីការពាជាតិ : ស៊ឹម វ៉ា

. រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ : ដាញ់ សួន

. រដ្ឋមន្ត្រីយុត្តិធម៌ : តុង អួនម៉ម

. រដ្ឋមន្ត្រីអប់រំជាតិនិងសន្តិសីទ :សម សារី

. រដ្ឋលេខធិការថវិកា : ប្រាក់ ប្រញ្ញើង

. ប្រតិភូព័តិមាន :សាមសុងហ្វៃណង់ ដេស

.អនុរដ្ឋលេខាធិកាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកកីឡា-យុវជន និងអប់រំមូលដ្ឋាន : ស៊ីវត្ថិឥស្សារ៉ូ

. អនុរដ្ឋលេខាធិការសង្គមកិច្ច និងការងារទទួលបន្ទុកកិច្ចការកសិករ : ម៉ៅ ចយ

.អនុរដ្ឋលេខាធិការជារាជប្រតិភូព័តិមានទទួលបន្ទុកឃោសនា និងអប់រំប្រជារាស្ត្រ : នរោត្តម វិរិយ៉ា

*តទៅលេខក្រោយ*

នាទី ព្រះពុទ្ធសាសនា

# អត្តបទស្តីអំពីខន្ធ៥ និងសមាធិវិប្បសនា

*តពីលេខមុន*

ឈាមរត់លឿនតឹងសសៃកហេវហត់ គ្មានមូលហេតុ ។ អ្នកប្រាជ្ញគ្រប់ជំនាន់បានអះអាងថា មនុស្សត្រូវបានឃុំសន្ធប់ក្នុងផ្សែងនៃសញ្ញាខន្ធ ឬការគិតមិនចេះ ឈប់ឈរ ឬការនិយាយម្នាក់ឯងខាងក្នុង ក្បាលមិនចេះចប់ ម្ចាស់ខ្លួនមិនចាប់អារម្មណ៍បាន ឬពុំដឹងទាល់តែសោះ ហើយគិតថា នេះជាធម្មតា ។ ចំណុចនេះហើយ ទើបយើងមើលឃើញ មនុស្សដែលមានសមាធិក្នុងខន្ធ និងមនុស្សសាមញ្ញលើសពីនេះ គេមានបន្ទប់មួយទៀត ដែលបើកផ្លូវឱ្យគេអាចសំរាក់ផុតពីភាពខ្វល់ខ្វាញ់នៃចិត្ត ដោយសារប្រការនេះ ហើយអ្នកសមាធិគិតការអ្វីបានហ្មត់ចត់ ខួរក្បាលគេភ្លឺថ្លា មានកម្លាំងពលំ មានសីលធម៌រស់ នៅក្នុងសន្តិភាពផ្លូវចិត្តជីវិតរបស់គេមានពន្លឺ ។

អ្នកប្រាជ្ញទំនើប បានប្រាប់យើងថា អស់លោកអ្នកអាចជួបនឹងវិញ្ញាណបរិសុទ្ធនេះ នៅពេលជួបនឹងហេតុការណ៍មួយអាស្ចារ្យហួសពីការស្មានដូចជាអស់លោកទៅមើលសៀកឃើញដំរីដើរជើងពីរ ឬអង្គុយលើជើងម៉ា ពេលនោះអស់លោកច្រហរមាត់ឆ្ងល់ ពិសោធន៍ភាពរីករាយនេះជាសញ្ញានៃវិញ្ញាណបរិសុទ្ធ ។ ក្នុងរយៈពេលមួយភ្លែតនោះ ខន្ធសញ្ញា និងសង្ខារសញ្ញាបានបញ្ឈប់សកម្មភាព បើកឱកាសឱ្យវិញ្ញាណបរិសុទ្ធអណ្តែតមកផ្ទៃលើនៃចិត្ត ។

អ្នកប្រតិបត្តិសមាធិយូរៗទៅនឹងអាចជួបនឹងពិសោធនិវិញ្ញាណបរិសុទ្ធនេះ ។

ចំពោះខ្ញុំផ្ទាល់ ឆ្លងកាត់ការប្រត្តិបត្តិសមាធិជិត ១០ឆ្នាំនេះ ខ្ញុំបានរកឃើញថា មានបន្ទប់ពីរ បន្ទប់ទី១ ខ្ញុំសំរាប់រស់នៅធម្មតាជាមនុស្ស (ការគិតគួរពិចារណា មានភ័យព្រួយ...) បន្ទប់ទី២ សំរាប់សំរាកខាងក្នុង ឬសំរាប់បោសសំអាតចិត្ត ។

**១.** បន្ទប់ទី១ នេះសំរាប៊រិះគិតពិចារណាស្រមៃ ។ បន្ទប់នេះខ្ញុំចាំបាច់សំរាប់ស្រាវជ្រាវរៀនសូត្រ ។ បន្ទប់នេះ ពោរពេញដោយគំនិតចាក់ស្រេះអារម្មណ៍ត្របាញ់ក្ងលក្នាញ់លាយឡំនឹងការភ័យ ខ្លាច ព្រួយ អរ សប្បាយ កើតទុក្ខច្រណែន ប្រចាន់ នេះក្នុងភាសាព្រះពុទ្ធសាសនាគេហៅថា វាលវដ្តសង្សា ។

**២.** បន្ទប់ទី២ : ក្រោយពីប្រតិបត្តិ សមាធិជិត ១០ឆ្នាំមកនេះ ខ្ញុំរកឃើញកន្លែងមួយទៀត ដែលអនុញ្ញាតិឱ្យខ្ញុំអាចសំរេកបានពីចរន្តវិកវរក្នុងបន្ទប់ទី១នោះ និងជាកន្លែងសំអាតចិត្តឱ្យបរិសុទ្ធ តើជាក់ស្តែង ខ្ញុំធ្វើដូចម្តេចឱ្យអាចសំរាកនិងសំអាតចិត្តបាន ?

**១.** ខ្ញុំត្រូវអង្គុយឱ្យរៀបរយប្រចាំថ្ងៃ១ថ្ងៃមួយដង ឬ២ដង ។ ក្នុងមួយពេលៗ ពី២០នាទីទៅ១ម៉ោង ។ ជួនកាលក៏អាក់ខាន ព្រោះរវល់ពេក ។ ការប្រតិបត្តិប្រចាំថ្ងៃនេះចាំបាច់ណាស់ ព្រោះធ្វើឱ្យប្រព័ន្ធរូបកាយចិត្តអាចហាត់ហ្វឹកហ្វឺនបានល្អ ។

**តទៅលេខក្រោយ**



## ប័ណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍

ខ្ញុំចង់ឱ្យ " ខ្មែរប៉ុស្តិ៍ " ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយព័តិមានក្នុងសហគមន៍ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាស័យដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :........................................................

អាស័យដ្ឋាន :................................................

........................................................U.S.A.

ទូរស័ព្ទ :......................................................

អ៊ីមែល :......................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួនមួយខែតម្លៃ ៥ ដុល្លារ ×.......(ចំនួនមួយខែ) =...................

U.A.M.G 5730Rising Sun Avenue Philadelphia,PA 19120

**Phone : (215) 722-2226**

# សម រង្ស៊ី ស្រមៃ ចន ម៉ាកខេន ...



ចន ម៉ាកខេន និង ប្រធានាធិបតី ប៊ុស



ចន ម៉ាកខេន

សម្លាប់មនុស្សក្រៅប្រព័ន្ធច្បាប់ ដោយនិទណ្ឌភាព ការធ្វើរដ្ឋប្រហារខុសច្បាប់នាខែកក្កដា ឆ្នាំ១៩៩៧ ករណីបោកគ្រាប់បែកបំបែកហ្វូងបាតុករនាថ្ងៃទី ៣០ មីនា ឆ្នាំ១៩៩៧ និងករណីបាញ់សម្លាប់ បំបែកហ្វូងបាតុករវាប់ម៉ឺននាក់ ដែលបានធ្វើ បាតុកម្មប្រឆាំងនឹងលទ្ធផលការបោះឆ្នោតខែ កញ្ញា ឆ្នាំ១៩៩៨ ថា ពុំមានសេរី និងយុត្តិធម៌ ព្រោះតែលួចបន្លំសន្លឹកឆ្នោតនោះ ។ ដែលរាល់ ករណីទាំងអស់នេះត្រូវបានលោក ចន ម៉ាកខេន ជារឿយៗតែង ធ្វើការរិះគន់លោក ហ៊ុន សែន ថា ជាជនផ្តាច់ការនៅពីក្រោយខ្នងនៃបទឧក្រិដ្ឋ-កម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រឆាំង សង្គ្រាមរបស់សហរដ្ឋអាមេរិក ត្រូវតែមាន ចំណាត់ការក្នុងការដាក់សំពាធនយោបាយទៅ លើប្រទេសកម្ពុជាក្នុងទណ្ឌកម្មណាមួយដែល អាចប្រើទៅបាន ។ លោក សម រង្ស៊ី និយាយ-ថា លោក ចន ម៉ាកខេន ជាអ្នកស្រឡាញ់ សេរីភាព, យុត្តិធម៌, ប្រជាធិបតេយ្យ ដោយ លោកគាំទ្រជានិច្ចចំពោះអ្នកប្រជាធិបតេយ្យ ដូច្នេះបើសិនលោកជាប់ជាប្រធានាធិបតីប្រទេស កម្ពុជានឹងមានប្រែប្រួលនូវស្ថានការណ៍ ។

ប៉ុន្តែ ការចោទប្រកាន់នេះត្រូវបានពួកមន្ត្រី ជាន់ខ្ពស់របស់រដ្ឋាភិបាលលោក ហ៊ុន សែន ធ្លាប់ បានអះអាងជារឿយៗកន្លងមកថា ជាទង្វើរៀប ចំសណ្តាប់ធ្នាប់សង្គម ដើម្បីបំបាត់ភាពអនា-ធិបតេយ្យ និងពួកអ្នកបះបោរខុសច្បាប់ ។

លោក សម រង្ស៊ី ថ្លែងថា គម្រោង ដើម្បី យកឈ្នះ ហ៊ុន សែន ក្រៅពីជាប់ទាក់ទងទៅនឹង នយោបាយសហរដ្ឋអាមេរិក គឺគម្រោងការធំៗ ៣ ដើម្បីរកជោគជ័យនៅក្នុងការបោះឆ្នោត សកល នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាង មុខនេះ ដើម្បីរកការឈ្នះ និងផ្តួលរំលំរបប ហ៊ុន សែន ដូចជាការសន្យាប្រគល់ដីធ្លីឱ្យប្រជាពល-រដ្ឋវិញ ការសន្យាឱ្យប្រជាជនមានការងារធ្វើ និងការលើកកំពស់សុខមាលភាពជួយព្យាបាល អ្នកក្រីក្រឱ្យទៅពេទ្យដោយមិនបាច់បង់ថ្លៃប្រាក់ នោះ ដោយរួមទាំងស្ថានភាពទំនិញឡើងថ្លៃ ជា ការធ្វើឱ្យប្រជាជនខឹងសម្បាចំពោះអ្នកដឹកនាំ រដ្ឋាភិបាលបច្ចុប្បន្ន ដែលគ្រប់គ្រងអំណាច ដោយលោក ហ៊ុន សែន ។

កន្លងទៅថ្មីៗនេះ លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានថ្លែងថា ប្រទេសជាតិនឹងមាន អស្ថេរភាពក្រោយពេលគណបក្សប្រជាជន កម្ពុជាបាត់បង់អំណាច នៅក្នុងការបោះឆ្នោត អាណត្តិក្រោយ ព្រោះគណបក្សប្រជាជនកម្ពុជា និងរូបលោកបានធ្វើការអភិវឌ្ឍន៍បាននូវសមិទ្ធិ ផលច្រើនណាស់ ។ អ្នកនិយមគាំទ្រគណបក្ស ប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន ថា សម រង្ស៊ី កំពុងស្រមៃអួតអាងហួសមាឌហើយ ដោយ គ្មានផ្លូវណាអាចយកឈ្នះ ហ៊ុន សែន បានទេ គេ គួរដឹងហើយថា គណបក្សប្រជាជនកម្ពុជាកំពុង ក្តោបអំណាច៥ចំណុចគឺៈ អំណាចលុយ, អំណាច កម្លាំងអាវុធ, អំណាចប្រព័ន្ធសារព័ត៌មាន, អំ-ណាចពីអ្នកចេះដឹង និងអំណាចស្នូលបក្ស ដែល សកម្មជនគណបក្សនៅមូលដ្ឋានម្នាក់គ្រប់គ្រង ១០នាក់នោះ ។ លោក សម រង្ស៊ី អះអាងថា ស្ថានការណ៍នយោបាយកម្ពុជា បច្ចុប្បន្នវាជា សម័យកាលបញ្ញាញាណ គេមិនអាចធ្វើអ្វីផ្តេស ផ្តាស់ដោយប្រើអំណាចកំលាំងប្រដាប់អាវុធជា តិ នោះទេ ហើយពួកកំលាំងប្រដាប់អាវុធក៏គេ លែងលង់បន្តបំរើលោក ហ៊ុន សែន ដើម្បីទៅ សំលាប់បងប្អូនប្រពន្ធកូនគេទៀតទេ ។

អគ្គលេខាធិការគណបក្ស សម រង្ស៊ី លោក អេង ឆៃអ៊ាង បានប្រាប់ខ្មែរប៉ុស្តិ៍តាមទូរស័ព្ទឱ្យ ដឹងថា សំដីលោក ហ៊ុន សែន គឺជាការគំរាម មួយទៅដល់អ្នកបោះឆ្នោតគាបសង្កត់ឱ្យមាន ការបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា ដែល ជាទង្វើមិនស្របច្បាប់នាំឱ្យមានការអាប់អួរដល់ បរិយាកាសសង្គម ដែលប្រជារាស្ត្រមិនអាចធ្វើ ការសម្រេចទៅតាមឆន្ទៈរបស់ខ្លួនបាន ដោយ ពួកគាត់ធ្វើការសម្រេចទៅតាមអ្វីដែលពួកគេ ធ្វើការគំរាមកំហែងនោះ ។

អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា ខៀវ កញ្ញារិទ្ធ ប្រាប់អ្នកកាសែតថា សេចក្តីថ្លែងការលោក ហ៊ុន សែន មិនមែនជាការគំរាមកំហែងទេ គឺ ជាការឆ្លើយតបទៅនឹងសំដីលោក សម រង្ស៊ី កន្លងមកតែងតែស្រែកក្តែងៗថា បើខ្លួនឈ្នះ ឆ្នោតលោកនឹងសើរើដីធ្លី និងការវិនិយោគទាំង ឡាយ ដែលទាំងអស់នេះត្រូវគេគិតថា នាំឱ្យ មានបញ្ហាជាថ្មីក្នុងសង្គមជាតិអស្ថេរភាពនយោ-បាយ ។ ប៉ុន្តែ លោក សម រង្ស៊ី និយាយថា នេះ ជាលេស និងល្បិចកលរបស់ក្រុមជនផ្តាច់ការ ដើម្បីបំរើអំណាចបង្កអំពើពុករលួយជិះជាន់ រំលោភបំពានដីធ្លី និងសិទ្ធិសេរីភាពប្រជាពលរដ្ឋ តែប៉ុណ្ណោះ ។

ក្រុមអ្នកវិភាគគិតថា ប្រទេសមានស្ថេរភាព ឬអស្ថេរភាពវាស្ថិតនៅនឹងដៃលោកនាយករដ្ឋ មន្ត្រី ហ៊ុន សែន ព្រោះអំណាចមានគ្រប់គ្រាន់នូវ កម្លាំងប្រដាប់អាវុធ ដោយគ្មានអ្នកណាហ៊ានបះ បោរប្រឆាំងចំពោះលោក ហ៊ុន សែន ឡើយ ។ ដែលវាខុសពីស្ថានភាពនយោបាយកាលពីអាណត្តិ ទី១ ដែលមានសហនាយករដ្ឋមន្ត្រី២នាក់ ដោយ កម្លាំងទ័ពក៏បែកចេញជាពីរផ្នែកប្រកាន់គោល ជំហរការពារគណបក្សខ្លួន និងអ្នកដឹកនាំរបស់ ខ្លួន ដែលជាការងាយចោទគ្នាបានពីអ្នកបង្ក បាតុភាពធ្វើឱ្យមានអស្ថេរភាព រហូតដល់មាន ការផ្ទុះអាវុធបង្ហូរឈាមគ្នាក្នុងអំពើរដ្ឋប្រហារ មួយនាថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ដែល ឱកាសនោះកងទ័ពហ្វ៊ុនស៊ិនប៉ិច ដែលស្មោះត្រង់ នឹងព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ, ញ៉ឹក ប៊ុនឆៃ ត្រូវបានវាយបាត់ស្រមោល នៅក្រោមអំណាច ក្តោបក្តាប់ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តែមួយ ដោយគ្មានអ្នកណាប្រឆាំងក្នុងផ្នែក នយោបាយបានឡើយ ។ ដោយអ្នកវិភាគ នយោបាយមិនបញ្ចេញឈ្មោះដាក់សំណួរថា តើអស្ថេរភាពនយោបាយដែលលោក ហ៊ុន សែន អះអាង ក្រោយពីខ្លួនចាញ់ឆ្នោត វាអាចកើតចេញ ពីណាមកបាន ? ។

អ្នកវិភាគនយោបាយខ្មែរ-អាមេរិកាំង សុំមិន បញ្ចេញឈ្មោះបច្ចុប្បន្នជាសាស្ត្រាចារ្យផ្នែកវិទ្យា សាស្ត្រនយោបាយនៅសាកលវិទ្យាល័យ UC Berkerly រដ្ឋ California ភាគខាងជើង បាន លើកសំដីលោក សម រង្ស៊ី ដែលបានអះអាងថា ប្រសិនបើលោក ចន ម៉ាកខេន ឈ្នះឆ្នោត នយោបាយការទូតនឹងជំរុញជួយដល់កម្ពុជាក្នុង ការប្តូររបប ហ៊ុន សែន នោះ វាមិនប្រាកដនោះ ទេ ។ ព្រោះនីតិរដ្ឋប្រទេសនីមួយៗមានច្បាប់ រដ្ឋធម្មនុញ្ញជាគោល និងគោលការណ៍យុទ្ធសាស្ត្រ ក្នុងការគ្រប់គ្រងប្រទេសជាមួយនយោបាយ ការទូតក្រៅប្រទេសលើពិភពលោក ។ ដូច្នេះការ សម្រេចផែនការណាមួយប្រឆាំងទៅនឹងប្រទេស ណាមួយត្រូវឆ្លងកាត់ចំណាត់ការនូវអ្វីដែលជា ការដាក់សំពាធ ឬធ្វើទណ្ឌកម្មទៅលើប្រទេសណា នោះ ចាំបាច់ត្រូវឆ្លងកាត់ក្រុមប្រឹក្សាសន្តិសុខ ជាតិ ឬក្រុមសភាអាមេរិកាំងថា តើត្រូវធ្វើ ឬ មិនត្រូវធ្វើ ហើយបើធ្វើខាតបង់អ្វីខ្លះទាំងសម្ភារៈ, នយោបាយការទូត និងបានផលចំណេញអ្វីទៅ ? ព្រោះជាការចៀសវាងនូវបាតុភាពប៉ះពាល់ដល់ អធិបតេយ្យភាពប្រទេសជាតិដទៃ ។

ប៉ុន្តែ អ្នកវិភាគនយោបាយរូបនោះបាន ព្យាករណ៍ថា បើសិន ចន ម៉ាកខេន ជាប់ឆ្នោត ឥទ្ធិពលនយោបាយរដ្ឋបាលរបស់លោកនៅ សេតវិមាន នឹងមានវិធានការណ៍នយោបាយការ ទូត ក្នុងការរកចំណាត់ការកំណែទម្រង់ដឹកនាំ របស់មេដឹកនាំកម្ពុជា តាមលក្ខខណ្ឌផ្តល់ជំនួយ អភិវឌ្ឍន៍ ក្នុងការចាប់យករបបគ្រប់គ្រងតាម បែបលទ្ធិប្រជាធិបតេយ្យ និងការគោរព សិទ្ធិមនុស្សពិតប្រាកដ វាសង្ឃឹមច្រើន ជាងការឱ្យសហរដ្ឋអាមេរិកទៅផ្តួលរំលំ ឬប្តូររបប ឬក៏ ទម្លាក់ ហ៊ុន សែន នោះ ព្រោះមានឧទាហរណ៍សង្គ្រាមអាមេរិក នៅអ៊ីរ៉ាក់, អាហ្គានីស្ថាន ជាគំរូ ស្រេច ហើយ ។ វាជាទំលាប់នៃអ្នកនយោបាយ ខ្មែរទៅហើយ នៅពេលរដូវកាលបោះ ឆ្នោតម្តងៗ គេតែងជួបប្រទះនូវការរិះ គន់លើកមុខមាត់ អួតអាងតែរៀងៗខ្លួន ដើម្បីទាក់ទាញប្រជាប្រិយភាពក្នុងការ ធ្វើប្រជាភិថុតនយោបាយជាមួយប្រជាជន ក្នុងការទាញយកសន្លឹកឆ្នោតសំរាប់ គណបក្សនយោបាយខ្លួន ។

នៅក្នុងបោះឆ្នោតសកលនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ខាងមុខនេះ មាន គណបក្សនយោបាយចំនួន៥៦ ដែលបាន ចូលរួមធ្វើការបោះឆ្នោត ។ ប៉ុន្តែគេ សង្កេត ឃើញតែគណបក្សចំនួន៥តែប៉ុណ្ណោះ ដែលកំពុងស្ថិតនៅក្នុងការពិចារណា និងក្តី សម្រេចចុងក្រោយសំរាប់ពលរដ្ឋខ្មែរបោះឆ្នោត ឱ្យនោះ មានគណបក្សប្រជាជនកម្ពុជា, គណបក្ស សម រង្ស៊ី, គណបក្សហ្វ៊ុនស៊ិនប៉ិច, គណបក្ស នរោត្តម រណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស ។

**+ អតីតអ្នកទោសឈ្លើយសឹកសង្គ្រាមនៅ វៀតណាម :**

នៅក្នុងអំឡុងសង្គ្រាមនៅប្រទេសវៀតណាម ខាងជើងនោះ លោក ចន ម៉ាកខេន ដែលជា ទាហានផ្នែកទ័ពអាកាស លោកបានបើកយន្ត ហោះទៅទម្លាក់គ្រាប់បែកស្ទើររាប់ភ្លេច ។ ប៉ុន្តែ មានគ្រាមួយលើកនោះ គឺនៅឆ្នាំ១៩៦៧ យន្ត ហោះរបស់លោកត្រូវបានទាហានវៀតណាម បាញ់ទម្លាក់ ហើយរូបលោកត្រូវបានទាហាន យួន ចាប់ដាក់គុកក្នុងរយៈពេល៥ឆ្នាំ ទើបដោះ លែងវិញក្នុងឆ្នាំ១៩៧៣ ។ ក្នុងអំឡុងពេលជាប់ មន្ទីរឃុំឃាំងនោះ ចន ម៉ាកខេន ទទួលរងនូវ ទារុណកម្មយ៉ាងធ្ងន់ធ្ងរបំផុត ដោយធ្វើឱ្យរូប លោកមានរបួសពិការដៃ និងជើង ដែលមាន សល់ស្លាកស្នាមរហូតមកដល់បច្ចុប្បន្ន ។ ហើយ សំណាងមួយក្នុងមួយលានគ្រោះថ្នាក់នៃជីវិត គាត់មិនត្រូវបានយួនសម្លាប់ក្នុងនាមជាអ្នក ទោសឈ្លើយសឹកសង្គ្រាមនោះ ក៏ព្រោះតែរូប គាត់ គឺជាកូនប្រុសរបស់លោកមេបញ្ជាការកង ទ័ពជើងទឹកប្រចាំអាស៊ីប៉ាស៊ីហ្វិករបស់សហរដ្ឋ អាមេរិក ។

ក្រោយពីមានសេរីភាពពីការដោះលែងលោក

ចន ម៉ាកខេន បានត្រឡប់មកកាន់សហរដ្ឋអាមេរិក ។ ប៉ុន្តែប្រពន្ធរបស់គាត់មិនបានពេញចិត្ត គាត់ដូចជាពេលមុនទៀតទេ ដោយសារតែរូប គាត់ជាអ្នករបួស ដែលនាងគិតថាមិនអាចជាដូច ដើម ហើយម៉្យាងទៀតនោះ នាងក៏មានមនុស្ស ថ្មីនៅក្នុងចិត្តនាងដែរ ដោយនាងមិនអាចទទួល ប្តីដែលពិការបានទេ ដែលជាការធ្វើឱ្យអ្នកទាំង ពីរត្រូវចែកផ្លូវគ្នាដើរ ។ ចំណែក ម៉ាកខេន ពេល នោះក៏មិនតក់ស្លុតនឹងប្រពន្ធបែកចិត្ត និង ស្អិតទ្រូងអ្វីទេ ក្នុងនាមជាយុទ្ធជនអង់អាច ក្លាហានម្នាក់ត្រូវសម្ងំសំរាកព្យាបាលខ្លួន ព្រោះ ជើងរបស់លោកខាងឆ្វេងមានរបួសខ្លាំងស្ទើរតែ ដើរមិនរួចតែនៅទីបំផុតក្រុមគ្រូពេទ្យក៏អាច ព្យាបាលឱ្យលោកបានជាសះស្បើយឡើងវិញ ។

លោក ចន ម៉ាកខេន មានឈ្មោះពេញ ចន ស៊ីតនីម៉ាកខេន កើតនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ ១៩៣៦ ។ ជីតា និងឪពុករបស់លោកសុទ្ធតែជា មេបញ្ជាការកងទ័ពជើងទឹកដ៏ល្បីនៅអាមេរិក ។ ម៉ាកខេន បានសិក្សាចប់ថ្នាក់កងទ័ពជើងទឹកនៅ សហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៥៨ ។

ដោយលោកចាប់យកជំនាញជាអាកាសយានិកចម្បាំងលើនាវា ។ លោក ម៉ាកខេន បានរៀប ការជាមួយស្ត្រីមេម៉ាយកូន២ឈ្មោះ Carol Shepp ដែលនាងជាតារាបង្ហាញម៉ូដម្នាក់មកពី ភីឡាដឺភៀ រដ្ឋផេនស៊ីវ៉ានៀរ ក្នុងឆ្នាំ១៩៦៥ ។ លោក ម៉ាកខេន និងនាង Carol បានកូនស្រីម្នាក់ ឈ្មោះ ស៊ីតនី ដែលកើតនៅក្នុងខែកញ្ញា ឆ្នាំ ១៩៦៦ មុនការចេញធ្វើសង្គ្រាមសឹកនៅវៀត ណាម កាលកូនស្រីគាត់មានអាយុ១ឆ្នាំ ។

ក្រោយពីរួចពីទុក្ខទោសជាអតីតអ្នកទោស សង្គ្រាមសឹកនៅវៀតណាមបានមួយឆ្នាំ ដែល នៅក្នុងឆ្នាំ១៩៧៤ លោកក៏បន្តបើកយន្តហោះ ចម្បាំងជាបន្តទៀត ហើយលោកក៏ទទួលបាន ឋានៈជាមេបញ្ជាការនៅលើនាវាចម្បាំងឈ្មោះ "A-7 Corrsair" ក្នុងរដ្ឋផ្លរីដា ។ លោកជាមេដឹក នាំដែលមានសមត្ថភាព ហើយមានការងារច្បាស់ លាស់ ដែលធ្វើឱ្យអ្នកនៅក្រោមឱវាទគោរព ស្រឡាញ់ ហើយថ្នាក់លើក៏ពេញចិត្តចំពោះការ ងាររបស់លោកដែរ ។ នៅឆ្នាំ១៩៧៧ លោក ក៏បានផ្លាស់មកនៅវ៉ាស៊ីនតោន ដែលជាមូលដ្ឋាន ផ្តុំដោយអ្នកនយោបាយដឹកនាំប្រទេស ដែល បានជំរុញចិត្តលោកឱ្យប្រឡូកចូលទៅក្នុងឆាក នយោបាយអាមេរិក ដែលឆ្នាំ១៩៧៩ លោក ម៉ាកខេន បានជួបនិងមានទំនាក់ទំនងជាមួយ នឹងនាង Cindy Lou Hensl ដែលជាគ្រូបង្រៀន ម្នាក់មកពី Phoenix រដ្ឋ Arizona ដែលជា ទីកន្លែងរបស់លោកក្លាយជាព្រឹទ្ធសភាអាមេរិក ប្រចាំរដ្ឋមួយនេះសព្វថ្ងៃ ព្រោះឪពុក ម៉ាកខេន និងឪពុកនាង គឺជាមិត្តភ័ក្តិនិងគ្នាជាអ្នកមាន ទ្រព្យសម្បត្តិស្តុកស្តម្ភដូចគ្នា ។

នៅក្នុងឆ្នាំ១៩៨០ លោក ម៉ាកខេន ក៏បាន លែងលះគ្នាដាច់ស្រេចជាមួយប្រពន្ធដើម ។ ដោយការដោះស្រាយដើម្បីបញ្ចប់រឿងលែង លះគ្នានោះ គឺលោកបានប្រគល់ផ្ទះពីរកន្លែងឱ្យ នាង និងប្រាក់មួយចំនួនថែមទៀត ទើបលោក រៀបការជាលើកទីពីរជាមួយគូស្នេហ៍ថ្មី គឺនាង Cindy នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៨០ ។

ម៉ាកខេន បានចូលនិវត្តន៍ឈប់ពីទាហាន ជើងទឹកនៅខែមេសា ឆ្នាំ១៩៨១ ។ នៅក្នុង អំឡុងឆ្នាំ ១៩៨៤ ក្រោយពីអាពាហ៍ពិពាហ៍ លើកទីពីរបាន ៤ឆ្នាំ ម៉ាកខេន និងប្រពន្ធរបស់ គាត់ Cindy បានកូនស្រីម្នាក់ឈ្មោះ Maghan រួចពីរឆ្នាំក្រោយមកគាត់មានកូនប្រុសម្នាក់ទៀត ឈ្មោះ Jonh Sidney Iv ហើយនៅក្នុងពេល ជាមួយគ្នានោះដែរ លោក និងភរិយាក៏បានទទួល យកក្មេងស្រីម្នាក់ដែលមានអាយុ៣ខែមកចិញ្ចឹម ដោយដាក់ឈ្មោះថា Brigel ។

## +ជីវប្រវត្តិ និងការប្រឡូកចូលធ្វើទាហាន និងឆាកនយោបាយ :

ជីវិត ចន ម៉ាកខេន ចាប់ផ្តើមឱ្យមានផ្លូវដើរ នៃដំណើរជីវិតទៅហើយនោះ គឺលោកត្រូវយក អាជីពទាហានជាចំបង ព្រោះនេះជាមុខរបរ ប្រចាំត្រកូលរបស់លោកទៅហើយ ។ ឪពុក និង ជីតារបស់គាត់ គឺអ្នកទាំងពីរជាមេបញ្ជាការកង ទ័ពជើងទឹកដូចគ្នា ដែលធ្លាប់បានឆ្លងកាត់ក្នុង ការចេញប្រយុទ្ធក្នុងសមរភូមិក្តៅធំៗជាច្រើន លើក ។




ចន ម៉ាកខេន ក្នុងឱកាសឃោសនាជាបេក្ខជនប្រធានាធិបតីសហរដ្ឋអាមេរិក

ក្រុមគ្រួសាររបស់ ម៉ាកខេន រួមទាំងបងស្រី និងប្អូនស្រី គឺសុទ្ធតែដើរតាមគន្លងឪពុកជាពូជ អ្នកទាហាន ព្រោះតែរាល់ពេលឪពុកដើរតាមនា វ៉ា នោះពួកលោកក៏ទៅជាមួយដែរ ។ ហើយ ចំពោះរូបលោកវិញធ្លាប់បានឆ្លងកាត់ចូលសាលា រៀនជាង២០ផ្សេងគ្នាមកហើយ ដោយសារ ឪពុករបស់លោកមិនមែនជាទាហានអចល័ត នៅមួយកន្លែងទេ ផ្លាស់ប្តូរទីតាំង ឬមូលដ្ឋាន គ្រប់ទីកន្លែងមិនថាក្នុង ឬក្រៅប្រទេស ដែលជា ចលនាផ្លាស់ប្តូរតម្រូវឱ្យរូបលោក ម៉ាកខេន រត់តាមពីក្រោយឪពុកជានិច្ច ។ នៅក្នុងឆ្នាំ ១៩៥១ ស្ថិតក្នុងភាពយុវវ័យគ្រួសាររបស់គាត់ ក៏បានទិញផ្ទះមួយខ្នង នៅឯតំបន់ Viginia ខាង ជើង ដែលនៅពេលនោះលោក ម៉ាកខេន ក៏បាន ផ្លាស់ប្តូរចូលសិក្សានៅវិទ្យាល័យ Episcopal ។ ក្រោយមកក៏បានសិក្សានៅសាលាឯកជនមួយ នៅឯ Alexandria ដោយនៅទីនោះលោកក៏ បានចូលសិក្សាបន្តថ្នាក់បរិញ្ញាផ្នែកកងទ័ពរៀន នូវមុខវិជ្ជាជាច្រើន ហើយអ្វីដែលលោកបាន ទទួលពិន្ទុច្រើនជាងគេនោះ គឺផ្នែកកីឡាកាស ។ ម៉ាកខេន បានបញ្ចប់បរិញ្ញាបត្រកងទ័ពទូទៅ នៅឆ្នាំ១៩៥៤ ។

ការដើរតាមជំហានរបស់ជីតា និងឪពុក របស់លោកនោះ ម៉ាកខេន ក៏បានចូលទៅបន្ត ថ្នាក់បណ្ឌិតផ្នែកកងទ័ពជើងទឹកនៅសហរដ្ឋអាមេរិកថែមទៀត ។ នៅទីនោះគាត់បានស្គាល់ មនុស្សជាច្រើន ។ តែនៅក្នុងចំណោមនោះ មិន មែនសុទ្ធតែមានអ្នកល្អទាំងអស់នោះទេ មានតែ មួយចំនួនដែលចូលចិត្តរករឿង និងសម្លុតពួក គាត់ជាញឹកញាប់ ។ ដោយមិនអាចទ្រាំទ្របាន រូបគាត់តែងតែរករឿងជាមួយគេវិញ រហូតដល់ ថ្នាក់ណាត់គ្នាវាយតប់ទៀតផង ។ តែទង្វើនោះ មិនទាន់ធ្វើផង រូបគេត្រូវទទួលទោសពីគ្រូជា មុនទៅហើយ ។ ហើយទីបំផុតគាត់បញ្ចប់វគ្គ សិក្សាទាហានជើងទឹកថ្នាក់បណ្ឌិតនៅឆ្នាំ១៩៥៨ ។

ឆ្នាំ១៩៦០ ម៉ាកខេន បញ្ចប់ថ្នាក់បើកបរយន្ត ហោះចម្បាំង ដោយចេញពីសាលារៀននោះមក គាត់ក៏បានក្លាយជាអាកាសយានិកបើកបរយន្ត ហោះចម្បាំង ។ បន្ទាប់មក ម៉ាកខេន បានចំណាយ ពេលអស់ពីរបីឆ្នាំនៅក្នុងការរស់នៅក្នុងអាកាស យានដ្ឋាន A-1 Skyrai-der ។ ដោយនៅទីនោះ លោកឧស្សាហ៍ចេញល្បាតនៅតាមសមុទ្រ Caribbea និង Mediterranean ។ នៅអំឡុង ពេលហ្វឹកហាត់ដោយផ្ទាល់នោះ លោកធ្លាប់បាន ជួយយន្តហោះចម្បាំងរបស់មិត្តភ័ក្តិបានពីរ គ្រឿង ឱ្យគេចេញពីខ្សែប្រយុទ្ធរបស់ខ្មាំងដោយ សុវត្ថិភាព ។ ម៉ាកខេន បានក្លាយជាសមាជិក សមាជម្នាក់តំណាងឱ្យនៅតំបន់ Phoenex ហើយនៅពេលនោះដែរ លោកក៏បានធ្វើការ នៅក្រុមហ៊ុន Hensley & Co. ជាក្រុមហ៊ុន ឪពុកក្មេកលោកឈ្មោះ Jim Hensley ដែល ជាអ្នកជំនួញធំនៅទីនោះ ។ លោក ម៉ាកខេន មានភារកិច្ចទទួលតួនាទីជាប្រធានក្រុមហ៊ុន ហើយក៏ជាអនុប្រធានបក្សនៅក្នុងតំបន់នោះ ដែរ ។ ដោយសារតែលោកជាអ្នកនយោបាយ ម្នាក់ដែរនោះ បានធ្វើឱ្យរូបលោកមានមុខមាត់ កាន់តែខ្លាំង ហើយមុខជំនួញក៏កាន់តែពង្រីកធំ ឡើងៗ ហើយនៅឆ្នាំ១៩៨២ គាត់ក៏ត្រូវបានគេ បោះឆ្នោតជ្រើសរើសជាចៅហ្វាយក្រុងប្រចាំនៅ អារីហ្សូណា ។ លោកបានបំរើការងារនេះបាន២ អាណត្តិ ដែលក្រោយមកនៅឆ្នាំ១៩៨៦ លោក ត្រូវបានគេជ្រើសរើសឱ្យធ្វើជាសមាជិកព្រឹទ្ធសភា តំណាងឱ្យរដ្ឋ Arizona នៅក្នុងឆ្នាំ១៩៨៦, ១៩៩២, ១៩៩៩ និង២០០៤ ។ ម៉ាក ខេន កាលពីឆ្នាំ២០០០ លោកក៏ធ្លាប់ឈរឈ្មោះជា បេក្ខជនប្រធានាធិបតីដែរ ប៉ុន្តែបានចាញ់លោក ចច ដាប់បែលយូប៊ូស ។

ក្នុងឆ្នាំ២០០៨នេះ លោកត្រូវបានគេជ្រើស រើសឱ្យធ្វើជាបេក្ខជនប្រធានាធិបតី តំណាងឱ្យ គណបក្សសាធារណរដ្ឋ ឆ្លងតាមការបោះឆ្នោត ទទួលបានជោគជ័យ ។

ការលើកឡើងពីស្ថានភាពនយោបាយ កម្ពុជា ភ្ជាប់ជាមួយស្ថានការណ៍នយោបាយអាមេរិក ដែលយើងលើកយកបរិយាយ ដោយទាញ យកប្រវត្តិបេក្ខជនប្រធានាធិបតីអាមេរិក ចន ម៉ាកខេន នេះឡើងមិនសបញ្ជាក់ថា កាសែត ខ្មែរប៉ុស្តិ៍ឡង់សេ ឬមាននិន្នាការនយោបាយ បំរើ គណបក្សសាធារណរដ្ឋនោះទេ គឺគ្រាន់តែចង់ឆ្លុះ បញ្ចាំង និងបង្ហាញឱ្យបងប្អូនខ្មែរ ដែលមាន សញ្ជាតិអាមេរិកាំងបានដឹងឮ និងថ្លឹងថ្លែងក្នុង ការសម្រេចចិត្តបោះឆ្នោត ដើម្បីយកសិទ្ធិរបស់ ខ្លួន រួមចំណែកអភិវឌ្ឍន៍សង្គម និងមូលដ្ឋានក្នុង ជីវភាពរស់នៅរបស់ខ្លួន ដែលជាអតីតជនភៀស ខ្លួនខ្មែរនៅលើទឹកដីរបស់ គេ ដែលបានផ្តល់សេចក្តី សុខគ្រប់បែបយ៉ាងឱ្យដល់ យើងរាល់គ្នា ថាតើនៅ ទីបញ្ចប់ខ្មែរគ្រប់រូប ដែល ក្លាយជាពលរដ្ឋអាមេរិកាំង ត្រូវធ្វើយ៉ាងណា ដើម្បី ជួយគេវិញនោះ ? តាម បែបគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដែល យើងជាម្ចាស់កម្មសិទ្ធិ សម្រេចវាសនាប្រទេស ដូចជាតិម្ចាស់ដើមរបស់ គេដែរ ។

នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៨នេះ នឹងមានការ បោះឆ្នោតជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិក ។ រយៈពេលជាច្រើន ខែមុនការបោះឆ្នោតចូលមកដល់គណបក្សសាធារណរដ្ឋ និងគណបក្សប្រជាធិបតេយ្យបាន ធ្វើការជ្រើសរើសបេក្ខជនតំណាងគណបក្សរៀងៗ ខ្លួន ក្នុងការត្រៀមប្រកួតប្រជែងយកតំណែងជា ម្ចាស់សេតវិមាន " White House" ។ គណបក្ស សាធារណរដ្ឋដែលកំពុងកាន់អំណាចបច្ចុប្បន្ន បានជ្រើស តាំងបេក្ខជនប្រធានាធិបតីរបស់ខ្លួន រួចហើយ តាមរយៈការបោះឆ្នោត គឺលោកសមាជិកព្រឹទ្ធសភា ចន ម៉ាកខេន ជាអតីតអាកាស យានិកចម្បាំង ដែលត្រូវទាហានវៀតណាមបាញ់ ទម្លាក់ ដោយចាប់បានជាឈ្លើយសឹកសង្គ្រាមដាក់គុកធ្វើទារុណកម្មអស់រយៈពេលជាង៥ឆ្នាំ ។ ប៉ុន្តែសំរាប់គណបក្សប្រជាធិបតេយ្យមិនទាន់ សម្រេចជាផ្លូវការនូវបេក្ខជនប្រធានាធិបតីនៅ ឡើយ ដោយលោកស្រី ហ៊ីឡារី គ្លីនតុន និងលោក បារ៉ាក់ អូបាមា ប្រកួតគ្នាពុំទាន់ដឹងចាញ់ឈ្នះនៅ ឡើយ ។ ដែលករណីនេះ នៅពេលដែលបេក្ខជន ទាំងពីរ ដែលអ្នកណាមួយឈ្នះសំរាប់គណបក្ស ប្រជាធបិតេយ្យកាសែតខ្មែរប៉ុស្តិ៍នឹងលើកបង្ហាញ ពីសមត្ថភាពដឹកនាំ និងខ្សែប្រវត្តិជីវិតក្នុងការ បរិយាយជូនអ្នកអាន ដើម្បីពិចារណានៅក្នុង សន្លឹកឆ្នោតរបស់លោកអ្នក នាខែវិច្ឆិកា ឆ្នាំ ២០០៨ខាងមុខ ៕

សុខភាព

# គុណប្រយោជន៍នៃបន្លែដែលទទួលទាន



-**ស្ពៃក្តោប** : វាមានវីតាមីនសេច្រើន ទទួលទានទឹកស្ពៃក្តោបក្នុង១ថ្ងៃ២កែវ និង ជួយព្យាបាលរោគរលាកក្រពះអាហារ ស្ពៃក្តោបមានសារជាតិប្រឆាំងរោគមហារីកជាច្រើនប្រភេទទៀតផង ។

-**គុយឆាយ** : សំបូរទៅដោយសារជាតិអាហារ ហើយថែមទាំងមានបេតាការ៉ូទីន ដែលជួយការពាររោគមហារីក ធ្វើឱ្យកាត់បន្ថយឱកាសក្នុងការកើតរោគមហារីកពោះវៀនធំបាន ។ ស្លឹកគុយឆាយ មានគុណប្រ-យោជន៍ច្រើនជាងផ្កា របស់វា ។

-**ខាត់ណា** : វាមានវីតាមីនសេនៅក្នុងនោះយ៉ាងច្រើន ព្រមទាំងកាល់ស្យូមវាផ្តល់ឱ្យនូវផលល្អបំផុត ប្រសិនបើទទួលទានខាត់ណានៅស្រស់នោះ ។

-**ការ៉ុត** : មានបេតាការ៉ូទីន ជួយកំចាត់សារជាតិបង្ករោគមហារីក ដែលសារជាតិការពាររោគមហារីកទទួលបាន ជាពិសេសមហារីកសួត ប្រសិនបើទទួលទានការ៉ុតស្រស់ដូចជាបុកល្ហុង ឬក៏ទឹកការ៉ុតនោះ ពិតជាមិនប្រឈមជាមួយនិងរោគមហារីកសួតនោះទេ ។

-**ផ្កាខាត់ណា** : វាមានវីតាមីន C ជួយឱ្យញើសចេញបានល្អ មិនកើតរោគផ្តាសាយ មិនប្រឈម និងរោគមហារីក និងជួយឱ្យស្ពៃមមានភាពរឹងមាំ ។

-**ដើមខ្ទឹម** : មានបេតាការ៉ូទីន ថែមទាំងមានសារជាតិពពួក ហ្វ្លាវ៉ូណយ ជាពិសេសខ្វេសេទីន ដែលជាអាវក្រោះការពាររោគមហារីក ។

-**ត្រសក់** : អាចធ្វើឱ្យស្បែកបានស្រស់ថ្លាមានសំណើមកាត់បន្ថយជាតិស្ករនៅក្នុងឈាម ( មិនប្រើចំពោះអ្នកកើតរោគមហារីក ) ។

-**សណ្តែកបារាំង** : វាមានវីតាមីន C ដែលបន្លែប្រភេទនេះ អាចនឹងបាត់បង់គុណភាពក្រោយពេលរងនឹងកំដៅខ្លាំង ។

-**សណ្តែកបណ្តុះ** : ក្នុងសណ្តែកបណ្តុះមួយកូនចាន វាផ្តល់ឱ្យនូវវីតាមីន C មួយភាគ១០នៃតំរូវការរាងកាយក្នុង១ថ្ងៃ ។ ក្នុងសណ្តែកបណ្តុះមានជាតិដែក និង វីតាមីន B បន្តិចបន្តួច ។ សណ្តែកបណ្តុះស័ក្តិសមសំរាប់អ្នកត្រូវការកាល់ឡូរីទាប ។







-**ពពាយ** : មានវីតាមីន C យ៉ាងច្រើន តែគួរទទួលទាននៅស្រស់ដូចជាប្រើធ្វើអន្លក់ជាដើម ។

-**ននោង** : ននោងជាបន្លែដែលមិនសូវមានសត្វល្អិតយាយី ទើបវាមានថ្នាំសម្លាប់សត្វល្អិតតិចជាងគេ ។ សំបកននោងជួយការពារសារជាតិអាហារមិនឱ្យខូចក្នុងការដាំស្ល ទើបគេមិននិយមចិតសំបកវាឱ្យអស់នោះទេ ។

-**បន្លែសាលាដ** : មានសារជាតិដែលបំពេញតួនាទី ចាំចាប់សារជាតិបង្ករោគមហារីក ហើយថែមទាំងមានវីតាមីន C ខ្ពស់ផងដែរ ។

-**បន្លែត្រកួន** : វាជួយកាត់បន្ថយជាតិស្ករនៅក្នុងឈាមស័ក្តិសមសំរាប់មនុស្សដែលកើតរោគទឹកនោមផ្អែម ។

-**ម្ទេស** : មានសារជាតិខេបស៊ីស៊ីន ដែលជាអ្នកចាំចាប់សារជាតិបង្ករោគមហារីក ហើយម្ទេសថែមទាំងជួយឱ្យចរន្តឈាមមានដំណើរការល្អ និងមិនកកគ្នាជាដុំទៀតផង ។

-**ប៉េងប៉ោះ** : អាចការពាររោគមហារីកបានទទួលទានប៉េងប៉ោះក្នុងមួយសប្តាហ៍១០ដង កាត់បន្ថយអាការកើតរោគមហារីកក្រពេញពងស្វាសបានដល់ទៅ ៤៥ ភាគរយឯណោះ ៕

## ចង់ស្អាតត្រូវតែ...

ដែលជាដើមហេតុធ្វើឱ្យសរសៃសក់ និងស្បែកឡើងខ្លាញ់បាននោះ ។

**៣-ទទួលទានប្រេងផ្កាឈើពណ៌លឿង ដើម្បីបំបាត់អាការរបកស្បែក** : ប្រសិនបើអ្នកមានស្ថានភាពស្បែកក្រៀមស្ងួតហើយងាយនឹងរលាត់ យើង សូមណែនាំឱ្យអ្នកទទួលទានប្រេងពី Primrose ផ្កាពណ៌លឿងដែលចំរាញ់ជាខែបសូលក្នុងមួយថ្ងៃ២គ្រាប់ ព្រឹកល្ងាច ឬក៏ទទួលទានត្រីសែលម៉ុនប្រឡាក់រ៉ូលផ្សេង អាហារសមុទ្រ ឬក៏បន្លែស្រស់ជំនួសក៏បានវានឹងជួយឱ្យស្បែក ព្រមទាំងស្បែកក្បាលរបស់អ្នកមានជាតិសំណើមឡើងមកវិញ ។

**៤-ទទួលទានស្វាយជួយឱ្យស្បែកទន់ ហើយរលោង :** ប្រសិនបើអ្នកចង់មានស្បែកទន់តោង ទទួលទានផ្លែស្វាយ ដែលមានបេតាការ៉ូទីន ជួយភ្ជោចនៃការសាងស្បែកដែលគគ្រើមឱ្យត្រឡប់មកជាទន់រលោង បានម្តងទៀត ។ ក៏ប៉ុន្តែប្រសិនបើអ្នកមិនចំណូលស្វាយ ក៏អាចទទួលទានដំឡូងបារាំង ការ៉ុត ក៏បានតែតោង ចាំទុកថា គួរទទួលទានរួមជាមួយស៊ុត និងថ្លើមសត្វ ។

**៥-ទទួលទានផ្លែត្របែកពន្យារភាពចាស់ជរា :** ផ្លែឈើស្រស់សំបូរទៅដោយ វីតាមីន C ដូចជាផ្លែត្របែកចាត់ទុកថា ជាចំណីសំរាប់មនុស្សដែលមិនចង់ឆាប់ចាស់ដោយសារវីតាមីន C មានគុណសម្បត្តិជួយរក្សាខលឡាចែន ប្រភពប្រូតេអ៊ីនក្រោមស្បែកក្នុងរាងកាយបានល្អ ធ្វើឱ្យស្បែករបស់អ្នកតឹងណែនមិនជ្រីវជ្រួញ ក្រៅពីនោះ អ្នកអាចទទួលទានផ្លែល្ហុង ក្រូច ក៏បានដូចគ្នា ៕

# ផលិតផលទឹកត្នោតមានគុណភាពខ្ពស់ និងទទួលការគាំទ្រខ្លាំង

***ភ្នំពេញ : គីម សារឿន***

ដើមត្នោតមានដុះនៅតាមវាលស្រែទីទួល និងតាមស្រុក ភូមិពាសពេញផ្ទៃប្រទេស ហើយត្រូវគេចាត់ទុកជាតំណាងព្រលឹងជាតិសាសន៍ខ្មែរទៀតផង ។ ជាច្រើនសតវត្សមកហើយអ្នកស្រុកបានទាញផលប្រយោជន៍ជាច្រើនពីដើមត្នោត ដូចជា ស្លឹក ផ្លែ និងទឹក ជាលក្ខណៈគ្រួសារសំរាប់ដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃបានធូរធារមួយកំរិត ។

ចាប់តាំងពីក្រុមហ៊ុនខុនហ្វីរ៉ែល ធ្វើការសិក្សាស្រាវជ្រាវ និងមានអ្នកឯកទេសមកពីបរទេសនោះ ក្រុមហ៊ុននេះបានបង្កើតឡើងជាផ្លូវការ និងដាក់លក់ផលិតផលទឹកត្នោតជាច្រើនប្រភេទសុទ្ធតែមានគុណភាពខ្ពស់ សំរាប់បំរើអតិថិជនទាំងក្នុង និងក្រៅប្រទេស ។ នៅឆ្នាំ២០០៣ ខុនហ្វីរ៉ែល បាននាំផលិតផលរបស់ខ្លួនលក់នៅលើទីផ្សារក្នុងស្រុក និងនាំយកទៅបរទេសទទួលបានការគាំទ្រកាន់តែខ្លាំង ។

រហូតមកទល់នឹងពេលនេះ ខុនហ្វីរ៉ែល បានផលិតនូវផលិតផលមួយចំនួនដូចជា ១. ស្រាទឹក ត្នោត៨ដឺក្រេ និង១១ដឺក្រេ ស្រាទឹកត្នោតច្រកដប ២. ទឹកខ្មេះទឹកត្នោតធម្មជាតិច្រកដបចំណុះ ៥០០មិល្លីលីត្រ ទឹកខ្មេះទឹកត្នោតម្រេចខ្ចីច្រកដបចំណុះ៥០០មិល្លីលីត្រ ៣. ភេសជ្ជៈទឹកត្នោតធម្មជាតិ ៤. ស្ករត្នោតសំរាប់ធ្វើដំណាប់ម្នាស់ប៉េងប៉ោះ និងចេក ។

ផលិតផលទាំងនេះត្រូវបានកញ្ញា លៀម សុជាតា អ្នកគ្រប់គ្រងផ្នែកលក់បានឱ្យដឹងថា ក្រុមហ៊ុនខុនហ្វីរ៉ែល បានលក់ផលិតផលទឹកត្នោត នៅតាមហាងផ្សារទំនើប ភ្ញៀវទេសចរ និងប្រទេសបារាំង កូរ៉េ ជប៉ុន អាមេរិក ព្រមទាំងប្រទេសជាច្រើនទៀតនៅអឺរ៉ុប ។

កញ្ញា លៀម សុជាតា បន្តថា បន្ទាប់ពីអ្នកឯកទេសយើងធ្វើតាមបច្ចេកទេសស្តង់ដាអន្តរជាតិ និងដាក់តាំងពិព័រណ៍នៅប្រទេសបារាំង សៀម យួន រួចមកស្ករត្នោតត្រូវគេទទួលស្គាល់ថា មានគុណភាពល្អ និងបានពានរង្វាន់ពីប្រទេសបារាំងថែមទៀតផង ។ ដោយសារតែខុនហ្វីរ៉ែល មានធនធានមនុស្សក្នុង ការផលិតការវេចខ្ចប់ បានត្រឹមត្រូវមានអនាម័យល្អ ធ្វើឱ្យអតិថិជនគាំទ្រកាន់តែច្រើន ។



ក្រុមហ៊ុនខុនហ្វីរ៉ែល ដែលបង្កើតឡើងនេះ មិនមែនសំរាប់លក់ផលិតផលនោះទេ គឺរួមចំណែកជួយអ្នកស្រុកឱ្យមានការងារធ្វើអាចទាញប្រយោជន៍ពីដើមត្នោតមានទឹកចិត្តស្រឡាញ់ថែរក្សាកេរដំណែលដូនតាឱ្យនៅគង់វង្ស ។

ជាមួយគ្នានេះដែរ កញ្ញា លៀម សុជាតាបានបញ្ជាក់ថា ខាងក្រុមហ៊ុនបានចុះទៅធ្វើការណែនាំដល់អ្នកស្រុកនៅតាមសហគមន៍នានា ក្នុងខេត្តកំពង់ស្ពឺ ពីរបៀបធ្វើស្ករត្នោត ទឹកត្នោត នៅពេលធ្វើបានក្រុមហ៊ុនទទួលទិញទាំងអស់ ។ តាមរយៈរបរឡើងត្នោតក៏បានជួយឱ្យពួកគាត់មានកាងារធ្វើចៀសវាងការផ្លាស់ប្តូរទីលំនៅ និងមានជីវភាពធូរធារ ។

អ្នកគ្រប់គ្រងទីផ្សាររូបនេះបញ្ជាក់ថា ដោយសារក្រុមហ៊ុនជួយដល់ប្រជាពលរដ្ឋបែបនេះហើយ ទើបអង្គការដុនបូស្កូ និងវិទ្យាស្ថាន CIRAD ក៏បានសហការជាមួយក្រុមហ៊ុនចុះជួយអ្នកស្រុកដល់ផ្ទះសំបែង ផ្នែកបច្ចេកទេស ការផលិត និងការដឹកជញ្ជូនជាដើម ។

ទន្ទឹមនឹងនេះដែរ ខាងក្រុមហ៊ុនបានសំដែងនូវការព្រួយបារម្ភចំពោះការបាត់បង់ដើមត្នោតជាបន្តបន្ទាប់ ដោយសារការកាប់បំផ្លាញ ។ ជាពិសេសអ្នកស្រុកដែលមានជីវភាពក្រីក្រមួយចំនួន បានលក់ដីឱ្យក្រុមហ៊ុន ឬពួកនាយទុន ធ្វើ

( តទៅទំព័រទី១៨ )

# ប្រេងនិងឧស្ម័នក្នុងដែនសមុទ្រ....

កំពុងស្វែងរកថវិកា២.៣០០ លានដុល្លារសំរាប់វិនិយោគកម្មវិធីសាធារណៈពីឆ្នាំ២០០៨ដល់២០១០ ខាងមុខនេះ ។

លោក សុន ឆ័យ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានឱ្យដឹងថា ការធ្វើអាជីវកម្មនេះស្ថិតក្នុងភាពអាថិកំបាំងមិនត្រូវបាន គេធ្វើការផ្សព្វផ្សាយជាសាធារណៈ ហើយលោកមានការព្រួយបារម្ភ



ផែនទីប្លុកប្រេងក្នុងដែនសមុទ្រកម្ពុជា

ចំពោះមន្ត្រីមួយចំនួនដែលពាក់ព័ន្ធនឹងបញ្ហានេះ អាចប្រព្រឹត្តិអំពើពុករលួយ ។

លោក សុន ឆ័យ បន្តថា ប្រសិនបើគ្រប់គ្រង មិនមានតម្លាភាពទេ បញ្ហាផ្សេងៗអាចកើតមានជាច្រើនទៀត ទោះបីជាប្រេងច្រើនបែបណា ក៏អ្នកក្រនៅតែក្រដដែល ។

គណបក្ស សម រង្ស៊ី, អង្គការសង្គមស៊ីវិល និងមន្ត្រីជំនាញមួយចំនួនបានសម្តែងនូវក្តីបារម្ភថា ប្រាក់ចំណូលដែលបានមកពីការធ្វើអាជីវកម្មប្រេង និងឧស្ម័ននេះ អាចនឹងធ្លាក់ក្នុងកណ្តាប់ដៃជនមានអំណាចមួយក្តាប់តូចប្រព្រឹត្តិអំពើពុករលួយផ្តេសផ្តាស ។ ជាពិសេសនោះ គេខ្លាចកម្ពុជាមិនអាចគ្រប់គ្រងចំណូលទាំងនោះបានហើយដើរ តាមគន្លងនៃប្រទេសនីហ្សេរីយ៉ា ដែលមានប្រេងដ៏ច្រើនហើយនៅតែក្រដដែល ។

ខណៈពេលដែលមានការព្រួយបារម្ភកាន់តែច្រើននោះ លោក ចូសេហ្វ ម៉ូសូមេលី អគ្គរដ្ឋទូតអាមេរិកាំងប្រចាំប្រទេសកម្ពុជា ក៏បានធ្វើការអំពាវនាវឱ្យមេដឹកនាំទាំងអស់ គួរមានសន្ទុះនយោបាយក្នុងការគ្រប់គ្រង និងប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីអាជីវកម្មប្រេង និងឧស្ម័នឱ្យបានត្រឹមត្រូវ ។

លោក ចូសេហ្វ ម៉ូសូមេលី បានបញ្ជាក់ថា ប្រសិនបើការគ្រប់គ្រងនោះមានតម្លាភាពប្រាក់ចំណូលនេះអាចជួយកែប្រែសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចំរើនមួយកំរិត ។ ជាពិសេសធ្វើឱ្យជីវភាពមន្ត្រីរាជការកាន់តែធូរធារប្រជាជនមានកំរិតជីវភាពខ្ពស់ ហើយសង្គមនឹងមានអភិវឌ្ឍន៍លើគ្រប់វិស័យ ។

ការយឺតយូរក្នុងការធ្វើអាជីវកម្មនេះ គឺបណ្តាលមកពីប្លុកប្រេងក្នុងសមុទ្រកម្ពុជាត្រួតស៊ីគ្នា និងប្រទេសសៀម ដែលដោះស្រាយគ្នាមិនទាន់ ដាច់ស្រេច ដោយសារភាគីសៀមទាមទារផលប្រយោជន៍ប្រហាក់ប្រហែលនិងកម្ពុជាដែរ ។

ការដោះស្រាយនោះ នៅតំបន់ដែលកៀកខាងសៀមទទួលបាន៩០ កម្ពុជា១០ តែបើនៅកៀកកម្ពុជាយើងគួរទទួលបាន៩០សៀម១០ ។ ប្លុកប្រេងកាតនេះស្ថិតនៅដែនសមុទ្រខ្មែរច្រើន ជាងហើយសៀមទាមទារប្រយោជន៍៦០ទល់នឹង៤០ ដែលខុសពីលក្ខខណ្ឌធ្វើឱ្យដំណោះស្រាយនេះ ត្រូវជាប់គាំងរហូតទល់សព្វថ្ងៃ ។

ទោះជាយ៉ាងណាគេសង្ឃឹមថា ភាពទល់ច្រកនេះនឹងទំលុះទំលាយចេញនៅពេលខាងមុខ តាមរយៈការទូតដោយសន្តិវិធីក្នុងនាមជាប្រទេសជិតខាង ។

ទាក់ទិននឹងបញ្ហានេះ ខ្មែរប៉ុស្តិ៍បានព្យាយាមសុំការបំភ្លឺពីលោក ស៊ាន ប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជាដែរ ប៉ុន្តែមិនអាចទំនាក់ ទំនងបានដោយសារប្រព័ន្ធទូរស័ព្ទរបស់លោកគ្មានអ្នកទទួល ៕

# ផលិតផលទឹកត្នោត...

ឱ្យពួកគាត់បាត់បង់ការងារធ្វើជាបណ្តើរៗ ហើយ ហើយដើមត្នោតក៏ប្រឈមមុខនឹងបាត់បង់ដែរ ។ កន្លងមកខាងក្រុមហ៊ុន Confirel បានធ្វើការងារជាមួយសហគមន៍១.០០០ ដែលមានអ្នកស្រុកប្រមាណ៥.០០០នាក់ ធ្វើត្នោតយកទឹកលក់ឱ្យ Confirel ដោះស្រាយជីវភាព និងខ្លះទៀតចាក់ស្ករលក់ឱ្យក្រុមហ៊ុន ។

កញ្ញា លៀម សុជាតា បានបន្តថា នៅថ្ងៃអនាគតក្រុមហ៊ុននឹងធ្វើការពង្រីកមុខរបររបស់ខ្លួនបន្ថែមទៀត តាមរយៈការបង្ហាត់បង្រៀនចំណេះដឹងដល់ប្រជាពលរដ្ឋទិញស្ករ ទឹកត្នោតក្នុងតំលៃខ្ពស់ជាងមុន ។ ការធ្វើបែបនេះនឹងជួយឱ្យពួកគាត់បញ្ឈប់ការកាប់ដើមត្នោត និងលក់ដីឱ្យឈ្មួញ ហើយបោះបង់មុខរបរចោល ។


ប្រជាពលរដ្ឋកំពុងរំងាស់ស្ករត្នោត

(តទៅទំព័រទី២០)

# ទំព័រសុខភាព

*រៀបរៀងដោយៈ គឹម ហៀន*

●●●សព្វថ្ងៃបញ្ហាសុខភាពបានចោទឡើងគួរឱ្យព្រួយបារម្ភណាស់ ។ សម័យវិទ្យាសាស្ត្រកាន់តែជឿនលឿននេះ ជម្ងឺដង្កាត់ក៏ផុសចេញមករាងសឹងមិនអស់ដែរ ។ យើងមិនហ៊ានចោទប្រកាន់ថា វិទ្យាសាស្ត្របង្កើតបង្កើនជម្ងឺឱ្យមនុស្សសត្វនឹងធម្មជាតិទេ ។ តែលផលសម្រេចបានរបស់វិទ្យាសាស្ត្រអាចនាំមកនូវផលបន្ទាប់បន្សំមួយ ឬលទ្ធផលបន្ទាប់បន្សំជាច្រើនទៀតដែលគេពុំចង់បានទាល់តែសោះ ឧទាហរណ៍ដូចវិទ្យាសាស្ត្រផ្នែកកសិកម្មទេ បានរកឃើញថ្នាំសម្លាប់ស្មៅ កក់ ផ្តុង ជាការរីកចំរើនជឿនលឿនមួយដ៏អស្ចារ្យ ។ ព្រោះថ្នាំជាតិគីមីនេះ ជួយកសិករឱ្យចំណេញពេលយ៉ាងច្រើន ក្នុងការជម្រះស្មៅស្រែចំការរបស់ខ្លួន ដោយមិនបាច់ប្រើដល់នង្គ័លរនាស់ទៀតទេ ។

គ្រាន់តែយកថ្នាំនេះបាញ់ទៅលើកក់ស្មៅក្នុងស្រែចំការរបស់ខ្លួនទៅ បីបួនថ្ងៃក្រោយកក់ស្មៅទាំងនោះនឹងងាប់រលួយទៅជាជីអស់តែម្តង ។ បើគិតពីសេដ្ឋកិច្ច គេបានទទួលផលចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់មកពីការរកឃើញរបស់វិទ្យាសាស្ត្រផ្នែកកសិកម្មនេះ ។ ប៉ុន្តែបើគិតពីលទ្ធផលបន្ទាប់បន្សំរបស់ថ្នាំនេះវិញ វាបង្កផលវិបាកអាក្រក់ដ៏ច្រើនដែលគេមិនអាចចៀសវាងបាន ពេលបាញ់ថ្នាំនេះរួចហើយត្រឹមនៅក្នុងទឹក ខ្យង ក្តាម នៅក្នុងរន្ធ អន្ទង់ ត្រីស្លួញ នៅក្នុងភក់ ក៏នាំគ្នាស្ទុះឡើងលើផ្ទៃទឹកប្រកាច់ស្លាប់គ្មានសល់ ។ បើបន្តការប្រើប្រាស់ថ្នាំនេះច្រើនសារទីវាលនេះ នឹងលែងមានស្មៅដុះតទៅទៀត ដីស្រែចំការនឹងក្លាយជាហិលសោះកក្រោះលែងដាំដុះអ្វីកើត ។ ឯអ្នកប្រើប្រាស់ថ្នាំនេះមិនបានត្រឹមត្រូវក៏ធ្លាក់ខ្លួនឈឺ ហើយអាចទៅដល់ជម្ងឺមហារីកទៀតផង ។ ជាតិថ្នាំនេះ ក៏ធ្វើឱ្យខូចបរិស្ថានយ៉ាងសម្បើមណាស់ដែរ ។ កាលសង្គ្រាមនៅវៀតណាម កងទ័ពអាមេរិកកាំងប្រើថ្នាំនេះ បាញ់ទៅលើព្រៃដែលជាជម្រករបស់ពួកយៀកកុង ប៉ុន្មានថ្ងៃក្រោយមកព្រៃនេះក៏ជ្រុះស្លឹកអស់គ្មានសល់ ។ បរិស្ថាននៅទីនោះក៏ក្លាយជាកន្លែងរស់នៅលែងកើតព្រោះគេសង្កេតឃើញថា មនុស្សនៅទីនោះក្រោយមកច្រើនកើតជម្ងឺមហារីក ។ ខ្ញុំក៏ចង់លើកពីឧទាហរណ៍ពីការរកឃើញថ្នាំពេទ្យម្យ៉ាងសម្រាប់ព្យាបាលជម្ងឺរបេងជាលើកដំបូង ឈ្មោះ

រីមីហ្វុង ។ ពីមុនកើតជម្ងឺរបេង គឺចប់ ដូចជាកើតជម្ងឺអេដស៍ក្នុងសម័យយើងសព្វថ្ងៃនេះដែរ ។ ដល់ពេលគេរកឃើញថ្នាំ រីមីហ្វុងនេះ ជម្ងឺរបេងត្រូវកំចាត់បានដូចជា ថ្នាំទិព្វ ។ ប៉ុន្តែដោយអ្នកប្រើមិនបានគោរពត្រឹមត្រូវតាមវេជ្ជបញ្ជា ក្រោយមកមេរោគក៏ស៊ាំនឹងថ្នាំ ហើយការប្រើថ្នាំនេះបន្តទៅទៀតមានផលវិបាកច្រើនយ៉ាង : អ្នកខ្លះបែរជា ឆ្កួត អ្នកខ្លះប្រែជារាំរៃ មិនប្រមជាតែក៏មិនព្រមស្លាប់ដែរ ។ នៅរស់ដោយវេទនា (រស់មិនរស់ ងាប់មិនងាប់) ។

ជម្ងឺដែលជួបប្រទះញឹកញាប់ជាងគេក្នុងជីវិតរស់នៅបច្ចុប្បន្នក្នុងប្រទេសរីកចំរើនក៏ ដូចជាប្រទេសក្រីក្រដែរ គឺជម្ងឺលើសឈាម (សំពាធឈាមខ្ពស់) ទឹកនោមផ្អែម (ជាតិស្ករនៅក្នុងឈាមខ្ពស់ហួសពីកម្រិតត្រូវការរបស់រាងកាយ) ជម្ងឺគ្រិនថ្លើម ឬជម្ងឺរលៀកថ្លើម ជម្ងឺមហារីក ។ល។ ជម្ងឺទាំងនេះបន្តកើតជារៀងរាល់ថ្ងៃ ព្រោះមនុស្សភាគច្រើនក្នុងលោកសន្និវាសន៍ ពុំបានដឹងច្បាស់ថា បុព្វហេតុណាខ្លះដែរ បណ្តាលឱ្យកើតជម្ងឺទាំងនេះឡើយ ។



មានជម្ងឺខ្លះអស់លោកអ្នកស្រាវជ្រាវ ក៏ពុំបានរកឃើញនូវបុព្វហេតុដែលបណ្តាលឱ្យកើតជម្ងឺដែរ តែអស់លោកគ្រាន់តែសាកល្បងព្យាបាលជម្ងឺតាមរោគសញ្ញា (Traitement symptomatique) នៃជម្ងឺតែប៉ុណ្ណោះ ។ ខ្ញុំខំសរសេរទំព័រនេះឡើង ដោយចង់ជួយឱ្យអ្នកអានបានជ្រាបខ្លះៗពីជម្ងឺដែលយើងតែជួបប្រទះរាល់ថ្ងៃដែលមានគ្រោះថ្នាក់ដល់ស្លាប់បាត់បង់ជីវិត តែបើយើងបានដឹងខ្លះៗពីបុព្វហេតុពីរបៀបទប់ទល់ ការពារ ថែទាំជម្ងឺ យើងអាចមានភាពកក់ក្តៅ ដូចមានប្រទីបកាន់នៅដៃ ដើរកាត់នៅផ្លូវងងឹត ។ តម្រានេះ គ្មានបំណងហ៊ឺកហ៊ឺនអស់លោកអ្នកអានក្លាយជាគ្រូពេទ្យឡើយ តែឱ្យដឹងថាពេលណា គួរទៅរកគ្រូពេទ្យកុំឱ្យហួសពេល ។

ខ្ញុំសរសេរអត្ថបទនេះ ដោយផ្អែកលើឯកសារ Asian Health Projects លើឯកសារបរទេសផ្សេងៗដែលខ្ញុំបានអាន ឯកសារ អានពីទស្សនាវដ្តីវៀតណាម Doi Moi នឹងចំណេះដឹងផ្ទាល់ខ្លួនខ្លះៗផង ព្រោះធ្លាប់បានជាអតីតនិស្សិតមហាវិទ្យាល័យពេទ្យក្រុងភ្នំពេញ ។ លើកក្រោយខ្ញុំសូមជូនជ្រាបនូវជម្ងឺលើសឈាម ឬសម្ពាធឈាមខ្ពស់ ៕

## ៣៣ឆ្នាំការវិលត្រឡប់របប....

ដែលគ្រងរាជ្យជាព្រះមហាក្សត្របានចូលទិវង្គត់ នៅក្នុងឆ្នាំ១៩៦០. តែនៅមានព្រះមាតារបស់ព្រះអង្គ គឺ ក្សត្រី ស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន បន្តគ្រប់គ្រងរាជ្យជាព្រះមហាក្សត្រិយានី ។

**ឆ្នាំ១៩៧០ :** ប្រាំបីឆ្នាំក្រោយមក លុះពេលចេញដឹងថា សម្តេច សីហនុ បានអនុញ្ញាតឱ្យយួនកុម្មុយនីស្តតាំងទ័ព និងទីបញ្ជាការសឹកនៅតំបន់ព្រំប្រទល់ខាងកើតនៃកម្ពុជា. សភាជាដែល ដែលបានប្រគល់តួនាទីប្រមុខរដ្ឋថ្វាយសម្តេច សីហនុ បានដកព្រះអង្គចេញពីតំណែងនេះទៅ ។

ក្រោយពេលជាង៣០ឆ្នាំបានកន្លងទៅហើយ គេអាចត្រិះរិះម្តងទៀត ស្វែងយល់អំពីហេតុជាចំបងខ្លះ ដែលនាំឱ្យព្រឹត្តិការណ៍ទាំងពីរខាងលើកើតឡើង ។ នៅក្នុងនគរដែលមានព្រះមហាក្សត្រផង មានប្រមុខរដ្ឋផង ជាអ្នកគ្រប់គ្រងកំពូលត្រួតគ្នាលើតួនាទីនយោបាយផង តួនាទីប្រតិបត្តិផង របស់នាយករដ្ឋមន្ត្រី គឺឧត្តមសេនីយ៍ លន់ នល់ ថែមទាំងមាន សម្តេច សីហនុ ដឹកនាំកិច្ចការជាតិទាំងអស់ផ្ទាល់ព្រះអង្គរវៀងរាល់ពេលវេលាទៅហើយ វិបត្តិស្មុគស្មាញដែលកើតឡើងតគ្នាមិនចប់បានជំរុញឱ្យមានការមិនពេញចិត្តចំពោះរបបរាជានិយមបន្តិចម្តងៗ បន្ថែមទៅលើការទិទៀនទាំងឡាយ ឯទៀតរបស់អ្នកសេរីនិយម ដែលប្រឆាំងរបបរាជានិយមស្រាប់ទៅហើយ ជាពិសេសនៅពេលសម្តេច សីហនុ ទ្រង់ "ខ្វាល់" តិះដៀលអ្នកដឹកនាំ ដែលបំពេញមុខការមិនបានពេញព្រះទ័យព្រះអង្គ ។

លោក ឆាំង សុង បានអះអាងថា ស្ថានការណ៍នេះបានធ្វើឱ្យអ្នកដឹកនាំមួយចំនួនសញ្ជឹងរិះរករបបគ្រប់គ្រងថ្មីមួយ ដែលអាចមានប្រសិទ្ធិភាពជាងរបបរាជានិយមមានរបបកុម្មុយនិស្ត និងរបបសាធារណរដ្ឋជាដើម ។ បញ្ញាវន្តខ្មែរមួយចំនួនទាំងមន្ត្រីទាំងសិស្ស គ្រូបង្រៀន បានសិក្សា និងជាប់ចិត្តទៅលើបដិវត្តន៍បារាំងឆ្នាំ១៧៨៩ ដែលបង្រៀនថា បារាំងបានព្យួ.កស្តេច កាត់.កស្តេចសម្លាប់ចោល ដើម្បីលប់ការគ្រប់គ្រងផ្តាច់ការរបស់ស្តេច ហើយលើកប្រជាជនឱ្យឡើងកាន់អំណាចរដ្ឋវិញ ។ មុនពេលទម្លាក់សម្តេច សីហនុ ចេញពីតំណែង និងមុនពេលប្រកាសសាធារណរដ្ឋខ្មែរ គេបានគាំទ្រស្វាត់ៗដល់ "គំនិតសាធារណរដ្ឋ " ។

អ្នកដឹកនាំខ្មែរត្រូវថ្នឹងថ្លែង ជជែកវែកញែកអស់រយៈពេលជាងមួយឆ្នាំ រៀបចំរបបសាធារណរដ្ឋ តាមរបៀបបោះឆ្នោតឱ្យកើតមានឡើង នៅក្នុងពេលដែលខ្មែរកំពុងច្បាំងវាយតបយ៉ាងប្តូរផ្តាច់ទល់នឹងទ័ពយួន ដែលបានចូលរាតត្បាតពេញប្រទេស ។ គ្រោះថ្នាក់រីកឡើងធំណាស់ ។ នៅពេលនេះយួនបានរុញក្បាលទ័ពរបស់គេដល់ស្ពានជិតភ្នំពេញណាស់ទៅហើយ ។ ប៉ុន្តែឆន្ទៈដ៏រឹងប៉ឹងក្នុងការគាំទ្រឧត្តមគតិសាធារណរដ្ឋទុកដល់ខ្មែរតទៅទៀត បានបង្កើត "កម្លាំងជាតិ " ជំរុញឱ្យខ្មែរសាធារណរដ្ឋធ្វើពលិកម្មតស៊ូការពារទឹកដីខ្មែររក្សាទឹកដីនេះជាជាតិឯករាជ្យបាន៥ឆ្នាំតមក ។

នេះជា "សេចក្តីសម្រេចចិត្ត" យ៉ាងក្លាហានរបស់ខ្មែរ ដែលបានស្រុះស្រួលគ្នាធ្វើឡើងតាមឆន្ទៈម៉ឺងម៉ាត់របស់ខ្លួនជា "ជាតិឯករាជ្យ " មិនចំណុះជាតិដទៃ បើកផ្លូវឱ្យពលរដ្ឋខ្មែរទាំងអស់ចូលរួមក្នុងការកសាងដឹកនាំប្រទេសជាតិដោយខ្លួនឯង ទទួលខុសត្រូវស្មើគ្នានៅមុខ " ច្បាប់ " ដែលពលរដ្ឋទាំងអស់នេះបានស្រុះស្រួលគ្នាចងក្រងឡើង ។

ទាក់ទិននឹងការដឹកនាំរបស់លោក លន់ នល់ នេះត្រូវបានលោក ប៊ិត ប៊ិន អាយុ៦៦ឆ្នាំ រស់នៅភូមិពាមរាំង ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល បានបញ្ជាក់ថា នៅសម័យ លន់ នល់ រូបលោកព្រមទាំងក្រុមគ្រួសារ ក៏មិនខុសប្លែកពីពលរដ្ឋខ្មែរដទៃទៀតដែរ គឺរងទុក្ខលំបាកវេទនាខ្លាំងណាស់ ។

លោក ប៊ិត ប៊ិន បានបន្តថា កាលនៅសម័យនោះ រូបលោកត្រូវគេដេញចាប់ឱ្យធ្វើទាហាន ហើយរត់គេចពីផ្ទះសំបែង ចោលប្រពន្ធកូនទៅរស់នៅក្នុងព្រៃ មិនសូវបានមកផ្ទះទេ ។ ក្នុងពេលនោះពួកទាហានអាមេរិកដែលគាំទ្រទាហាន លន់ នល់ បានទំលាក់គ្រាប់បែកពីលើអាកាសដូចគ្រាប់ភ្លៀងត្រូវអ្នកស្រុកខ្លះស្លាប់ របួស និងសំណង់សាធារណៈខូចខាតអស់យ៉ាងច្រើន ។

លោក ប៊ិត ប៊ិន បន្តទៀតថា ការរត់លួននោះ ធ្វើឱ្យក្រុមគ្រួសារជួបការលំបាកយ៉ាងខ្លាំង គឺមិនមានឱកាសរកស៊ីចិញ្ចឹមជីវិត ។ ណាមួយទំនិញឡើងថ្លៃកប់ពពក ដែលធ្វើឱ្យគាត់ត្រូវបង្ខំចិត្តរត់មកភ្នំពេញធ្វើជាកម្មករលីបាវ ដើម្បីដោះស្រាយជីវភាព ។

លោក វ៉ា សុខហេង អាយុ៧១ឆ្នាំ អតីតជាគ្រូបង្រៀននៅសម័យសាធារណៈរដ្ឋខ្មែរ បច្ចុប្បន្នរស់នៅក្រុងភ្នំពេញបានឱ្យដឹងថា នៅសម័យនោះប្រាក់ខែមន្ត្រីរាជការច្រើនគួរសមអាចចិញ្ចឹមគ្រួសារបាន ហើយធ្វើឱ្យមានកិត្តិយសថ្លៃថ្នូរ ធ្វើឱ្យអ្នករៀនសូត្រកាន់តែមានមោទនភាព ។ បើធៀបទៅនឹងសព្វថ្ងៃ អ្នករាជការម្នាក់មិនអាចចិញ្ចឹមខ្លួនឯងបានទេ លុះត្រាតែមានអ្នកផ្សេងជួយឧបត្ថម្ភ គឺប្រាក់ខែប្រហាក់ប្រហែលនឹងកម្មករប៉ុណ្ណោះ ។

លោក វ៉ា សុខហេង បន្តថា ខ្ញុំជឿលើសមត្ថភាពរបស់លោក លន់ នល់ ក្នុងការដឹកនាំប្រទេសជាតិ របបនោះបានរលំរលាយផុតទៅច្រើនឆ្នាំមកហើយ ។ ទោះជាយ៉ាងណាក៏ដោយលោកអះអាង ចំពោះគណបក្សដែលដឹកនាំដោយកូនប្រុសលោក លន់ នល់ នេះ លោកពុំទាន់សម្រេចចិត្តបោះឆ្នោតឱ្យ ឬយ៉ាងណាទេ ពីព្រោះលោកមិនទាន់ឃើញពីសមត្ថភាពដឹកនាំបន្តិចសោះនោះ ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី១៨ ខែមេសាកន្លងមកនោះ អតីតព្រះមហាក្សត្រនរោត្តម សីហនុ បានសរសេរក្នុងវេបសាយរបស់ព្រះអង្គថា "របបសាធារណៈរដ្ឋខ្មែរនៃពួកលន់ នល់ គឺជាការប្រកួតប្រជែងមួយនៃការប្រកួតប្រជែងដ៏ធំបំផុតនៅលើពិភពលោក បញ្ហាអំពើពុករលួយចោរកម្ម និងភូតកុហក ។

ក្នុងវេសាយបានបញ្ជាក់ថា "ដោយមិនអាចយកឈ្នះបន្តិចណាឡើយខាងនយោបាយប្រឆាំងនឹងខ្មែរក្រុមរបស់លោក លន់ នល់ បានពឹងផ្អែកកំលាំងអាកាសអាមេរិក ហើយចង្អុលប្រាប់នៅលើផែនទីភូមិសាស្ត្រ ជនបទឱ្យគេបំផ្លាញប្រជាជនត្រូវកំចាត់សំលាប់ដោយគ្មានក្តីមេត្តា ឬគ្មានស្ទាក់ ស្ទើរជាមួយនឹងគ្រាប់បែក និងការបាញ់កាំភ្លើងធ្លាក់ "។

ឌីឃែមបូឌាដេលលី ដែលដកស្រង់សំដីលោក គល់ បញ្ញា ប្រធានគណបក្សថា លន់ ឫទ្ធិ មានពេលវេលាតិចណាស់សំរាប់ធ្វើឱ្យគេស្គាល់ និងចាប់អារម្មណ៍ ទោះបីជាមនុស្សមួយចំនួនស្គាល់ លោក លន់ នល់ ក៏ដោយ ។ ជាពិសេសមនុស្សមួយភាគធំកើត ក្រោយឆ្នាំ ១៩៧០ គេពុំបានស៊ីជំរៅរឿងនយោបាយដឹកនាំប្រទេសជាតិរបស់លោក លន់ នល់ នោះទេ ។

អ្នកវិភាគនយោបាយមួយចំនួនយល់ថា ការវិលត្រឡប់របស់លោក លន់ ឫទ្ធិ ដែលចង់ដើរ តាមគន្លងរបស់ឪពុកខ្លួននោះ វាជារឿងមួយលំបាកទាំងផ្នែកពេលវេលា ធ្វើខ្លួនឱ្យគេស្គាល់ និងទាក់ទាញមហាជនឱ្យគាំទ្រ ។ លោកបញ្ជាក់ថា គណបក្សនេះទទួលបានការគាំទ្រតិចតួចបំផុត ក្នុងអាសនៈសភាពេលបោះឆ្នោតថ្ងៃទី ២៧ កក្កដា ឆ្នាំ២០០៨ខាងមុខ ៕

## ហ៊ុន សែន ឬ ញឹក ប៊ុនឆៃ ...

បណ្តឹងចោទប្រកាន់ទ្រង់ រណឫទ្ធិ ទៅតុលាការក្រុងភ្នំពេញ ពីបទលក់ទីស្នាក់ការគណបក្ស និងរំលោភលើសេចក្តីទុកចិត្ត ។ ក្នុងបណ្តឹងនេះ តុលាការបានផ្តន្ទាទោសទ្រង់ រណឫទ្ធិ ឱ្យជាប់គុក១៨ ខែ និងសងជំងឺចិត្តដោយប្រាក់១៥ម៉ឺនដុល្លារ ។

បញ្ហាទាំងអស់នេះត្រូវបាន ញឹក ប៊ុនឆៃ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច បញ្ជាក់ថា មុនពេលដែលមានសមាជនេះកើតឡើង រូបលោក និងក្រុមការងារបានទៅជួបទ្រង់ រណឫទ្ធិ នៅប្រទេសម៉ាឡេស៊ី និងណាត់ជួបគ្នានៅបាងកក ប្រទេសថៃ ជាញឹកញាប់ ដើម្បីយាងព្រះអង្គឱ្យដឹកនាំគណបក្ស ។ ប៉ុន្តែព្រះអង្គបដិសេធមិនព្រមមក និងចង់តែងតាំងលោក យូ ហុកគ្រី ជាអគ្គលេខាបក្ស ហើយលោក កែវ ពុទ្ធរស្មី លោកក៏មិនចង់បានតំណែងប្រធាននេះដែរ តែវាគ្មានជំរើស ។

ញឹក ប៊ុនឆៃ បន្តថា រឿងទាំងអស់នេះ វាបង្កឡើងដោយព្រះអង្គខ្លួនឯងផ្ទាល់ ពុំមែនរូបលោកទេ សូម្បីតែអតីតព្រះមហាក្សត្រ ក៏មិនចង់ឱ្យទ្រង់ រណឫទ្ធិ ធ្វើនយោបាយទៀតដែរ ពីព្រោះដឹកនាំគណបក្សតាំងពីរីកចំរើនរហូតជិតរលាយ ។

ទ្រង់ រណឫទ្ធិ ប្រៀបដូចជាកូនឆ្មារត្រូវទឹកក្តៅ គឺបានតែស្រែកឡាំប៉ាពីក្រៅប្រទេស ទីបំផុតព្រះអង្គក៏សំរេចបង្កើតគណបក្សមួយដោយដាក់ឈ្មោះខ្លួនឯង ដើម្បីប្រកួតប្រជែងការបោះឆ្នោត ។ ប៉ុន្តែ អ្វីដែលសំខាន់នោះ ព្រះអង្គត្រូវតុលាការចោទប្រកាន់មានទោសជាប់ខ្លួន មិនអាចយាងត្រឡប់ចូលមាតុប្រទេសបានឡើយ ធ្វើឱ្យប្រជាពលរដ្ឋដែលគាំទ្រព្រះអង្គអស់ក្តីសង្ឃឹមប្រៀបដូចទូកគ្មានច្រវ៉ា ។

ញឹក ប៊ុនឆៃ បញ្ជាក់ថា អ្នកដែលមិនឱ្យទ្រង់ រណឫទ្ធិ ធ្វើនយោបាយនោះ គឺអតីតព្រះមហាក្សត្រ និងមហាក្សត្របច្ចុប្បន្នទៅវិញទេ គឺអតីតព្រះមហាក្សត្របានប្រាប់ទ្រង់ រណឫទ្ធិ ពេលចូលគាល់នៅខេត្តសៀមរាប មុនទំលាក់ពីប្រធាន ថាកូនធ្វើនយោបាយតាំងពីខ្លាំងទៅខ្សោយកូន គួរតែឈប់ធ្វើទៅ ។

*** ហ៊ុន សែន បញ្ចេញប្រតិកម្ម ចំពោះការយាងត្រលប់របស់ទ្រង់ រណឫទ្ធិ :**

គណបក្សនរោត្តម រណឫទ្ធិ ដោយចង់បានមេដឹកនាំរបស់ខ្លួន ត្រឡប់ចូលប្រទេស ប្រកួតប្រជែងបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៨ បានដើរប្រមូលស្នាមមេដៃរាប់ម៉ឺននាក់ ដើម្បីឱ្យព្រះមហាក្សត្រលើកលែងទោស ។ ការពិតព្រះមហាក្សត្រមានព្រះរាជបុព្វសិទ្ធិគ្រប់យ៉ាង ដើម្បីលើកលែងទោសឱ្យអ្នកនយោបាយ ប៉ុន្តែ នៅពេល ហ៊ុន សែន ស្រែកតាមទូរទស្សន៍ លុះតាមតែមានការយល់ព្រមពីនាយករដ្ឋមន្ត្រីសិន រឿងនេះក៏ស្ងាត់ដូចគេចុក ។ ថ្មីៗនេះ ហ៊ុន សែន ដែលគេតែងចោទថា ជាមនុស្សសំបូរល្បិចកលក្នុងការបំបែកបំបាក់អ្នកដទៃ ដើម្បីការពារអំណាចខ្លួននោះ ក៏បានធ្វើការព្រមានទ្រង់នរោត្តម រណឫទ្ធិ ម្តងទៀត ជាសាធារណៈ នៅខេត្តក្រចេះ ដោយចង់ដករាជស័ព្ទនឹងពាក្យទ្រង់ទូលបង្គំចោល នៅក្នុងរដ្ឋសភាព្រឹទ្ធសភា និងរដ្ឋាភិបាល ។ លើសពីនេះ ហ៊ុន សែន បាននិយាយចំអកទៅអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រ នៅពេលជួបទ្រង់ រណឫទ្ធិ ជួយប្រដៅផង ។

***ហ៊ុន សែន បង្កបញ្ហាចំពោះទ្រង់ រណឫទ្ធិ :**

ក្នុងជីវិតនយោបាយរបស់ទ្រង់ រណឫទ្ធិ នេះ ត្រូវបានមតិជាតិ-អន្តរជាតិមើលឃើញថា ញឹក ប៊ុនឆៃ និង ហ៊ុន សែន ជា



ទ្រង់ រណឫទ្ធិ

អ្នករៀបចំឡើង មិនចង់ឱ្យ ទ្រង់ រណឫទ្ធិ មានឱកាសចូលរួមបោះឆ្នោតនៅ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះ ។

ចំណែកលោក មុត ចន្ថា មន្ត្រីអ្នកនាំពាក្យគណបក្សនរោត្តម រណឫទ្ធិ បាននិយាយក្នុងកម្មវិធីរាជានិយមថា រឿងរ៉ាវរបស់សម្តេចក្រុមព្រះ តាំងពីដើមដល់ចប់ គឺ ហ៊ុន សែន ជាអ្នកនៅពីក្រោយខ្នង ញឹក ប៊ុនឆៃ ដូចជាធ្វើសមាជដកទ្រង់ពីប្រធាន បក្សរៀបចំបណ្តឹងទៅតុលាការចោទប្រកាន់ មិនឱ្យចូលមាតុប្រទេស ជំរុញតុលាការកាត់ទោសទ្រង់ ។ ជាពិសេស ហ៊ុន សែន ប្រមាថស្នាមមេដៃរបស់ប្រជារាស្ត្រ ដែលគាំទ្រសម្តេចក្រុមព្រះ និងរារាំងមិនឱ្យព្រះមហាក្សត្រលើកលែងទោស ។

លោក មុត ចន្ថា បន្តថា ហ៊ុន សែន បានប្រើប្រាស់គ្រប់ឧបាយកលមានទាំងអាទិកំបាំង និងជាជំហរក្នុងការកំចាត់សម្តេចក្រុមព្រះចេញពីឆាកនយោបាយ ដើម្បីកុំឱ្យមានឱកាសវិលត្រឡប់មកចូលរួមបោះឆ្នោតនាពេលខាងមុខនេះ ។

អ្នកអង្កេតការណ៍ជាតិ-អន្តរជាតិ និងមជ្ឈដ្ឋាននានាថា ទ្រង់ រណឫទ្ធិ ពិតជាជួបនឹងផលវិបាកច្រើនក្នុងការរំដោះខ្លួនឱ្យមានសេរីភាពមានឱកាសធ្វើនយោបាយដូចដើមវិញ ។ ប៉ុន្តែ ទ្រង់ រណឫទ្ធិ នៅតែមានប្រជាប្រិយភាពក្នុងឆាកនយោបាយដដែល ហើយមានមនុស្សស្គាល់ច្រើន និងមានទំនុកចិត្ត ព្រមទាំងអាចទទួលបានការគាំទ្រពីសំណាក់មហាជនក្នុងការដណ្តើមយកអាសនៈរដ្ឋសភាខាងមុខ ៕

# បច្ចុប្បន្នភាពរឿងមិនគួរកើតនៅកម្ពុជា

### ពាក់អាវយោធាស្ទាក់ប្លន់ម៉ូតូចៅអធិការវត្ត

**ដោយ : ទីឃាយុ**

ព្រះគ្រូចៅអធិការវត្ត និងអាចារ្យវត្ត ដែលទើបនិមន្តមកពីបុណ្យបញ្ចុះសីមា ត្រូវចោរពីរនាក់ពាក់ឯកសណ្ឋានយោធាប្រដាប់ដោយកាំភ្លើង បានប្លន់យកម៉ូតូសេរី ១២៥ គេចខ្លួនដោយសុវត្ថិភាព ។

ហេតុការណ៍នេះ កើតនៅចំណុចស្ពានកន្ទួត ភូមិឯករាម ឃុំជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង កាលពីថ្ងៃទី១៩ មករា ឆ្នាំ២០០៨ ។

ព្រះចៅអធិការព្រះនាម ហ៊ាន សារឿន ព្រះជន្ម២៩ឆ្នាំ គង់នៅវត្តសុខោ ភូមិ២ ឃុំជើងទឹក ស្រុកកំពង់លាវ ។ ព្រះតេជគុណបានមានសង្ឃដីកាឱ្យដឹងថា នៅយប់នោះ ព្រះអង្គនិមន្តមកពីសូត្រធម៌បុណ្យបញ្ចុះសីមាជាមួយលោកអាចារ្យ និងអ្នកឧបម្នាក់ទៀត លុះពេលមកដល់ចំណុចកើតហេតុ ត្រូវបានក្រុមចោរប្រដាប់ដោយកាំ-ភ្លើង២ដើម ប្លន់យកម៉ូតូគេចដោយសុវត្ថិភាព ៕

### បងប្អូនបង្កើតយកគ្នាជាប្តីប្រពន្ធ

**ដោយ : ទីឃាយុ**

វាជារឿងមួយពិបាកនឹងជឿណាស់ បងប្អូនពីរនាក់ដែលមានឈាមជ័រឪពុកតែមួយម្តាយទីទៃ បានយកគ្នាជាប្តីប្រពន្ធ ហើយមានកូន៣នាក់ រស់នៅក្នុងខ្ទមកំសត់ ។ ហេតុការណ៍នេះកើតឡើង នៅភូមិកោះស្លា ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

គូស្នេហ៍ចំឡែកនេះ ប្តីឈ្មោះ ជា វ៉ិត អាយុ ៣៤ ឆ្នាំ រីឯប្រពន្ធឈ្មោះ ជា ស៊ីម អាយុ២៨ឆ្នាំ អ្នកទាំងពីររស់នៅផ្ទះជាមួយគ្នាតាំងតែពីតូចក្រូចឆ្មារម្ល៉េះ ។ លុះធំឡើងពួកគេដេកនៅជាមួយគ្នា រហូតកើតជាអណ្តាតភ្លើងតណ្ហាឆាបឆេះឡើង ។

លោក ជា វ៉ិត បានឱ្យដឹងថា ដោយសារតែភាពស្និទ្ធស្នាលខ្លាំងពេក ធ្វើឱ្យខ្លួនទប់ចិត្តលែងបាន ក៏ជំរុញឱ្យមានសេចក្តីស្នេហាជ្រាលជ្រៅជាមួយប្អូនស្រីឯង ហើយប្អូនស្រីក៏ដូចគ្នាដែរ ។

នៅថ្ងៃមួយពួកខ្លួនក៏សុំឪពុករៀបការដំបូងគាត់ជំទាស់ដែរ តែក្រោយមកក៏យល់ព្រម ។ អាពាហ៍ពិពាហ៍របស់ខ្លួន ត្រូវបានអ្នកភូមិសើចចំអកយ៉ាងខ្លាំង ប៉ុន្តែដោយសារសេចក្តីស្រឡាញ់ចេះតែទ្រាំទៅតាមគ្នាទៅចុះ ។

លោក ជា ជាង ជាឪពុកអាយុ៦៣ឆ្នាំ បានឱ្យដឹងថា គាត់ធ្លាប់មានកូនពីរនាក់ គឺទី១ ឈ្មោះ កុយ សារិន នៅភូមិពោធិ៍ខៀវ ឃុំគគីរធំ ស្រុកកៀនស្វាយ មានកូន៣នាក់ ហើយ ជា វ៉ិត ជាកូនទី៣ ។ ក្រោយមកប្រពន្ធគាត់ក៏ឈឺស្លាប់ ហើយគាត់ក៏បានយកប្រពន្ធមួយទៀត យួន លន់ មានកូន៥នាក់ ជាអកុសលប្រពន្ធទីពីរក៏ស្លាប់ចោលទៀត ។ ចំណែកឯកូនទាំងពីរសំបុកបានរស់នៅជាមួយគ្នាបង្កើតឱ្យមានសេចក្តីស្រឡាញ់កើតឡើង ដោយគ្មានអ្នកណារារាំង ហើយឪពុកម្តាយក៏មិនសូវនៅផ្ទះ ។

គូស្នេហ៍មួយនេះ ហាក់ដូចជាត្រូវបណ្តាសារបស់ព្រហ្មលិខិត ពួកគេមានជីវភាពលំបាកណាស់រកព្រឹកខ្វះល្ងាច ប៉ុន្តែទោះជាយ៉ាងណា ក៏ចំណងស្នេហារបស់ពួកគេនៅតែល្អូកល្អើននឹងគ្នាជានិច្ច ៕

### ជាប់របបយូរ ចាប់កូនស្រីអាយុ៨ឆ្នាំរំលោភ

**ដោយ : ទីឃាយុ**

ឪពុកមិនសូវគ្រប់ទឹកម្នាក់ ដែលត្រូវប្រពន្ធផ្តាច់របបខានរួមរ័កជាច្រើនខែ ដោយសារតែមានជំងឺប្រចាំកាយ ក៏ចាប់កូនស្រីរំលោភត្រូវតុលាការ ខេត្តកំពតផ្តន្ទាទោសឱ្យជាប់គុករយៈពេល១៥ឆ្នាំ ។

ស្ត្រីជាប្រពន្ធឈ្មោះ លីម លី អាយុ៤៤ឆ្នាំ បានរៀបរាប់ពីហេតុការណ៍នោះថា គាត់ធ្លាប់រៀបការប្តីទី១ ឈ្មោះ សារឿន បង្កើតបានកូនស្រីពីរនាក់ រស់នៅភូមិថ្មី សង្កាត់ព្រៃធំ ខណ្ឌកែប ក្រុងកែប ។ លុះដល់ឆ្នាំ១៩៩២ ប្តីគាត់ក៏បាត់ដំណឹងមិនដឹងទៅទីណា ។ ដោយសារស្ថានភាពលំបាកក្នុងភាពជាស្ត្រីមេម៉ាយ នៅឆ្នាំ២០០០ គាត់ក៏សំរេចចិត្តយកឈ្មោះ ជាតិ សាខន ជាប្តីរស់នៅជាមួយគ្នាបានកូន៣បីនាក់ ។

ស្ត្រី លីម លី បានបន្តថា ប្តីរបស់គាត់ត្រូវរបួសមានរោគសរសៃប្រសាទមិនសូវគ្រប់ទឹកទេ គឺរករឿងគាត់ស្ទើរតែរាល់ថ្ងៃ ។ នៅថ្ងៃទី២៥ ឧសភា ឆ្នាំ២០០៧ ពេលគាត់ត្រឡប់មកពីធ្វើការវិញ ខ្ញុំឮកូនស្រីអាយុ៨ឆ្នាំ ដែលសូវមិនគ្រប់ទឹកដែរ បានប្រាប់ថា ឪយកប្រដាប់ភេទមកដាក់លើប្រដាប់ភេទខ្ញុំ ។ គ្រាន់តែឮដូចនេះ គាត់ខឹងខ្លាំងណាស់ ក៏ដេរប្តីយ៉ាងចាស់ដៃ ហើយអ្នកស្រុកឮក៏ទៅប្តឹងប៉ូលិសឱ្យចាប់ខ្លួន ។ ខណៈនោះ សមត្ថកិច្ចបានមកចាប់ប្តីគាត់យកទៅកន្លែងប៉ូលិស និងនាំយកកូនស្រីទៅធ្វើកោសល្យវិច័យ តែមិនឃើញមានបាត់បង់អ្វីនោះទេ ។

ឈ្មោះ ជាតិ សាខន នេះ ពេលសមត្ថកិច្ចសួរម្តងឆ្លើយថា បានរំលោភកូនស្រីមែន ម្តងឆ្លើយថា អត់ទេ ។ ពេលនោះ សមត្ថកិច្ចបានសម្រេចបញ្ជូនទៅតុលាការ ហើយផ្តន្ទាទោសឱ្យជាប់គុករយៈពេល១៥ឆ្នាំ ៕

### ប៉ូលិសម្នាក់បង្ខំឱ្យក្មេងស្រីបៀមលិង្គ ត្រូវសមត្ថកិច្ចប៉េអឹមឃាត់ខ្លួន

**ដោយ : ទីឃាយុ**

ប៉ូលិសម្នាក់ ត្រូវបានសមត្ថកិច្ចប៉េអឹមឃាត់ខ្លួន បន្ទាប់ពីអាណាព្យាបាលក្មេងស្រី ដាក់ពាក្យបណ្តឹងពីបទបង្ខំឱ្យក្មេងស្រីបៀមលិង្គ កាលពីថ្ងៃទី២៧ មករា ឆ្នាំ២០០៨ កន្លងមក ។

ប្រភពព័ត៌មានពីក្រុមគ្រួសារក្មេងស្រីរងគ្រោះ

( តទៅទំព័រទី២១ )

## ផលិតផលទឹកត្នោតមាន...

ទោះបីជាយ៉ាងណាខាងក្រុមហ៊ុន Confirel ក៏បានធ្វើការអំពាវនាវចំពោះប្រជាកសិករទាំងអស់មេត្តាជួយគាំទ្រផលិតទឹកត្នោតផង បើពុំនោះពួកគាត់នឹងជួបការលំបាក ហើយលក់ដីស្រែ ចំការផ្ទះសំបែងអស់ជាពុំខាន ។ ជាពិសេសរាជរដ្ឋាភិបាលជួយជំរុញផលិតផលរបស់ខ្មែរតាមរយៈការចំណេញក្នុងតំលៃថោក និងបញ្ហាមួយចំនួន ដើម្បីឱ្យផលិតផលខ្មែរយើងអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន ។

យោងតាមឯកសាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅសម័យសង្គមរាស្ត្រនិយម ដើមត្នោតមានប្រហែល៦លានដើម ប៉ុន្តែដោយសារតែសង្គ្រាមអូសបន្លាយនោះ បានធ្វើឱ្យដើមត្នោតត្រូវបំផ្លាញអស់មួយភាគធំ គឺនៅសល់ប្រហែល៣លានដើមប៉ុណ្ណោះ ។ ខេត្តដែលដុះដើមត្នោតច្រើនជាងគេ គឺខេត្ត កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពត, កណ្តាល, តាកែវ, ព្រៃវែង, ស្វាយរៀង... ។

អ្នកឯកទេសបានអះអាងថា មានដើមត្នោត ប្រមាណ៤០ភាគរយប៉ុណ្ណោះដែលគេទាញជាប្រយោជន៍បាន ហើយដើមត្នោតមួយដើមអាចប្រមូលផលបានពី១០១ទៅ២២៤ដុល្លារក្នុងមួយឆ្នាំ ។ គ្រប់ផ្នែកនៃដើមត្នោតត្រូវបានគេទាញជាផលប្រយោជន៍ទាំងអស់ ហើយអ្នកនិពន្ធក៏បានសរសេរជាទំនុកច្រៀងយ៉ាងពិរោះជក់ចិត្តពីសារប្រយោជន៍របស់ត្នោត ។ ជាពិសេសនោះដើមត្នោតតំណាងឱ្យព្រលឹងជាតិទឹកដីរបស់ជាតិសាសន៍ ដែលបុព្វបុរសតែងនិយាយថា ទីណាមានដើមត្នោតដុះ គឺទីនោះជាទឹកដីខ្មែរ ៕

## ហ៊ុន សែន លុបភាសា ...

យោងតាមឌីប៉ៃបូឌាដេលី បានបញ្ជាក់ថា ហ៊ុន សែន បាននិយាយកាលពីថ្ងៃទី១៨ មេសា ថា ឈប់ប្រើគោរមងារសំរាប់រាជវង្សានុវង្សក្នុងឆាកនយោបាយហើយ ។ បញ្ហានេះ ត្រូវបានលោក ងួន ញ៉ិល អនុប្រធានទី១រដ្ឋសភា លើកហេតុផលថា ត្រូវដាក់រាជវង្សានុវង្សឱ្យនៅក្នុងការប្រកួតប្រជែងស្មើភាពគ្នាក្នុងឆាកនយោបាយខាងមុខនេះ ។

លោក ងួន ញ៉ិល បន្តថា បើចង់ធ្វើសមាជិករាជវង្សានុវង្ស សូមកុំពាក់ព័ន្ធនឹងឆាកនយោបាយ ហើយបើពាក់ព័ន្ធនយោបាយកុំចាត់ទុកខ្លួនថា ជាសមាជិករាជ្យានុវង្ស ។ ករណីនេះ លើកលែងតែអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រពីរអង្គប៉ុណ្ណោះ ។

ម្ចាស់ក្សត្រី ស៊ីសុវត្ថិ សាវតា សមាជិកសភាគណបក្សហ៊្វុនស៊ិនប៉ិច បានបញ្ចេញប្រតិកម្មខ្លាំងទៅនឹងការហាមប្រាមនេះ ហើយព្រះអង្គមានព្រះ-បន្ទូលថា ក្រុមមេដឹកនាំកំពូលរបស់រាជរដ្ឋាភិបាលគួរតែស្វែងយល់ពីរាជស័ព្ទ ពីព្រោះជាវប្បធម៌ខ្ពង់ខ្ពស់របស់យើងទាំងអស់គ្នា ។

ម្ចាស់ក្សត្រីបន្តថា នេះគឺជាការប្រមាថមួយប្រសិនបើក្រុមមន្ត្រីរដ្ឋាភិបាលទាំងនោះមិនប្រើរាជស័ព្ទ ។

លោក មុត ចន្ថា អ្នកនាំពាក្យគណបក្សនរោត្តមរណឫទ្ធិ បានហៅបញ្ហានេះថា គឺជាការប្រមាថ ហើយពួកគេមិនគោរពរបបរាជានិយមធិបតេយ្យ ។ លោកក៏បានធ្វើការថ្កោលទោសធ្ងន់ៗចំពោះលោក ហ៊ុន សែន ដែលចេញបទបញ្ជានេះ ៕

## សម្តេចនរោត្តម សីហនុ....

ក្រុមខ្មែរ យៀកមិញ នោះ នាឆ្នាំ១៩៧៥ ។

តើការស្លាប់បាត់បង់ជីវិតរបស់ជនជាតិខ្មែរស្លូតត្រង់ ជាពិសេសអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ទាំងទាហានទាំងស៊ីវិល បញ្ញាវន្ត សំខាន់ៗ បានចេញពីនយោបាយប្រមុខរដ្ឋ សីហនុ ឬចេញមកពីសេនាប្រមុខ លន់ នល់ ដែលបណ្តាលឱ្យជីវិតច្រើនរាប់លាននាក់ ត្រូវស្លាប់ និងច្រើនលាននាក់ ត្រូវរងទុក្ខវេទនា រហូតមកដល់សព្វថ្ងៃនេះ ។

តើលោក ហ៊ុន សែន ជា ស៊ីម ហេង សំរិន និងក្រុមអ្នកគាំទ្រគណបក្សប្រជាជនខ្មែរ យៀក មិញ សព្វថ្ងៃនេះ តែងតាំងឡើងដោយកងទ័ពព្រៃក្រហមនៃប្រទេសណា ?

តើពួកនេះ មានសេចក្តីសុខសាន្តកិត្តិយស និងទ្រព្យសម្បត្តិស្តុក-ស្តម្ភមហាសាល ដោយសារហេតុអ្វី ?ដោយសារព្រមធ្វើអាយ៉ងមែនឬទេ ?

តើក្រុមពួកនេះមានសេចក្តីសុខសាន្តកិត្តិយស និងទ្រព្យសម្បត្តិមហាសាល ដោយសារលុយដុល្លារ ឬដោយសារលុយដុងយួន ? ដែលបណ្តាលឱ្យក្រុមពួកនេះ ក្លាយទៅជាអ្នកប្រើអំណាចផ្តាច់ការក្នុងការដឹកនាំប្រទេសជាតិខ្មែរសព្វថ្ងៃ រហូតធ្វើឱ្យប្រទេសខ្មែរបានក្លាយទៅជាមាន ឈ្មោះថា "ប្រទេសសំរាប់លក់ ឬប្រទេសហ៊ុន សែន" ដូចគ្នាសម័យសង្គមរាស្ត្រនិយមមានឈ្មោះថា "ប្រទេសសីហនុ" "Cambodia of Sihanouh" នោះដែរ ។

ជនជាតិខ្មែររស់នៅក្រៅប្រទេស និងក្នុង ប្រទេសទាំងអស់ ដែលជាសកម្មជន បានដឹង និងយល់ច្បាស់អំពី ទង្វើ និងការប្រព្រឹត្តរបស់អតីតព្រះមហាក្សត្រខ្មែរ និងបច្ចុប្បន្ន មេដឹកនាំខ្មែរ បានប្រឹងពង្រីកសតិស្មារតី ឧត្តមគតិ ស្នេហា ជាតិយ៉ាងរឹងមាំជានិច្ច មិនអាចយល់ស្របតាម ចំណារលិខិតរបស់អតីតរបស់មហាក្សត្រនេះបានទេ ប៉ុន្តែ យើងមានការស្រណោះស្រណោកសោកស្តាយណាស់ចំពោះជនជាតិខ្មែររួមឈាម ដែលពុំបានដឹង និងបានឆ្លងកាត់នៅក្រោមការដឹកនាំរបស់អតីតប្រមុខរដ្ឋសីហនុនេះ ដែលព្រះអង្គតាំងខ្លួនឯងថា ជាអ្នកគ្មានកំហុសហើយស្នេហាជាតិពិតប្រាកដណាស់ទៅវិញទេ ៕

**ទស្សនៈ លោក ម៉ម យិន**



# ហោរាសាស្ត្រ ប្រចាំខែ ឧសភា ថ្ងៃទី ២២_០៧



### ឆ្នាំជូត : (ពង្សទេវតាប្រុស ធាតុទឹក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះលោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិតប្រាជ្ញាឈ្លាសវៃ ទោះបានប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចដំណើរបានស្រួលដែរ ។ បើលោកអ្នកបានជួបពិគ្រោះពិភាក្សាការងារក៏ឆាប់និយាយត្រូវរ៉ូវ និងចុះសម្រុងនឹងគ្នាដែរ តែដាច់ខាតមិនត្រូវសម្តែងឫកក្រអឺតក្រទមឡើយ ពុំនោះសោតអាចជួបការបរាជ័យវិញ ៕



### ឆ្នាំឆ្លូវ : ( ពង្សមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ នៅក្នុងគ្រួសារមានសិរីសួស្តីបងប្អូនញាតិសន្តានប្រុសស្រីប្រកបតែសេចក្តីសុខក្សេមក្សាន្ត ព្រមទាំងអាចរកស៊ីមានបានទៅតាមមុខជំនួញរៀងៗខ្លួនទៀតផង ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ ហាក់ដូចជាមានមន្តស្នេហ៍អ្វីម្យ៉ាង ព្រោះត្រូវបានកំលោះៗ ឬបុរសពោះម៉ាយចោមរោមស្រលាញ់ ព្រមទាំងសុំធ្វើជាគូអនាគតអស់មួយជីវិត ៕



### ឆ្នាំខាល : ( ពង្សយក្សស្រី ធាតុឈើ )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹង បញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះដែរ ទោះជាលោកអ្នកប្រកបកិច្ចការងារអ្វីក៏ដោយ គឺមិនត្រូវធ្វើទាំងងងឹតងងុលខ្វះការពិចារណាឡើយ ជាពិសេសមុននឹងសេពគប់ជាមួយនឹងមិត្តភ័ក្តិ ឬមុននឹងរកស៊ីចូលហ៊ុនជាមួយ នឹងអ្នកណាម្នាក់ ចូរចេះសង្កេតតាមដានមើលសមាសភាពមនុស្សល្អ និងអាក្រក់ឱ្យបានត្រឹមត្រូវ ។ ចំពោះ គូស្នេហ៍ក្នុងរយៈពេលនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



### ឆ្នាំថោះ : ( ពង្សមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសំរេចសមតាមបំណងប្រាថ្នាទាំងអស់ ។ លោកអ្នកអាចបណ្តាក់ទុនរកស៊ី ឬក៏ចេញទៅជួញដូរផ្លូវឆ្ងាយមិនថាផ្លូវគោក ឬផ្លូវទឹកឡើយ គឺសមប្រកប តែទាំងអស់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ ប្រកបតែភាពផ្អែមល្ហែមដូចទឹកឃ្មុំ និងត្រជាក់ត្រជុំដូចទឹកអម្រឹត ៕



### ឆ្នាំរោង : (ពង្សទេវតាប្រុស ធាតុមាស)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វី ក៏ដោយ ក៏អាចទទួលបានផលសំរេចសមតាមបំណងប្រាថ្នាទាំងអស់ ។ លោកអ្នកអាចបើកហាងលក់ដូរថ្មី ព្រោះពុំគ្រាន់តែអាចរកផលចំណូលបានច្រើនប៉ុណ្ណោះទេ ថែមទាំងអាចប្រមូលអតិថិជនបានច្រើនទៀតផង ៕



### ឆ្នាំម្សាញ់ : (ពង្សមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងឧបសគ្គច្រើន ។ ក្នុងរយៈពេលនេះជួញជិតល្អជាងជួញឆ្ងាយ ព្រោះការដើរឆ្ងាយច្រើនជួបស៊យ និងបានត្រឹមតែបាតដៃទទេត្រឡប់ចូលផ្ទះតែប៉ុណ្ណោះ ។ បើជាអាជីវកអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការពូសារពើ ចូរមានស្មារតីប្រយ័ត្នក្រែងមានជនខិលខូចបន្លំភ្នែកស្រស់ៗ ឬក៏ឆក់ប្លន់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ ចូរកុំមានចិត្តប្រចណ្ឌផ្តេសផ្តាសប្រយ័ត្នអាចប្រេះឆាគ្នា ៕



### ឆ្នាំមមី : (ពង្សទេវតាស្រី ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ក៏តែងតែបានជួបនឹងឧបសគ្គផ្សេងៗមករាំងស្កាត់ ដូច្នេះទាល់តែពុះពារបន្តិច ទើបមិនលិចលង់ទាន់ ។ ក្រៅពីនោះបើមានរឿងជម្លោះកើតឡើង ចូរចេះអត់ធ្មត់និងរំងាប់ចិត្តឱ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ៕



### ឆ្នាំមមែ : (ពង្សទេវតាស្រី ធាតុមាស)

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុនពេលចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើលិខិតស្នាមផ្សេងៗ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាត់ស្នៀត តែបន្តិចអាចបង់ខាតផលប្រយោជន៍ច្រើន ៕



### ឆ្នាំវក : (ពង្សយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខសន្សឹមៗ ។ ក្នុងរយៈពេលនេះមុជមិនជ្រៅទៅមុខមិនឆ្ងាយឡើយ ដូច្នេះបើលោកអ្នកប្រកបកមុខរបរអ្វីតោងធ្វើដោយប្រុងប្រយ័ត្នប្រយែងជា ពិសេសត្រូវមានគំរោងផែនការឱ្យបានច្បាស់លាស់ ទើបអនុវត្តបានស្រួល ។ ក្នុងរយៈពេលនេះបើលោកអ្នកមានបំណងចង់ពង្រីកមុខរបរ គឺមិនខុសទាស់អ្វីឡើយ តែកុំធ្វើដោយទ្រង់ទ្រាយធំហួសពីកម្លាំងសមត្ថភាពឡើយ ៕



### ឆ្នាំរកា : (ពង្សយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកប្រកបកកិច្ចការងារអ្វីក៏ដោយ ចូរកុំធ្វើទាំងចិត្តតក់ក្រហល់ឱ្យសោះ ជាពិសេសមុននឹងរកស៊ីចូលហ៊ុនជាមួយនឹងអ្នកណាម្នាក់ ចូរត្រិះរិះពិចារណាឱ្យបានល្អិតល្អន់ ទើបមិនជួបគ្រោះចាញ់បោកគេ ៕



### ឆ្នាំច : ( ពង្សយក្សស្រី ធាតុដី )

រាសីលោកអ្នកធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែកិច្ចការងាររកស៊ីជួបនឹងឧបសគ្គខ្លះៗក្តី តែមិនចោទជាបញ្ហាធ្ងន់ធ្ងរឡើយ ព្រោះលោកអ្នកអាចរកដំណោះស្រាយ និងច្រកចេញជាបណ្តើរៗ ។ ក្រៅពីនោះចំពោះបុរស បើមានមនុស្សស្រីសម្តីផ្អែមល្ហែមលួងលោម ចូរប្រយ័ត្នប្រយែងបន្តិចខ្លាចក្រែងទប់ចិត្តមិនបានអាចអស់ដីធ្លី អស់ផ្ទះសម្បែង ឬអស់រថយន្តម៉ូតូ ៕



### ឆ្នាំកុរ : (ពង្សមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះឱកាសល្អៗបានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវរវៀសរវៃញាប់ដៃញាប់ជើងបន្តិច ព្រោះពេលវេលាជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ តែចូរកុំមានចិត្តលោភលន់ដោយចង់មានចង់បានឱ្យហួសប្រមាណពេកទេ ព្រោះការលោភលន់នាំមកនូវក្តីវិនាសអន្តរាយ ៕

## បច្ចុប្បន្នភាពរឿងមិនគួរកើត...

បានឱ្យដឹងថា ជនល្មើសនោះឈ្មោះ ចេង លីហួរ អាយុ៤១ឆ្នាំ ជាប៉ូលិសផ្នែកវិទ្យុទាក់ទងនៃស្នងការខេត្តកោះកុង ដែលមានទីលំនៅសង្កាត់ចាក់ អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ប្រភពដដែលបានបន្តថា នៅយប់ថ្ងៃទី២៦ មករា ឈ្មោះ ចេង លីហួរ បានផឹកស្រានៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រួចហើយក៏បបួលកូនរបស់ខ្លួនឱ្យចូលបន្ទប់ទឹក បង្ខំឱ្យស្រាតខោអាវ រួចឱ្យបៀមលិង្គ ។ ជនល្មើសបានគំរាមកូនស្រីគាត់មិនឱ្យនិយាយប្រាប់នរណា បើពុំនោះទេ នឹងសំលាប់ចោល ។

នៅពេលដែលកូនស្រីប្រាប់រឿងនេះ គាត់ក៏ទៅដាក់ពាក្យបណ្តឹង ហើយត្រូវកងរាជអាវុធហត្ថ ចាប់ខ្លួន នៅថ្ងៃទី២៧ មករា ផ្តន្ទាទោសតាមច្បាប់ ៕

## ខ្លាចប្តីចាប់ចងជើងញាត់អំបិលចូល ទ្វារមាស អំពាវនាវឱ្យសមត្ថកិច្ចជួយ

***ដោយ : ទីឃាយុ***

ស្ត្រីចំណាស់ម្នាក់ឈ្មោះ យ៉ែម យ៉ៃ អាយុ៥០ ឆ្នាំ រស់នៅភូមិទួលអំពិល ឃុំល្បើក ស្រុកឈូក ខេត្តកំពត បានទទួលរងនូវការវាយដំយ៉ាងឃោរឃៅពីសំណាក់ប្តីរបស់ខ្លួន ។ ជាពិសេសនោះគាត់ប្តីរបស់ខ្លួនចាប់ចងជើងព្យួរនឹងដើមអំពិល ហើយញាតិអំបិលម្ទេសចូលទ្វារមាសយ៉ាងឃោរឃៅពេលនេះ គាត់បានអំពាវនាវឱ្យសមត្ថកិច្ចជួយការពារសុវត្ថិភាពផង ។

ស្ត្រីឈ្មោះ យ៉ែម យ៉ៃ បានឱ្យដឹងថា ប្តីគាត់ស្រវឹងជោកជាំរាល់ថ្ងៃ ហើយតែងវាយដំកូនចៅ និងរូបគាត់ស្ទើរលស់ថ្ងៃណាស់ ។ នៅថ្ងៃទី២៤ សីហា ឆ្នាំ២០០៧ ប្តីគាត់ឈ្មោះ មុជ អំ អាយុ៤៧ ឆ្នាំ បានវាយដំកូនប្រុសយ៉ាងខ្លាំង ឃើញដូច្នេះ គាត់អត់ទ្រាំមិនបានក៏ទៅឃាត់ ។ ប្តីរបស់គាត់ខឹង ក៏ចាប់គាត់ចងនឹងដើមអំពិល វាយព្យួរជើងឡើងលើ ហើយយកអំបិលម្ទេសញាត់ចូលទ្វារមាស ឈឺក្រហល់ក្រហាយខ្លាំងណាស់ ។

ស្ត្រីអភ័ព្វនេះ បាននិយាយទាំងអួលដើមកថា ដោយអត់ទ្រាំមិនបាន ក៏ប្តឹងប៉ូលិសឱ្យចាប់ដាក់គុករយៈពេល១ឆ្នាំ ។ លុះដល់ចុងឆ្នាំ២០០៧ ប្តីគាត់បានយកកាំបិតមកគំរាមយកមាសពីគាត់ចំនួន២ជី ទៅបាត់ទៀត ។ ពេលនេះគាត់ភ័យខ្លាំងណាស់ ស្ទើរតែមិនហ៊ានដេកនៅលើផ្ទះ ហើយអំពាវនាវឱ្យសមត្ថកិច្ចជួយការពារសុវត្ថិភាពផង ៕

## មាត់ស៊ីអំបិលប្រហុកថាចេះអាបធ្មប់ ត្រូវអ្នកស្រុកបណ្តេញចេញពីភូមិ

***ដោយ : ទីឃាយុ***

បុរសជនជាតិខ្មែរលើ ដែលរស់នៅតំបន់ចុងកាត់មាត់ញូកក្នុងភូមិដរធំ ឃុំយ៉ាទុក ខេត្តរតនគិរី ដែលឧស្សាហ៍និយាយលេងសើចថា ចេះធ្វើអាប ធ្មប់ ត្រូវអ្នកស្រុកបណ្តេញលែងឱ្យនៅក្នុងភូមិ ។ ប៉ុន្តែ ពេលនេះត្រូវបានមន្ត្រីអង្គការសិទ្ធិមនុស្ស អាដហុក ជួយសំរួលឱ្យមករស់នៅក្នុងភូមិវិញហើយ ។

បុរសឈ្មោះ ក្លាន ជ័រ អាយុ៤២ឆ្នាំ រួមទាំងប្រពន្ធ និងកូន៧នាក់ ត្រូវអ្នកស្រុកចោទប្រកាន់ថា ចេះធ្វើអាបធ្មប់ ហើយបានលើកគ្នាមកបណ្តេញលែងឱ្យរស់នៅក្នុងភូមិ ព្រោះកន្លងមកគាត់ធ្លាប់និយាយអួតអាងធ្វើអំពើអាបធ្មប់ ។ នៅថ្ងៃទី១៥ ធ្នូ ឆ្នាំ២០០៧ គាត់បានទៅប្តឹងមេឃុំ និងមន្ត្រីអង្គការសិទ្ធិមនុស្សឱ្យជួយសំរួល និងការពារសុវត្ថិភាពរបស់ពួកគាត់ផង ។

លោកមេភូមិ រចំ ហុស និងបក្ខពួក៤នាក់ បានដឹកនាំប្រជាពលរដ្ឋប្រមាណ២០០នាក់ ទៅបណ្តេញ លោក ក្លាន ជ័រ ដោយសង្ស័យថា បានធ្វើឱ្យអ្នកភូមិឈឺគ្រុនក្តៅជាបន្តបន្ទាប់ ។ លោក ប៉ែន ប៊ុណ្ណារី មន្ត្រីសិទ្ធិមនុស្សអង្គការអាដហុក បានធ្វើការសំរបសំរួលបញ្ហានេះ ព្រមទាំងឱ្យអ្នកធ្វើការសន្យាលែងបង្កទំនាស់ និងបណ្តេញឈ្មោះ ក្លាន ជ័រ ទៀត ៕

FreeLife
The Himalayan Goji Company®

# the World's Most Powerful Anti-Aging Food

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេ
ក្នុងលោក គឺទឹកផ្លែឈើ "គោជី "
នៃព្រៃហេមពាន្ត






## HIMALYAN GOJI
## Juice

ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំងឆ្នាំ ៨00 គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។
ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIOES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។
បើចង់បានមកពិសារ www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

## TIME Magazine wrote :

" this year's breakout (Superfruit ) was the Himalyan Goji Berry , said to be A source of energy and longevity "
To order, please visit the website at : **www.forever.freelife.com**
**Or please call (267) 253-3947 to order**